# ពាក្យប្រារព្ធ

ការសិក្សានូវព្រះពុទ្ធភាសិត ឈ្មោះថាបានសេពគប់ជាមួយនឹងព្រះអរិយៈ ការសេពគប់នឹងព្រះអរិយបុគ្គល ជាការល្អប្រសើរ ព្រោះញ៉ាំងប្រយោជន៍ឱ្យសម្រេច ដូចសក្កទេវរាជពេលជិតច្យុត និង បញ្ចសិខគន្ធព្វបុត្ត ស្រឡាញ់ស្នេហានាងសុរិយវច្ឆសា ជាដើម ។

## សក្កទេវរាជសម្រេចមគ្គផល

ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅនាវេឡុវ-គ្រាមទ្រង់មាននូវអាពាធដ៏ធ្ងន់គឺចុះព្រះលោហិត ព្រះអង្គទ្រង់ប្រារព្ធសក្កទេវរាជ ។ សក្កទេវរាជបានមកបម្រើព្រះបរមសាស្តា ទូលឧច្ចារៈលាយដោយព្រះលោហិតលើព្រះសីសៈ ប្រព្រឹត្តដោយសេចក្តីគោរពយ៉ាងក្រៃលែងដែលធ្វើឱ្យភិក្ខុទាំងឡាយពោលសរសើរ ។ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជ

ធ្វើនូវការគោរពស្រឡាញ់ចំពោះតថាគតនេះ មិនគួរឱ្យអស្ចារ្យឡើយ ព្រោះសក្កទេវរាជស្តាប់ធម៌ទេសនាហើយ សម្រេចសោតាបត្តិផល លះបង់នូវជរាភាព បានជាព្រះឥន្ទ្រកំលោះ អាស្រ័យនឹងតថាគត នៅនាឥន្ទ្រសាលគុហា ព្រមដោយទេវតា ១៤ កោដិសម្រេចធម្មាភិសម័យ ។ តថាគតមានឧបការៈច្រើនដល់សក្កទេវរាជនោះ ដោយប្រការយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ការបានជួបប្រទះឃើញព្រះអរិយៈទាំងឡាយ ជាការល្អប្រសើរ ។

## ស្នេហាគន្ធព្វ

(កំណាព្យពាក្យ ៧)

បញ្ចសិខៈគន្ធព្វបុត្ត ចូលគាល់ព្រះពុទ្ធពោលគាថា
រៀបរាប់ខ្លួនឯងមានស្នេហា ចំពោះធីតាស្តេចគន្ធព្វ ។
នៅគុហាភ្នំឥន្ទ្រសាល រស្មីភ្លឺច្រាលកណ្តាលយប់
បញ្ចសិខៈបុត្តគន្ធព្វ ស្រែកច្រៀងទាំងយប់ដៃដេញពិណ ។
គាថាកបដោយគុណទាំងបី ព្រះរតនត្រៃនិងព្រះឥន្ទ្រ
ចម្រៀងស្នេហាកាមភូមិន្ទ បន្ទរដោយពិណមានខ្សែបី ។

ម្នាលនាងសុរិយវច្ឆសា បងនមស្ការបិតាស្រី
ទ្រង់ជាគន្ធព្វាធិបតី បូពិាបុរិសុមេរ៉ុទ្រង់ ។
នាងជាធីតាកល្យាណី នាងមានសិរីប្រកបអង្គ
ព្រោះហេតុតែនាងល្អត្រចង់ ចិត្តបងដូចទង់ត្រូវខ្យល់បក់ ។
គន្ធព្វធីតាមានរស្មី ចិត្តបងបេតីស្រីវរលក្ខណ៍
ដូចព្រះអរហន្តសែនស្មោះស្ម័គ្រ នឹងលោកុត្តរៈដូច្នោះដែរ ។
សូមនាងជួយលត់ភ្លើងតណ្ហា សម្រេចប្រាថ្នាកុំគេចបែរ
ប្រៀបដូចអ្នកឈឺមានគេថែ ថ្នាំដែលពូកែអូនស្នេហ៍បង ។
កាមបងតិចទេតែព្រោះនាង មានរូបមានរាងល្អកន្លង
ទើបបានកិលេសមកទាំងកង បំណងនៃបនិត្យជិតកាយា ។
ដូចទក្ខិណាទានមានបាយ និងចីវរថ្វាយអរហន្តា
សទ្ធាចម្រើនស្តាប់ទេសនា នៃបនិត្យសោតានឹងព្រះធម៌ ។
បុណ្យបងធ្វើហើយពេលណា១ ដល់អរហន្តាគុណបវរ
សូមបុណ្យជួយបងបានស្រីល្អ ដូចអ្នកស្តាប់ធម៌បាននិព្វាន ។
បុណ្យបងធ្វើហើយក្នុងមណ្ឌល ប្រឹថពីថ្កើងថ្កល់បុណ្យជាស្ពាន
សូមបានជួបស្រីដូចព្រហ្មយាន ឆ្លងដល់និព្វានសុខបុរី ។

សូមបាននៃបនិត្យផ្ដិតឱរា បីដូចគជសារពេលក្ដៅដី
ចុះទឹកស្រះឈ្ងុកផ្កាវីកថ្មី កេសរពេញផ្ទៃបឹងបុប្ផា ។
ព្រះសក្យមុនីគង់ក្នុងឈាន ស្វែងរកនិព្វាននោះយ៉ាងណា
ម្នាលនាងសុរិយវច្ឆសា បងរកកនិដ្ឋាយ៉ាងនោះដែរ ។
នាងកើតមកហើយស្អាតអស្ចារ្យ ឱ្យបងប្រាថ្នាហឫទ័យស្នេហ៍
បីដូចវាំយោបក់ល្ហើយល្ហែ ឬដូចដួងខែចន្ទត្រជាក់ ។
ព្រះមុនីត្រាស់ដឹងធម៌បវរ ត្រេកអរក្នុងផ្លូវអរិយមគ្គ
បើបងបានអូនមករួមរក្ស រួមដើរផ្លូវមគ្គចិត្តបងត្រេក ។
ដូចធម្មតាទឹកត្រជាក់ថ្លា ជាទីប្រាថ្នានៃអ្នកស្រេក
ឬដូចរាត្រីចូលដំណេក នៃអ្នកហត់ពេកពេញមួយថ្ងៃ ។
ម្នាលនាងសុរិយវច្ឆសា បងមានតណ្ហាងប់នឹងស្រី
ស្នេហ៍បងចុះប្រេងដូចដំរី ហួសពីវិស័យនៃកង្វែរ ។
បងមានចិត្តស្លុងក្នុងស្រីហើយ ថយពុំរួចឡើយណាមាសមេ
ដកចិត្តមិនរួចពីស្រីទេ ដូចត្រីលេបផ្លែសន្ទូចហើយ ។
បើបានព្រះឥន្ទប្រទានពរ គឺពិតជាល្អដូចដល់ត្រើយ
បងសូមពរភ្លាមមិនកន្ដើយ ប្រាថ្នាអូនហើយសូមពរស្នោះ ។

គន្ធព្វគាថាមានអត្ថន័យ ធ្វើឱ្យចិត្តស្រីនឹកស្រណោះ
ឆ្លើយថាស្រឡាញ់ព្រមរួមរស់ រួមកាយរួមស្នោះលុះក្ស័យប្រាណ ។
ម្នាលទេពធីតាប្រាជ្ញាក្រាស់ បងត្រេកអរណាស់ណាកល្យាណ
សូមបិតាអូនបានថ្កើងថ្កាន ប្រៀបបានសាលព្រឹក្សទើបនឹងផ្កា ។
មុននឹងបញ្ចប់សូមចារចង ប្រវត្តិកន្លងទេពធីតា
នាមនាងសុរិយវច្ឆសា សម្រេចស្នេហាតាមធម្មា ។
នាងជាធីតាគន្ធព្វរាជ នៅក្រោមអំណាចព្រះឥន្ទ្រា
នាងតែងតែទៅរាំជុំគ្នា ឯរោងសភាតាវតិង្សា ។
ត្រៃត្រិង្សឋានខ្ពស់កំពូលភ្នំ ជុំដោយចាតុម្មហារាជិកា
ធីតាគន្ធព្វជាប់ស្នេហា ចំពោះបុត្រាព្រះមាតលី ។
នាងទៅរឿយៗ តាវតិង្សា ដើម្បីទស្សនារបាំថ្មី
ទាំងរាំជុំគ្នាបុត្តមាតលី ព្រះឥន្ទកោសិយត្រាស់ទេសនា ។
ពីគុណព្រះពុទ្ធអស្ចារ្យក្រៃ ជ្រៅដោយអត្ថន័យច្រើនប្រការ
នាងបានស្តាប់ហើយកើតជ្រះថ្លា បំណងប្រាថ្នាគាល់ព្រះពុទ្ធ ។
លុះនាងបានស្តាប់នូវគាថា ចម្រៀងតណ្ហាជម្រៅមុត
ប្រកបដោយគុណនៃព្រះពុទ្ធ ដែលគន្ធព្វបុត្តបានច្រៀងហើយ ។

នាងបានព្រមព្រៀងនឹងបិតា | រៀបចំស្នេហាមិនកន្តើយ
រកគូប្រាកដពិតឃើញហើយ | មាតលីបុត្តអើយលាហើយណា៎ ។
បញ្ចសិខៈគន្ធព្វបុត្ត | ត្រេកអរបំផុតបានវច្ឆសា
ពន្លឺកាយនាងដូចសុរិយា | គាល់ព្រះសាស្តាស្តាប់ព្រះធម៌ ។
កាលនោះព្រះឥន្ទស្តេចយាងមក | គាល់ព្រះមានជោគជាបន្ត
សាកសួរបញ្ហាផ្លូវព្រះធម៌ | ទេវតាកុះករបានអមតៈ ។
កំណាព្យចងចារសូមបញ្ចប់ | បុគ្គលមានភ័ព្វឃើញប្រចក្ស
រួចផុតចាកទុក្ខដល់អមតៈ | ផ្លូវអរិយមគ្គប្រសើរហោង ។

**សូមអនុមោទនាធម្មយាត្រាទៅកាន់ដែនពុទ្ធភូមិ !**

ភ្នំពេញថ្ងៃ ១៥ កើត ខែមាឃ ព.ស. ២៥៥៤

**ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត សាវង្ស**

# ព្រះពុទ្ធភាសិត អធិប្បាយខ្លីៗ

**១~ មនោបុព្វង្គមា ធម្មា** ធម៌ទាំងឡាយមានចិត្តជាប្រធាន។

**មនោ** ក្នុងព្រះគាថាប្រារព្ធប្រវត្តិរបស់ **ព្រះចក្ខុបាលត្ថេរ** បានដល់ ទោសមូលចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹងទោមនស្សវេទនា។

**បុព្វង្គមា** ដោយសេចក្តីថា ជាប្រធាន ជាមេនាំមុខ។

**ធម្មា** ធម៌ទាំងឡាយ គឺចេតសិកដែលប្រកបជាមួយនឹងទោសមូលចិត្តនោះឯង។

ចិត្តជាប្រធានក្នុងបាទនៃព្រះគាថានេះ ប្រៀបដូចជាមេចោរ។

ព្រះគាថាប្រារព្ធព្រះចក្ខុបាលត្ថេរធ្លាប់ធ្វើបាបពីមុនមក :

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។**

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត (មានចិត្តជាធំ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ[១] ពោលក្តី ធ្វើក្តី(រមែងជាទុច្ចរិត) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ ។

---

១. ធម៌ជាទោស ឬជាឧបក្កិលេសនៃចិត្តមានអភិជ្ឈា ជាដើម ដែលចូលមកធ្វើចិត្តឱ្យរីករវ ។

បិដកលេខ ៥២ ,ទំព័រ ២១ ,បន្ទាត់ ៧

**២. មនោបុព្វង្គមា ធម្មា** ធម៌ទាំងឡាយមានចិត្តជាប្រធាន។

**មនោ** ក្នុងព្រះគាថាប្រារព្ធ **មដ្ឋកុណ្ឌលី** បានដល់មហាកុសលចិត្តញាណសម្បយុត្ត ប្រព្រឹត្តទៅជាមួយនឹងសោមនស្សវេទនា។

ចិត្តនេះ ប្រៀបដូចជាមេដឹកនាំពុទ្ធបរិស័ទទាំងឡាយ ឱ្យថ្វាយទានដល់សង្ឃ ស្តាប់ព្រះធម៌ទេសនា បូជាប្រទីបជាដើម ទើបឈ្មោះថាប្រធាន។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ព្រះអង្គទ្រង់ប្រារព្ធមដ្ឋកុណ្ឌលី ។ មដ្ឋកុណ្ឌលី ជាកូនប្រុសម្នាក់របស់អទិន្នបុព្វកព្រាហ្មណ៍ ពេលឈឺជិតស្លាប់ បានញ៉ាំងសេចក្តីជ្រះថ្លាឱ្យកើតឡើងនៅក្នុងព្រះពុទ្ធគុណ ហើយបានធ្វើកាលកិរិយាទៅកាន់តាវត្តិង្សទេវលោក ។

មដ្ឋកុណ្ឌលីទេវបុត្រ បានចុះមកកាន់ស្ថានមនុស្ស ដើម្បីជួយបិតារបស់ខ្លួន ដែលបិតារបស់ខ្លួនជាមនុស្ស

កំណាញ់មិច្ឆាទិដ្ឋិ ទីបំផុតបានស្តាប់ព្រះធម៌ទេសនា និង ព្រះគាថា **មនោបុព្វង្គមា ធម្មា** ជាដើមហើយ ក៏បាន សម្រេចសោតាបត្តិផល ទាំងខ្លួនឯង ទាំងបិតា ព្រមទាំង ពពួកជនដ៏ច្រើន ។

ព្រះគាថាប្រារព្ធមដ្ឋកុណ្ឌលីជ្រះថ្លាក្នុងពុទ្ធគុណ :

**មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា**
**មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា**
**តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។**

ធម៌ទាំងឡាយមានចិត្តជាប្រធាន មានចិត្តប្រសើរ បំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី (រមែងជាសុចរិត) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោល តាមប្រាណ ។

បិដកលេខ ៥២ ,ទំព័រ ២៤ ,បន្ទាត់ ៦

**៣- កតបុញ្ញោ ឧភយត្ថ មោទតិ** បុគ្គលអ្នកធ្វើបុណ្យទុកហើយ រមែងរីករាយក្នុងលោកទាំងពីរ។

បទថា **កតបុញ្ញោ** ជាដើម ដោយសេចក្តីថា បុគ្គលអ្នកធ្វើកុសលមានប្រការផ្សេងៗ រមែងរីករាយ ដោយការរីករាយ ព្រោះអំពើក្នុងលោកនេះថា អំពើអាក្រក់ យើងមិនបានធ្វើឡើយ ចំណែកអំពើល្អ យើងបានធ្វើហើយ។ រមែងរីករាយក្នុងលោកខាងមុខ ព្រោះដែលឈ្មោះថាបុណ្យ ដោយអត្ថថា មានវិបាកជាសុខ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ទ្រង់ប្រារព្ធធម្មិកឧបាសក ។ ធម្មិកឧបាសក ជាអ្នកប្រព្រឹត្តធម៌ ទាំងបុត្រទាំងភរិយា ជាអ្នកមានសីល មានកល្យាណធម៌ ត្រេកអរក្នុងការចែកទានរស់នៅក្នុងក្រុងសាវត្ថី ។ នៅពេលមានជំងឺ គាត់មានបំណងស្តាប់ធម៌ ទើបឱ្យកូនទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគ និមន្តភិក្ខុសង្ឃសូត្រសតិប្បដ្ឋានសូត្រ ។ នៅពេលកំពុងស្តាប់ធម៌នោះ ទេវតានាំរាជរថពីទេវលោក

ទាំង ៦ ថានមកអញ្ជើញគាត់ទៅទេវលោក ។ ធម្មិក-ឧបាសក ចុតិហើយបដិសន្ធិក្នុងរាជរថស្ថានតុសិត មានទេពអប្សរមួយពាន់ហែហមទៅកាន់ស្ថានសួគ៌ ។ ព្រះ-បរមសាស្តា ទ្រង់ត្រាស់ព្រះគាថា :

**ឥធ មោទតិ បេច្ច មោទតិ កតបុញ្ញោ ឧភយត្ថ មោទតិ សោ មោទតិ សោ បមោទតិ ទិស្វា កម្មវិសុទ្ធិមត្តនោ ។**

បុគ្គលអ្នកធ្វើបុណ្យទុក រមែងរីករាយក្នុងលោកទាំងពីរ គឺ រីករាយក្នុងលោកនេះ ១ រីករាយក្នុងលោកខាងមុខ ១ បុគ្គលនោះ រមែងរីករាយស្រស់ស្រាយព្រោះឃើញអំពើបរិសុទ្ធរបស់ខ្លួន ។

បិដកលេខ ៥២ ,ទំព័រ ២៥ ,បន្ទាត់ ១៤

**៤~ អប្បមាទោ អមតំ បទំ** សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់។

សេចក្តីមិនប្រមាទ ជាឈ្មោះរបស់សតិដែលតាំងមាំជានិច្ច ដោយអត្ថ គឺការមិននៅប្រាសចាកសតិ ។ សេចក្តីមិនប្រមាទ ជាឫសគល់នៃកុសលធម៌ទាំងអស់ ជាទីប្រជុំចុះនៃកុសលធម៌ទាំងពួង ប្រៀបដូចជាស្នាមជើងដំរី ជាស្នាមជើងដ៏ធំ ជាទីប្រជុំចុះនៃស្នាមជើងសត្វទាំងពួង។ សេចក្តីមិនប្រមាទ ក៏ជាទីប្រជុំចុះនៃព្រះពុទ្ធ-វចនៈ ក្នុង ៤៥ ព្រះវស្សាផងដែរ។

**អមតំ បទំ** សេចក្តីមិនប្រមាទ ជាផ្លូវទៅដល់ព្រះនិព្វាន ជាទីបំផុតទុក្ខ ។

ព្រះគាថាប្រារព្ធព្រះនាងសាមាវតី :

**អប្បមាទោ អមតំ បទំ　　បមាទោ មច្ចុនោ បទំ**
**អប្បមត្តា ន មីយន្តិ　　យេ បមត្តា យថា មតា**
**ឯតំ វិសេសតោ ញត្វា　　អប្បមាទម្ហិ បណ្ឌិតា**
**អប្បមាទេ បមោទន្តិ　　អរិយានំ គោចរេ រតា**

**តេ ឈាយិនោ សាតតិកា  និច្ចំ ទឡ្ហបរក្កមា**
**ផុសន្តិ ធីរា និព្វានំ  យោគក្ខេមំ អនុត្តរំ ។**

សេចក្តីមិនប្រមាទជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ ជនទាំងឡាយ ដែលមិនប្រមាទហើយ ឈ្មោះថាមិនស្លាប់ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ។ ពួកបណ្ឌិតបានជ្រាបនូវដំណើរនេះ ដោយប្លែកគ្នា (ទើបឋិតនៅ) ក្នុងសេចក្តីមិនប្រមាទ រីករាយក្នុងសេចក្តីមិនប្រមាទ បណ្ឌិតទាំងនោះ ជាអ្នកត្រេកអរក្នុងធម៌ជាទីគោចរនៃព្រះអរិយបុគ្គលទាំងឡាយ ។ បណ្ឌិតអ្នកមិនប្រមាទទាំងនោះ មានការពិនិត្យជាប្រក្រតី មានព្យាយាមជាប់តគ្នា មានសេចក្តីប្រឹងប្រែងមាំមួនជានិច្ច ជាអ្នកមានប្រាជ្ញា តែងពាល់ត្រូវនូវព្រះនិព្វានជាទីក្សេមក្សាន្តចាកយោគៈ ជាធម្មគុណដ៏ប្រសើរបំផុត ។

បិដកលេខ ៥២ ,ទំព័រ ២៩ ,បន្ទាត់ ៣

**៥~ ចិត្តំ រក្ខេថ មេធាវី** អ្នកមានប្រាជ្ញា គប្បីរក្សាចិត្ត។

ជនអន្ធពាលមិនមានបញ្ញា គឺថា អាចរក្សាចិត្តរបស់ខ្លួនបាននោះ រមែងមិនមានឡើយ។ ជនអន្ធពាលតែងប្រព្រឹត្តទៅក្នុងអំណាចនៃអកុសលចិត្ត រមែងដល់នូវសេចក្តីវិនាស។

បុគ្គលអ្នកមានបញ្ញា គឺជាបណ្ឌិតពិតប្រាកដ រមែងរក្សាចិត្ត គ្រប់គ្រងចិត្តទុកបាន។ ព្រោះហេតុនោះ ក្នុងនាមជាពុទ្ធបរិស័ទ គប្បីបំពេញតួនាទីរបស់ខ្លួន គឺការគ្រប់គ្រងចិត្តខ្លួនឯង ព្រោះថា ចិត្តដែលគ្រប់គ្រងបានល្អហើយ ជាហេតុឱ្យសម្រេចនូវបរមសុខ ។

ព្រះបរមសាស្តា ទ្រង់គង់នៅនាមហាវិហារព្រះ-ជេតពន ទ្រង់ប្រារព្ធភិក្ខុមួយអង្គដែលចង់សឹក ។ ភិក្ខុអង្គនោះ ជាសេដ្ឋីបុត្រកាលពីមិនទាន់បួស បានជ្រះថ្លាបំពេញបុណ្យតាំងពីធ្វើទាន ដល់ត្រៃសរណគមន៍ សមាទានសីលរហូតចូលកាន់ផ្នួស ។ ក្នុងផ្នួសលោកមានព្រះវិន័យធរ

ជាព្រះឧបជ្ឈាយ៍ មានព្រះអាចារ្យជាភិក្ខុទ្រទ្រង់នូវព្រះ-អភិធម្ម ។ ចំណុចដែលធ្វើឱ្យលោកចង់សឹក ព្រោះលំបាកធ្វើតាមព្រះវិន័យ និង មិនយល់ក្នុងព្រះអភិធម្ម ។ កាលដែលលោកបានចូលគាល់ព្រះបរមសាស្តា ព្រះអង្គទ្រង់បានប្រទានឱវាទដូច្នេះថា អ្នកចូររក្សាចំពោះតែចិត្តរបស់ខ្លួន អ្នកនឹងអាចរួចផុតចាកទុក្ខបាន ។ រួចហើយព្រះអង្គទ្រង់ត្រាស់នូវព្រះគាថា ដែលធ្វើឱ្យលោកស្តាប់ហើយបានសម្រេចសោតាបត្តិផល អស់ខ្វល់ពីរឿងសឹក ។

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។**

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ ( ព្រោះថា ) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

បិដកលេខ ៥២ ,ទំព័រ ៣០ ,បន្ទាត់ ២

**៦. អចិរំ វតយំ កាយោ** ឱហ្ន៎ កាយនេះមិននៅយូរប៉ុន្មានឡើយ។

ព្រះបរមសាស្តា ទ្រង់ប្រារព្ធចំពោះភិក្ខុមានអាពាធមួយអង្គ។ ម្នាលភិក្ខុ មិនយូរឡើយ កាយនេះ នឹងដេកសង្កត់នៅលើផែនដី ព្រោះតែវិញ្ញាណប្រាសទៅ គេនាំយកទៅចោលដូចជាអង្កត់អុស រកប្រយោជន៍គ្មានឡើយ។

ពិតណាស់ គេចូលព្រៃកាប់យកឈើដែលមានប្រយោជន៍ យកមកធ្វើទព្វសម្ភារៈផ្សេងៗ ត្រង់កន្លែងណាដែលឥតបានការ គេកាត់វាចោលក្នុងព្រៃនោះឯងយ៉ាងណាមិញ កាយនេះ ប្រជុំដោយអាការ ៣២ ក៏យ៉ាងនោះដែរ ជាសាកសព ជារបស់ដែលគេត្រូវចោល។

ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅនាវិហារ-ជេតពន ព្រះអង្គត្រាស់សម្តែងនូវព្រះគាថានេះ ដែលធ្វើឱ្យព្រះភិក្ខុបូតិគត្តតិស្សត្ថេរ បានសម្រេចព្រះអរហត្តផលព្រមដោយបដិសម្ភិទា ។

ព្រះភិក្ខុអង្គនេះ លោកមានបាបកម្មពៀរវេរាក្នុង

រឿងបៀតបៀនសត្វ និង សម្លាប់សត្វ ទើបធ្វើឱ្យលោកមានអាពាធធ្ងន់ធ្ងរ ប៉ុន្តែដោយលោកធ្លាប់បានថ្វាយទានដល់ព្រះខីណាស្រព ទើបជាឧបនិស្ស័យឱ្យលោកបានសម្រេចព្រះអរហត្តបរិនិព្វាន ។

ព្រះគាថាប្រារព្ធព្រះបូតិគត្តតិស្សត្ថេរ កើតដំបៅពេញរាងកាយ :

**អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ**
**ឆុឌ្ឌោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។**

ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ តែមានវិញ្ញាណទៅប្រាសហើយ គេនឹងយកទៅបោះបង់ចោលមុខជានឹងដេកស្តូកស្តឹងនៅលើផែនដី ដូចជាអង្កត់អុសរកប្រយោជន៍គ្មានឡើយ ។

**៧_ អត្តានំ ទមយន្តិ បណ្ឌិតា** បណ្ឌិតទាំង-ឡាយ តែងទូន្មានខ្លួន។

មានព្រះពុទ្ធតម្រាស់ ត្រាស់ទុកដូច្នេះថា :

ពួកអ្នកបាចទឹក រមែងបាចទឹកទៅតាមការពេញចិត្តរបស់ខ្លួនបាន អ្នកពត់ព្រួញ ក៏រមែងធ្វើការពត់ព្រួញ គឺធ្វើឱ្យត្រង់ ចំណែកជាងឈើ ក៏រមែងកាប់កាត់ ចាំងឈូសនូវឈើ ដើម្បីប្រយោជន៍ដល់ទព្វសម្ភារៈមានកង់ជាដើម គឺរមែងធ្វើឈើឱ្យត្រង់ឬកោង តាមការពេញចិត្តរបស់ខ្លួន។

បណ្ឌិតទាំងឡាយ ធ្វើហេតុមានប្រមាណប៉ុណ្ណេះឱ្យជាអារម្មណ៍ហើយ បានញ៉ាំងអរិយមគ្គឱ្យកើតឡើង រមែងឈ្មោះថា ទូន្មានខ្លួន។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាព្រះវិហារ-ជេតពន ព្រះអង្គប្រារព្ធបណ្ឌិតសាមណេរ ។ បណ្ឌិត-សាមណេរលោកកើតក្នុងត្រកូលឧបដ្ឋាកព្រះសារីបុត្ត ជាអ្នកសម្បូណ៌បុណ្យបានបំពេញទុកមកពីជាតិមុន។ លោក

ប្រសូតមកបាន ៧ ឆ្នាំ ក៏សូមមាតាបួស មាតាមិនទម្លាយអធ្យាស្រ័យរបស់បុត្រ បានអនុញ្ញាតឱ្យបុត្របួសក្នុងសម្នាក់ព្រះសារីបុត្ត ។

នៅពេលនិមន្តទៅបិណ្ឌបាត បណ្ឌិតសាមណេរលោកចេះពិចារណាក្នុងរឿងអ្នកស្រែបាចទឹក រឿងជាងពត់ព្រួញ និង រឿងជាងឈើ មកជាការទូន្មានចិត្ត ទើបព្រះបរមសាស្ដាទ្រង់ត្រាស់នូវព្រះគាថាដូច្នេះ :

**ឧទកញ្ហិ នយន្តិ នេត្តិកា**

**ឧសុការា នមយន្តិ តេជនំ**

**ទារុំ នមយន្តិ តច្ឆកា**

**អត្តានំ ទមយន្តិ បណ្ឌិតា ។**

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញតែងពត់ព្រួញ ( ឱ្យត្រង់ ) អ្នកចាំងឈើ តែងចាំងឈើឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន (ដូច្នោះឯង ) ។

បិដកលេខ ៥២ ,ទំព័រ ៤៦ ,បន្ទាត់ ១០

**៨~ អភិត្ថរេថ កល្យាណេ** បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ។

បានជាប្រញាប់ធ្វើអំពើល្អ ព្រោះមកអំពីប្រញាប់ហាមឃាត់ចិត្តចាកបាប ដូចជាបុគ្គលត្រូវភ្លើងឆេះហើយប្រញាប់លត់ភ្លើងនោះ ដូច្នោះឯង។

ធម្មជាតិចិត្ត រមែងសម្បូណ៌ទៅដោយបាបមិត្តមានសេចក្ដីកំណាញ់ ការច្រណែន ការលុបគុណកាមច្ឆន្ទៈ និងព្យាបាទជាដើម ព្រោះហេតុដូច្នេះ កាលបើបុគ្គលធ្វើបុណ្យដោយកម្លាំងទន់ខ្សោយ ឬ យឺតយ៉ាវ ចិត្តរមែងត្រូវបាបមិត្តអូសទាញឱ្យលិចលង់ក្នុងអន្លង់បាបកម្ម។

ព្រះបរមសាស្ដា ទ្រង់គង់ប្រថាប់នៅនាព្រះវិហារ-ជេតពន ព្រះអង្គទ្រង់ប្រារព្ធចូឡេកសាដកព្រាហ្មណ៍ ។ ព្រាហ្មណ៍នេះបានស្ដាប់ព្រះធម៌ជ្រះថ្លាប្រាថ្នាបូជាព្រះធម៌ ប៉ុន្តែត្រូវសេចក្ដីកំណាញ់គ្របសង្កត់ចិត្តអស់ ២ យាមនៃរាត្រី លុះដល់ពេលជិតភ្លឺ ទើបគាត់អាចឈ្នះសេចក្ដីកំណាញ់បាន ដោយអំណាចនៃសទ្ធានាំមុខ ។

តាមពិត ពុទ្ធបរិស័ទយើងគ្រប់គ្នា សុទ្ធតែមានសទ្ធាជាកល្យាណមិត្រ សទ្ធាបានរំដោះចិត្តយើងឱ្យរួចពីសត្រូវគឺកិលេស ឱ្យចិត្តបានចូលមកជិតព្រះរតនត្រ័យ ហើយគ្រប់គ្រងថែរក្សាឱ្យតាំងនៅក្នុងកុសលធម៌ផ្សេងៗ រហូតដល់ឱ្យឆ្លងនូវអន្លង់ ៤ បានទៀតផង ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះគាថាប្រារព្ធចូឡេកសាដកព្រាហ្មណ៍ ដូច្នេះថា :

**អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ**
**ទន្ធំ ហិ ករតោ បុញ្ញំ បាបស្មឹ រមតី មនោ ។**

បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

៩~ **សុខោ បុញ្ញស្ស ឧច្ចយោ** ការសន្សំបុណ្យ តែងនាំមកនូវសេចក្តីសុខ។

បុណ្យជាមិត្តល្អ នាំសុខមកឱ្យ សុខទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ។ បានជាព្រះពុទ្ធ ព្រះពុទ្ធ-មាតា ព្រះពុទ្ធបិតា កន្សែស្រាវពេជ្ជ ឯតទគ្គបុគ្គល។ល។ ព្រោះបុណ្យនាំឱ្យបានសម្រេចទាំងអស់ គឺបុណ្យជាឧប-និស្ស័យនៃសេចក្តីសម្រេចនោះៗ ។

ព្រោះហេតុដូច្នេះ បុគ្គលត្រូវធ្វើបុណ្យឱ្យរឿយៗ កុំល្ហមក្នុងបុណ្យ ធ្វើទាំងការពេញចិត្ត ពេញកម្លាំង ព្រោះបុណ្យដែលបុគ្គលសន្សំហើយ តែងនាំមកនូវសេចក្តីសុខ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហា-វិហារព្រះជេតពន ទ្រង់ប្រារព្ធនាងលាជទេវធីតា ។ នាងលាជទេវធីតា កាលនៅពីមនុស្ស បានថ្វាយលាជដល់ព្រះមហាកស្សបត្ថេរ ដែលទើបតែចេញពីនិរោធសមា-បត្តិ ។ ព្រះថេរៈគង់នៅបិប្ផលិគុហានាភ្នំវេភារៈជិតក្រុងរាជគ្រឹះ បានប្រោសកូនស្រីអ្នកស្រែម្នាក់នេះ ឱ្យបានទៅ

កាន់ទេវលោកក្នុងថ្ងៃហ្នឹងឯង ព្រោះកូនស្រីនេះត្រូវពស់ខាំស្លាប់នៅពេលឱ្យទានហើយ ។

នាងទេពធីតា បានចុះមកបំពេញបុណ្យ ដោយការបម្រើព្រះមហាកស្សបត្ថេរ មានបោសសម្អាតត្រង់ទីបិប្ផលិគុហា និងដងទឹកសម្រាប់ឆាន់ជាដើម ប៉ុន្តែបានតែពីរបីថ្ងៃត្រូវព្រះថេរៈបណ្តេញ ទើបស្ទុះទៅឈរំនៅឰដ៏អាកាស ។ ព្រះពុទ្ធអង្គទ្រង់ផ្សាយព្រះរស្មី ដើម្បីឱ្យប្រាកដព្រះរូបដល់ទេពធីតា ហើយត្រាស់ព្រះគាថាឱ្យនាងបានសម្រេចសោតាបត្តិផល :

**បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ**
**តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ។**

បើបុរស[១] ធ្វើបុណ្យ គួរធ្វើបុណ្យនោះឱ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ ( ព្រោះថា ) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឱ្យ ។

---

១-ទាំងប្រុសទាំងស្រីគួរធ្វើបុណ្យឱ្យរឿយៗ ។

**១០~ ឃាធានិ បរិវជ្ជយេ** បុគ្គលគួរចៀសវាង នូវបាបទាំងឡាយ។

អ្នកជំនួញមានទ្រព្យច្រើន មានគ្នាតិច កាលដែលធ្វើដំណើរតាមផ្លូវ ដឹងថាខាងមុខមានពួកចោរ ត្រូវតែកុំទៅ ឬ ត្រូវចៀសវាងរកផ្លូវសុវត្ថិភាព យ៉ាងណាមិញ បុគ្គលត្រូវតែចៀសវាងនូវបាបទាំងពួង យ៉ាងនោះដែរ។

ម្យ៉ាងទៀត បុគ្គលគួរចៀសវាងនូវបាបទាំងឡាយ ឱ្យដូចជាអ្នកប្រាថ្នាការរស់នៅ ចៀសវាងការផឹកនូវថ្នាំពិស ដូច្នោះដែរ។

បុគ្គលខ្លាចពៀរវេរា គប្បីចៀសវាងនូវបាបកម្មទាំងឡាយ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅព្រះវិហារ-ជេតពន ព្រះអង្គប្រារព្ធនាយពាណិជមានទ្រព្យច្រើន ។

ដោយមានពួកភិក្ខុច្រើនអង្គ បាននិមន្តទៅតាមរទេះនាយពាណិជ ហើយត្រឡប់មកវត្តវិញក្រាបទូលនូវព្រឹត្តិការណ៍នោះ ថាពួកចោរចាំស្ទាក់ផ្លូវនាយពាណិជ ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាយពាណិជមានទ្រព្យច្រើន រមែងគេចអំពីផ្លូវដែលមានភ័យ ព្រោះដោយសារផ្លូវនោះមានពួកចោរ ម្យ៉ាងទៀត បុរសដែលប្រាថ្នាការរស់នៅ រមែងវៀរចាកនូវថ្នាំពិស ក្នុងសេចក្តីនេះ ភិក្ខុកាលដែលបានជ្រាបថា ភពបីដូចជាផ្លូវដែលមានពួកចោរ ក៏រមែងវៀរនូវអំពើអាក្រក់ ។ ដោយការបន្តនូវអនុសន្ធិ ទើបព្រះអង្គទ្រង់ត្រាស់នូវព្រះ-គាថា ដែលធ្វើឱ្យពួកភិក្ខុសម្រេចព្រះអរហត្ត :

**វាណិជោវ ភយំ មគ្គំ អប្បសត្ថោ មហទ្ធនោ**
**វិសំ ជីវិតុកាមោវ បាបានិ បរិវជ្ជយេ ។**

បុគ្គលគួរចៀសវាងបាបទាំងឡាយ ឱ្យដូចពាណិជដែលមានទ្រព្យច្រើន តែមានគ្នាតិច ចៀសវាងផ្លូវដែលគួរឱ្យខ្លាច ឬដូចជាបុរសដែលប្រាថ្នានឹងរស់នៅចៀស-វាងថ្នាំពិស ដូច្នោះដែរ ។

**១១-  អត្តានំ  ឧបមំ  កត្វា** បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញាការវាយដំ ព្យាបាទ បៀតបៀន និងខ្លាចចំពោះសេចក្តីស្លាប់ដ៏យ៉ាងក្រៃលែង បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា មិនគប្បីប្រហារ មិនគប្បីបៀតបៀនសត្វទាំងឡាយឡើយ។

ជីវិតជាទីស្រឡាញ់ ជាទីហួងហែងដ៏ក្រៃលែងនៃសត្វទាំងឡាយ គ្រប់ជីវិតប្រាថ្នាសុខ ប្រាថ្នាការរស់នៅជាមួយនឹងបុគ្គលជាទីស្រឡាញ់ ជាមួយនឹងទ្រព្យសម្បត្តិ និង សេចក្តីប្រសើរគ្រប់យ៉ាង។ បុគ្គលគួរមានខ្លួនឯងជាគ្រឿងប្រៀបធៀប គួរអប់រំមេត្តាចិត្ត។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ទ្រង់ប្រារព្ធពួកភិក្ខុឆព្វគ្គិយ ។ ពួកភិក្ខុមានគ្នា ៦ អង្គនេះ បានទះតប់ដោយដៃទៅលើពួកភិក្ខុដទៃ ។ បន្ទាប់ពីព្រះដ៏មានព្រះភាគបញ្ញត្តសិក្ខាបទហើយ ព្រះអង្គទ្រង់ត្រាស់ប្រទានឱវាទថា ម្នាលភិក្ខុទាំងឡាយ

ជាធម្មតាភិក្ខុរមែងដឹងថា  សត្វដទៃរមែងតក់ស្លុតចំពោះ
អាជ្ញា ដូចជាអាត្មាអញដែរ ទើបព្រះអង្គទ្រង់ត្រាស់ ២
ព្រះគាថាដូច្នេះថា :

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភាយន្តិ មច្ចុនោ**
**អត្តានំ ឧបមំ កត្វា  ន ហនេយ្យ ន ឃាតយេ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំងឡាយ  តែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗរូប បុគ្គលគួរធ្វើខ្លួន ឱ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ ។

**សព្វេ តសន្តិ ទណ្ឌស្ស  សព្វេសំ ជីវិតំ បិយំ**
**អត្តានំ ឧបមំ កត្វា  ន ហនេយ្យ ន ឃាតយេ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា) ជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ ។

បិដកលេខ ៥២ ,ទំព័រ ៥០ ,បន្ទាត់ ៥

**១២‑ ឧុក្ខា ហិ សារម្ភកថា** ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឱ្យកើតទុក្ខ។

ព្រះបរមសាស្តា ព្រះអង្គប្រថាប់នៅជេតវនារាម ទ្រង់ត្រាស់ប្រារព្ធចំពោះព្រះកោណ្ឌធានត្ថេរ។ រឿងហេតុដោយសារព្រះកោណ្ឌធានត្ថេរ មានបុព្វកម្ម ធ្វើឱ្យគេមើលឃើញលោក មានស្ត្រីម្នាក់ដើរជាប់ពីក្រោយ និងនៅជាមួយនឹងលោកជានិច្ច ម្ល៉ោះហើយ ភិក្ខុដទៃក៏ចោទលោកថាទ្រុស្តសីល។

ព្រះថេរៈកាលដែលលោកនៅជាទេវតា បានបំបែកភិក្ខុអ្នកមានសីលពីរអង្គឱ្យបែកគ្នា។ ក្នុងការបំបែកនោះ ទេវតាបាននិម្មិតស្រីម្នាក់ធ្វើហាក់ដូចជាភិក្ខុមួយអង្គនោះបានទម្លាយសីលជាមួយនឹងនាង ។ ទេវតាត្រូវធ្លាក់អវីចីនរករហូតមួយចន្លោះព្រះពុទ្ធ ក្នុងពុទ្ធុប្បាទកាលនេះកើតក្នុងក្រុងសាវត្ថី ក្នុងថ្ងៃដែលបួសនោះឯង ចាប់ផ្តើមមានរូបស្រីម្នាក់នៅជាមួយនឹងលោក ។ កាលដែលភិក្ខុដទៃពោលទោស លោកក៏ពោលប្រទូស្តតបដោយការខឹង

ក្រោធ ។ ព្រះបរមសាស្ដា ទ្រង់ត្រាស់ព្រះគាថាទូន្មាន :

**មាវោច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុ តំ**
**ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ តំ។**
**សចេ នេរេសិ អត្តានំ កំសោ ឧបហតោ យថា**
**ឯស បត្តោសិ និព្វានំ សារម្ភោ តេ ន វិជ្ជតិ។**

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្ដីថាឱ្យហើយ គេគប្បីស្ដីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែងជាហេតុនាំឱ្យកើតទុក្ខ អាជ្ញាតបត្រូវបានធ្លាក់ចុះមកប៉ះពាល់ដល់អ្នកវិញ ។

បើអ្នកធ្វើខ្លួនមិនឱ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញហើយ (រមែងមិនលាន់ឮសូរ ) ដូច្នោះ អ្នកនុ៎ះជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នកឡើយ ។

បិដកលេខ ៥២ ,ទំព័រ ៥៣ ,បន្ទាត់ ៥

**១៣~ មរណន្តំ ហិ ជីវិតំ** ជីវិតមានសេចក្តីស្លាប់ជាទីបំផុត។

ព្រះសុគតសាស្តា ព្រះអង្គប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះឧត្តរាថេរី ដែលមានព្រះជន្ម ១២០ ឆ្នាំ ។ ព្រះអង្គត្រាស់ថា រូបនេះគ្រាំគ្រាអស់ហើយ ជាសំបុកនៃរោគ ជារបស់ពុកផុយ រូបកាយដែលជារបស់ស្អុយនេះតែងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមានសេចក្តីស្លាប់ជាទីបំផុត។ ចប់ព្រះធម៌ទេសនា ព្រះថេរីបានសម្រេចសោតាបត្តិផល។

យើងមិនអាចទាមទារអ្វីបានស្រេចតែចិត្តយើងនោះឡើយ បើទាមទារបាននោះ មិនមានអ្នកណាស្លាប់ទេ ប្រាកដជារស់នៅហើយមានអ្វីៗគ្រប់យ៉ាង ដូច្នេះបានជាមិនទាន់ស្លាប់ត្រូវប្រញាប់រៀនស្លាប់ឱ្យហើយ ពោលគឺរៀនលះបង់របស់ដែលជាប់ជំពាក់។

ជីវិតជាប្រក្រតី គឺជាអារម្មណ៍នៃព្រះកម្មដ្ឋាន ទោះជារូបកម្មដ្ឋានក្តី អរូបកម្មដ្ឋានក្តី ក៏ត្រូវអាស្រ័យជីវិត

ប្រចាំថ្ងៃហ្នឹងឯង ជាទីតាំង ។ កាលដែលជីវិតជាប្រក្រតី ប្រចាំថ្ងៃប្រាកដជាតួ **ឆម្ម** ក៏រមែងរលត់នូវការខ្វល់ចំពោះខ្លួនឯង អត់មានរវល់សាង **ឆម្ម** ដទៃឱ្យបានជាអ្វីទាំងអស់ ព្រោះបដិបទានេះ មិនប្រព្រឹត្តទៅដើម្បីឱ្យបាននូវតួ **ឆម្ម** ណានោះឡើយ ស្រេចហើយតែតួ **ឆម្ម** ដែលកំពុងប្រាកដ មិនមែនជាយើង នេះជាបដិបទាវិសុទ្ធិ ។

ព្រះគាថាប្រារព្ធព្រះនាងឧត្តរាថេរី :

**បរិជិណ្ណមិទំ រូបំ　　　　　រោគនិឌ្ឌំ បភង្គុណំ**
**ភិជ្ជតិ បូតិ សន្ទេហោ　　　មរណន្តំ ហិ ជីវិតំ ។**

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសម្នាក់នៃរោគ ជារបស់ពុកផុយ កាយរបស់ខ្លួនជារបស់ស្អុយនឹងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមានសេចក្ដីស្លាប់ជាទីបំផុត ។

បិដកលេខ ៥២ ,ទំព័រ ៥៣ ,បន្ទាត់ ១២

**១៤. សតញ្ច ធម្មោ ន ជរំ ឧបេតិ** ធម៌របស់សប្បុរស មិនចូលដល់ការចាស់គ្រាំគ្រាឡើយ។

បទថា **សតញ្ច** ដោយសេចក្តីថា លោកុត្តរធម៌ ៩ របស់សប្បុរសទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម រមែងមិនមានការប៉ះទង្គិចបែកបាក់ រង្គោះរង្គើអ្វីឡើយ ឈ្មោះថា មិនចូលដល់ការចាស់គ្រាំគ្រា។

ព្រះភគវា ទ្រង់គង់ប្រថាប់នៅព្រះជេតពនមហាវិហារ ព្រះអង្គត្រាស់ប្រារព្ធសរីរៈព្រះរាជា ដែលព្រះរាជាត្រាស់ថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន គឺចាប់តាំងអំពីព្រះនាងមល្លិកាចែកឋានទៅបរលោក សរីរៈខ្ញុំព្រះអង្គមិនរហ័សរហួនសោះ។ព្រះមានព្រះភាគត្រាស់ថា រាជរថដ៏វិចិត្រពិតគ្រាំគ្រា សរីរៈដូចគ្នាគ្រាំគ្រាដែរ រីឯធម៌របស់សប្បុរស មិនចូលដល់ការចាស់គ្រាំគ្រាឡើយ។

នៅពេលដែលមនុស្សយើងចាស់ជរាគ្រាំគ្រាទ្រុឌទ្រោម គួរតែអប់រំចិត្តឱ្យណាស់ ទោះជាមានការលំបាកក្នុងរូបរាងកាយយ៉ាងណា ក៏មិនទោមនស្ស ទាស់ទែង

ខឹងក្រោធក្នុងរឿងអ្វីៗឡើយ ព្រោះរីករាយជាមួយនឹងការ ដល់ព្រះត្រៃសរណគមន៍ មានសទ្ធា មានសីលជាដើម។

ព្រះគាថាប្រារព្ធព្រះនាងមល្លិកាទេវីអស់ព្រះជន្ម ឯព្រះរាជាទ្រង់ជរា :

**ជីរន្តិ វេ រាជរថា សុចិត្តា**

**អថោ សរីរម្បិ ជរំ ឧបេតិ**

**សតញ្ច ធម្មោ ន ជរំ ឧបេតិ**

**សន្តោ ហវេ សព្ភិ បវេទយន្តិ ។**

រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា រីឯធម៌របស់សប្បុរស មិនចូលដល់ការចាស់ជរាឡើយ សប្បុរសទាំងឡាយតែង ប្រឹក្សាជាមួយនឹងពួកសប្បុរសផងគ្នា ។

បិដកលេខ ៥២ ,ទំព័រ ៥៤ ,បន្ទាត់ ៥

**១៥~ ទុក្ខា ជាតិ បុនប្បុនំ** ទុក្ខទាំងឡាយរឿយៗឥតស្រាកស្រាន្ត ព្រោះមកអំពីមានជាតិជាបច្ច័យ។

ព្រះបរមសាស្តា ក្នុងវេលាទើបតែបានសម្រេចនូវព្រះសម្មាសម្ពោធិញ្ញាណ ទ្រង់គង់ប្រថាប់នៅនាគល់ព្រះពោធិព្រឹក្ស ទ្រង់ព្រះឧទានប្រារព្ធដល់វដ្តសង្សាររបស់ព្រះអង្គ ។

**ទុក្ខា ជាតិ បុនប្បុនំ** នេះ គឺជាពាក្យបញ្ជាក់អំពីហេតុដែលមិនទាន់រកជាងផ្ទះឃើញ ។ ជាងផ្ទះ គឺតណ្ហាដែលធ្វើផ្ទះគឺអត្តភាពឱ្យដល់ព្រះអង្គ ។ ពាក្យថា មិនទាន់រកជាងផ្ទះឃើញ គឺមិនទាន់បានសម្រេចនូវព្រះសម្មាសម្ពោធិញ្ញាណហ្នឹងឯង ។ ឥឡូវព្រះអង្គបានជួបហើយជាងឯងមិនអាចធ្វើផ្ទះឱ្យដល់ព្រះតថាគតទៀតបានឡើយព្រោះព្រះអង្គបានដល់នូវព្រះនិព្វានរលត់តណ្ហាហើយ។

ព្រះគាថាព្រះពុទ្ធឧទានដំបូងបង្អស់ :

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។**

គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

កាលតថាគតកំពុងតែស្វះស្វែងរកជាងធ្វើផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះគឺអត្តភាព មិនទាន់បានជួបប្រទះនៅឡើយ (តថាគត) ក៏អន្ទោលទៅកាន់សង្សារវដ្ដ មានជាតិដ៏ច្រើន សេចក្ដីកើតជាទុក្ខរឿយៗ ។

នែជាងផ្ទះ! អ្នកធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀតមិនបានឡើយ បង្កង់ គឺ កិលេសរបស់អ្នកទាំងអស់តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះគឺអវិជ្ជា តថាគតកម្ទាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលប្រាសចាកសង្ខារហើយ តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

បិដកលេខ ៥២ ,ទំព័រ ៥៥ ,បន្ទាត់ ៩

**១៦‑ អត្តា ហិ អត្តនោ នាថោ** ខ្លួនជាទីពឹងនៃខ្លួនឯង។

ព្រះអង្គទ្រង់គង់ប្រថាប់នៅវត្តជេតពន ត្រាស់សម្តែងនូវព្រះធម៌ទេសនា ប្រារព្ធភិក្ខុនីជាព្រះមាតានៃព្រះកុមារកស្សបៈ។ ហេតុតែខ្លួនឯងជាម្តាយហើយនៅជាបុថុជ្ជននឹកអើយសែននឹក គឺនឹកកូនប្រុសដែលព្រាត់ប្រាសទៅអស់ ១២ ឆ្នាំ មានមុខទទឹកជោកដោយទឹកភ្នែក និមន្តទៅបិណ្ឌបាត។ ស្រាប់តែបានជួបកូនតាមផ្លូវ ស្រែកហៅកូនហើយស្ទុះទៅ ខ្លួនឯងក៏ត្រូវដួលផ្កាប់មុខ ខំប្រឹងត្រដរក្រោកទៅចាប់កូនទាំងអរ ទាំងអួលអាក់។

ពុទ្ធោអើយ ! សង្ឃឹមថាបានទទួលពាក្យផ្អែមល្ហែមតបត តែបែរជាកូនពោលថា អ្នកស្ទុះមករកអ្វី បួសហើយដូចម្តេចមិនកាត់ការស្រឡាញ់ចោល។ ព្រោះការខកចិត្តក៏បានកាត់នូវសេចក្តីស្នេហាក្នុងបុត្រ សម្រេចព្រះអរហត្តក្នុងថ្ងៃនោះឯង ព្រះបរមសាស្តាទ្រង់ត្រាស់ប្រារព្ធរឿងនេះឯង ទ្រង់ត្រាស់ថា **អត្តា ហិ អត្តនោ នាថោ** ...។

ព្រះគាថាប្រារព្ធមាតារបស់ព្រះកុមារកស្សបត្ថេរ មានខ្លួនឯងជាទីពឹង :

**អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា**
**អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។**

ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

បណ្តាបទទាំងនោះ បទថា **នាថោ** គឺជាទីពឹងពំនាក់ ព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះទុកថា បុគ្គលតាំងនៅក្នុងខ្លួន គឺសម្បូណ៌ហើយដោយខ្លួន ដែលខ្លួនអាចនឹងធ្វើកុសលហើយបានឋានសួគ៌ ឬដើម្បីញ៉ាំងមគ្គឱ្យចម្រើន ជាក់ច្បាស់នូវអរិយផល (អត្តសម្បទា) ព្រោះហេតុនោះឯង ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន ។

ក្នុងបទថា **នាថំ លភតិ ទុល្លភំ** នេះ ព្រះដ៏-មានព្រះភាគត្រាស់សំដៅយកព្រះអរហត្ត ។

**១៧~ សុទ្ធិ អសុទ្ធិ បច្ចត្តំ** បរិសុទ្ធិ និង មិនមែនបរិសុទ្ធិ ជារបស់ចំពោះខ្លួន។

ព្រះអង្គទ្រង់គង់ប្រថាប់នៅវត្តជេតពន ព្រះអង្គទ្រង់ប្រារព្ធឧបាសកឈ្មោះចុល្លកាល។ ឧបាសកស្តាប់ព្រះ-ធម៌ពេញមួយយប់ ចេញពីវត្តទៅកាន់ក្រុងសាវត្ថីជាន់ដានចោរ អ្នកស្រុកនាំគ្នាចាប់ដោយចោទថាជាចោរ ប៉ុន្តែបាននាងកុម្ភទាសីជួយនិយាយហេតុផល ពួកអ្នកស្រុកក៏ដោះលែងឧបាសកវិញទៅ។

ភិក្ខុទាំងឡាយជ្រាបដំណឹង បានក្រាបទូលព្រះ-មានព្រះភាគថា ចុល្លកាលឧបាសកបានជីវិតដោយសារនាងកុម្ភទាសី។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បាបដែលបុគ្គលធ្វើហើយដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង បាបដែលបុគ្គលមិនបានធ្វើហើយដោយខ្លួនឯង រមែងបរិសុទ្ធដោយខ្លួនឯង ចុល្លកាលឧបាសកបានជីវិតព្រោះនាងកុម្ភទាសី និង ព្រោះខ្លួនឯងមិនបានធ្វើបាបកម្មនោះទុកមក។

ព្រះគាថាប្រារព្ធចុល្លកាលឧបាសក រួចខ្លួនពីការចោទប្រកាន់ថាជាចោរ :

**អត្តនា ហ កតំ បាបំ អត្តនា សង្កិលិស្សតិ**

**អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ**

**សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ។**

អ្នកធ្វើបាបដោយខ្លួនឯង រមែងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបដោយខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្ដីបរិសុទ្ធ និង មិនបរិសុទ្ធជារបស់ចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ ឱ្យបរិសុទ្ធ ពុំបានឡើយ ។

បរិសុទ្ធិ គឺកុសលកម្ម និង មិនមែនបរិសុទ្ធិ គឺអកុសលកម្ម ជារបស់ចំពោះខ្លួន រមែងផលិតនូវផលចំពោះក្នុងខ្លួននៃបុគ្គលអ្នកធ្វើកម្មទាំងឡាយ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ចុល្លកាលឧបាសក បានតាំងនៅហើយក្នុងសោតាបត្តិផល ។

បិដកលេខ ៥២ ,ទំព័រ ៥៧ ,បន្ទាត់ ៦

**១៨~ ហីនំ ធម្មំ ន សេវេយ្យ** បុគ្គលមិនគួរសេពធម៌ថោកទាប។

ព្រះបរមសាស្តា ព្រះអង្គគង់ប្រថាប់នៅព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុកំលោះមួយអង្គ។ ភិក្ខុអង្គនោះ ឈ្មោះជាមួយនឹងចៅលោកយាយវិសាខា ដើមរឿងមកអំពីលោកសើចនឹងចៅលោកយាយ ។ ចំណុចត្រង់ដែលលោកសើចឡេះឡោះដោយខ្វះការសង្រួមនេះឯង ឈ្មោះថា សេពធម៌ថោកទាប ហើយនេះជាលក្ខណៈនៃសេចក្តីប្រមាទ។

បទថា **ហីនំ ធម្មំ** ក្នុងទីនេះ ជាឈ្មោះនៃកាមគុណ ៥ ព្រោះកាមគុណ ៥ ជារបស់ថោក សូម្បីសត្វតិរច្ឆានក៏សេពបាន ទាំងជាធម៌នាំសត្វទៅកើតក្នុងទីទាបមាននរកជាដើមទៀតផង ។

ភិក្ខុនោះ មិនព្រមតាមការសម្រុះសម្រួលរបស់អ្នកណាៗឡើយ សូម្បីតែព្រះឧបជ្ឈាយ៍របស់លោក លុះព្រះបរមសាស្តា ស្តេចយាងទៅដល់ហើយ ទើបព្រម

ស្តាប់ព្រះអង្គ ដោយអាងថា ព្រះអង្គទ្រង់ជ្រាបការពិត ។

អង្គព្រះសាស្តា ទ្រង់ទូន្មាននូវភិក្ខុកំលោះនោះ ដោយព្រះគាថាដូច្នេះថា :

**ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**
**មិច្ឆាទិដ្ឋិំ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ។**

បុគ្គលមិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោកឡើយ ។ ភិក្ខុស្តាប់ ហើយតាំងនៅក្នុងសោតាបត្តិផល។

មនុស្សយើង គួរសេពគប់ជាមួយសទ្ធា សតិ ហិរិ និង ឱត្តប្បៈជាដើម ព្រោះគុណធម៌ទាំងអស់នេះនាំឱ្យយើងបានខ្ពង់ខ្ពស់ នាំឱ្យយើងបានបញ្ញា រួចអំពីធម៌ថោកគ្រប់យ៉ាង រុងរឿងដូចព្រះចន្ទរួចផុតពីពពកខ្មៅ ។

បិដកលេខ ៥២ ,ទំព័រ ៥៧ ,បន្ទាត់ ៩

**១៩. ធម្មចារី សុខំ សេតិ** បុគ្គលមានប្រក្រតីប្រព្រឹត្តធម៌ រមែងដេកជាសុខ។

ព្រះលោកនាថ កាលទ្រង់គង់ប្រថាប់នៅនិគ្រោធារាម ព្រះអង្គទ្រង់ប្រារព្ធព្រះបិតា គឺព្រះបាទសិរីសុទ្ធោទនមហារាជ។ ទ្រង់ព្រះពុទ្ធដំណើរ យាងទៅក្រុងកបិលពស្តុលើកទីមួយ ព្រះអង្គពិចារណាព្រះពុទ្ធអំពីអតីត ទ្រង់ស្តេចយាងបិណ្ឌបាតតាមលំដាប់ ព្រមដោយព្រះអរហន្ត ២ ម៉ឺនអង្គ។ ព្រះពុទ្ធបិតាត្រាស់ថា បិតាខ្មាសគេណាស់ត្រង់ដែលព្រះអង្គត្រាច់ទៅដើម្បីភិក្ខាដូច្នេះ។ ព្រះបរមសាស្តាត្រាស់ថា មហាបពិត្រ នេះជាវង្សរបស់ព្រះពុទ្ធពីអតីតមក រួចហើយព្រះអង្គត្រាស់សម្តែងព្រះធម៌ទេសនាញុំាងព្រះពុទ្ធបិតា ឱ្យសម្រេចមគ្គផលនៅនឹងផ្លូវក្នុងក្រុងនោះឯង ។

**ធម្មចារី** គឺបុគ្គលមានប្រក្រតីប្រព្រឹត្តធម៌ បានដល់ការត្រាច់ទៅដើម្បីភិក្ខានោះឯងឱ្យជាសុចរិត ប្រព្រឹត្តឱ្យជាប្រក្រតី **សុខំ សេតិ** រមែងជាសុខគ្រប់ឥរិយាបថទាំង

៤ ទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

ព្រះគាថាប្រោសព្រះពុទ្ធបិតាជាដំបូង :

**ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ធម្មំ សុចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច។**

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឱ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ទាំងក្នុងលោកនេះផង ទាំងក្នុងលោកខាងមុខផង ។

**ធម្មំ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច។**

បុគ្គលគួរប្រព្រឹត្តធម៌ឱ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឱ្យទុច្ចរិតឡើយ បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ទាំងក្នុងលោកនេះផង ទាំងក្នុងលោកខាងមុខផង ។

បិដកលេខ ៥២ ,ទំព័រ ៥៨ ,បន្ទាត់ ៤

**២០៑ ឯថ បស្សថិមំ លោកំ** អ្នកទាំងឡាយចូរមកមើលនូវលោកនេះ។

ព្រះសុគតសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារវេឡុវន័ ព្រះអង្គទ្រង់ប្រារព្ធអភយរាជកុមារ។

អភយរាជកុមារបានទទួលរង្វាន់សោយរាជ្យ៧ ថ្ងៃព្រមទាំងស្រីរបាំដ៏ស្អាតម្នាក់ជាភរិយា។ ថ្ងៃទី ៨ ស្រីរបាំកើតខ្យល់ចាប់ស្លាប់ចោលទៅ អភយរាជកុមារ មានសេចក្តីសោកសៅ ត្រូវចូលទៅរកព្រះបរមសាស្តា សូមឱ្យព្រះអង្គជួយរំងាប់នូវសេចក្តីសោករបស់ខ្លួន។

ព្រះមានព្រះភាគ ទ្រង់ប្រារព្ធទឹកភ្នែកក្នុងសង្សារវដ្ត ដែលមិនអាចប្រមាណបាន ទ្រង់ត្រាស់ឱ្យមើលនូវលោកនេះដ៏វិចិត្រដូចរាជរថ ដែលបុគ្គលពាលទាំងឡាយត្រូវលិចលង់ ចំណែកអ្នកចេះដឹងមិនជាប់ជំពាក់ឡើយ ។ ចប់ព្រះធម៌ទេសនា អភយរាជកុមារតាំងនៅក្នុងសោតាបត្តិផល ព្រះធម៌ទេសនាមានប្រយោជន៍ដល់អ្នកស្តាប់ក្រៃលែង ព្រោះសម្តែងពីការពិតនៃជីវិត ។

**ឥមំ លោកំ** លោកនេះ គឺខន្ធលោក ព្រះអង្គត្រាស់ហៅឱ្យមកមើលដោយបញ្ញា ឱ្យឃើញលោកតាមពិត លោកដែលកើតហើយ រមែងបែកធ្លាយ។

ព្រះគាថាប្រារព្ធអភយរាជកុមារ :

**ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ**
**យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ។**

អ្នកទាំងឡាយ ចូរមកមើលនូវលោកនេះ ដ៏ត្រកាល ដូចរាជរថ ជនពាលទាំងឡាយ រមែងលិចលង់ក្នុងលោកណា ការជាប់ជំពាក់ក្នុងលោកនោះ រមែងមិនមានដល់បណ្ឌិតទាំងឡាយ ដែលដឹងច្បាស់ឡើយ ។

ក្រោយមកអភយរាជកុមារ សង្វេគចំពោះទុក្ខទោសក្នុងវដ្តសង្សារ តក់ស្លុតចំពោះកិលេសក្នុងសន្តានទើបបានចេញទៅបួសសម្រេចជាព្រះអរហន្ត ។

**២១_ អន្ធភូតោ អយំ លោកោ** លោកិយ-មហាជននេះ ងងឹតណាស់ ដូចជាមនុស្សខ្វាក់។

អង្គសម្តេចព្រះសាស្តា ទ្រង់ប្រថាប់នៅនាអគ្គា-ឡវចេតិយ ព្រះអង្គទ្រង់ប្រារព្ធធីតានៃជាងតម្បាញម្នាក់។

ធីតានៃជាងតម្បាញម្នាក់នេះ ចម្រើនមរណស្សតិអស់ ៣ ឆ្នាំ តាមបណ្តាំព្រះបរមសាស្តា ក្រោយមកបានឆ្លើយក្នុងមរណបញ្ហា ព្រមទាំងបានស្តាប់ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគ ក៏តាំងនៅក្នុងសោតាបត្តិផល ។ នាងស្លាប់ក្នុងថ្ងៃនោះឯង ដោយអចេតនារបស់បិតា នាងបានទៅកើតក្នុងតុសិតទេវលោក ។ ចំណែកបិតាសែនសោយសោកទៅរកព្រះសាស្តា ស្តាប់ព្រះធម៌ទេសនាចូលកាន់ផ្នួសសម្រេចព្រះអរហត្ត។

**អយំ លោកោ** លោកិយមហាជននេះ **អន្ធភូតោ** ងងឹតណាស់ដូចជាមនុស្សខ្វាក់ ព្រោះមិនមានបញ្ញាចក្ខុ តិចនាក់ណាស់ដែលឃើញត្រៃលក្ខណ៍ តិចនាក់ណាស់ដែលទៅកាន់ស្ថានសួគ៌ ដូចបក្សីជាប់សំណាញ់ព្រាន

ហើយ តិចណាស់ដែលអាចរួចពីសំណាញ់បាន ។

ព្រះគាថាដែលធីតារបស់ជាងតម្បាញស្តាប់ហើយ បានសម្រេចសោតាបត្តិផល :

**អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ សកុន្តោ[១] ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ។**

លោកិយមហាជននេះ ងងឹតណាស់ ដូចជាមនុស្សខ្វាក់ ក្នុងលោកនេះ មានមនុស្សតិចនាក់ណាស់ ដែលបានដឹងច្បាស់នូវបញ្ញកូន្ធតាមពិត តិចនាក់ណាស់ ដែលទៅកាន់ស្ថានសួគ៌ ដូចបក្សីដែលជាប់សំណាញ់របស់ព្រានហើយ តិចណាស់ ដែលអាចរួចពីសំណាញ់បាន ។

---

១. អដ្ឋកថាថា **សកុណោ** ។

បិដកលេខ ៥២ ,ទំព័រ ៥៩ ,បន្ទាត់ ៦

**២២. ន វេ កទរិយា ទេវលោកំ វជន្តិ**

បុគ្គល កំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកឡើយ។

ព្រះពុទ្ធអង្គទ្រង់គង់នៅវត្តជេតពន ទ្រង់ប្រារព្ធ **អសទិសទាន** គឺទានមិនមានអ្នកណាធ្វើដូច ជាទានមានដល់ព្រះពុទ្ធគ្រប់ៗព្រះអង្គ មួយអង្គមានតែម្តងប៉ុណ្ណោះ ព្រោះត្រូវបរិច្ចាគទ្រព្យ ១៤ កោដិត្រឹមតែមួយថ្ងៃនោះឯង ហើយទាននោះ ចំពោះតែស្ត្រីប៉ុណ្ណោះ ដែលជាអ្នកចាត់-ចែង ដើម្បីព្រះសាស្តា និង ព្រះភិក្ខុសង្ឃ ។

ក្នុងកាលនោះ អមាត្យរបស់ព្រះរាជាពីរនាក់ ម្នាក់ឈ្មោះ កាឡៈ ម្នាក់ទៀតឈ្មោះ ជុណ្ហៈ ។ កាឡៈមិនត្រេកអរនឹងទានរបស់ព្រះរាជា ដែលមានព្រះនាងមល្លិកាជាអ្នកចាត់ចែងនោះឡើយ ចំណែកអមាត្យជុណ្ហៈអនុ-មោទនាដ៏ក្រៃលែង។

បុណ្យអនុមោទនាជាបុណ្យដ៏ធំមួយឱ្យសុខប្រសើរទាំងក្នុងលោកនេះ ទាំងទៅបរលោក ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ព្រះគាថា :

**ន វេ កទរិយា ទេវលោកំ វជន្តិ**

**ពាលា ហវេ នប្បសំសន្តិ ទានំ**

**ធីរោ ច ទានំ អនុមោទមានោ**

**តេនេវ សោ ហោតិ សុខី បរត្ថ ។**

បុគ្គលកំណាញ់ ស្វិតស្វាញ មិនបានទៅកាន់ទេវលោកឡើយ ជនពាលទាំងឡាយមិនសរសើរនូវការឱ្យទានទេ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនាទាន ព្រោះហេតុនោះ លោករមែងបានសុខក្នុងលោកខាងមុខ។

ចប់ព្រះធម៌ទេសនា អមាត្យជុណ្ហៈបានសម្រេចសោតាបត្តិផល ។

ព្រះរាជា ជ្រះថ្លានឹងអមាត្យជុណ្ហៈ បានប្រគល់រាជសម្បត្តិឱ្យអមាត្យជុណ្ហៈធ្វើទានអស់ ៧ ថ្ងៃ ដោយទំនងដែលព្រះរាជាបានថ្វាយហើយ ដូចគ្នាដែរ ។

**២៣~ កិច្ឆោ មនុស្សប្បដិលាភោ** ការត្រឡប់បានអត្តភាពជាមនុស្ស ជាការក្រ។

ព្រះពុទ្ធបរមគ្រូ ស្តេចទ្រង់យាងទៅកាន់ដែនកាសី ទ្រង់ប្រថាប់ជិតក្រុងពារាណសី នៅក្រោមដើមច្រេសធំៗ ៧ ដើម ព្រះអង្គទ្រង់ប្រារព្ធស្តេចនាគឈ្មោះឯរកបត្ត។

ក្នុងសាសនាព្រះពុទ្ធកស្សបទសពល ឯរកបត្ត-នាគរាជនេះជាភិក្ខុកំលោះមួយអង្គ ត្រូវអាបត្តិក្នុងភូត-គាមសិក្ខាបទ។ ដោយការធ្វេសប្រហែស មិនប្រញាប់សម្តែងអាបត្តិ ដល់ពេលត្រូវអស់ជីវិតនឹកក្តៅក្រហាយចិត្តថា អាត្មាអញមានសីលមិនបរិសុទ្ធ ហើយក៏អស់ជីវិតទៅកើតក្នុងកំណើតសត្វតិរច្ឆាន ដែលមិនអាចសម្រេចមគ្គផលបាន។ កើតហើយក្តៅក្រហាយចិត្តទៀត ព្រោះខ្លួនខំប្រព្រឹត្តសមណធម៌អស់ ២ ម៉ឺនឆ្នាំ មកកើតជាអហេតុកសត្វ ទើបអង្គព្រះសម្ពុទ្ធទ្រង់ត្រាស់ព្រះគាថា :

**កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ។**

ការត្រឡប់បានអត្តភាពជាមនុស្សជាការក្រ ជីវិតរបស់សត្វទាំងឡាយរស់នៅបានដោយលំបាក កម្រនឹងបានស្តាប់ព្រះសទ្ធម្ម ការកើតឡើងនៃព្រះពុទ្ធទាំងឡាយជាការក្រក្រៃលែង។

ចប់ព្រះធម៌ទេសនា ពពួកជនជាច្រើនម៉ឺននាក់បានសម្រេចមគ្គផល ឯស្តេចនាគវិញគួរតែបានសម្រេចមគ្គផលក្នុងថ្ងៃនោះដែរ តែខ្លួនឯងជាសត្វតិរច្ឆាន ធ្វើដូចម្តេចនឹងបានទៅ ។

ពុទ្ធបរិស័ទយើងអ្នកមានសទ្ធា គួរកំណត់ឱ្យសុខចិត្តខ្លួនឯងថា រស់នៅសព្វថ្ងៃ បានត្រឹមតែមិនទាន់ស្លាប់ប៉ុណ្ណឹង គ្រប់គ្រាន់ហើយ ព្រោះជីវិតប៉ុណ្ណឹងឯងជាអារម្មណ៍នៃព្រះកម្មដ្ឋាន ជម្រះផ្លូវទៅព្រះនិព្វាន ។

**២៤. សុខោ ពុទ្ធានមុប្បាទោ** ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ។

សម្តេចព្រះទ្រង់ញាណ ព្រះអង្គគង់ប្រថាប់នៅក្នុងវត្តព្រះជេតពន ទ្រង់ប្រារព្ធការសន្ទនាគ្នារបស់ពួកភិក្ខុច្រើនអង្គ ។ ប្រធានបទនៃការសន្ទនាគឺ អ្វីជាសុខក្នុងលោកនេះ អង្គខ្លះឆ្លើយថា មិនមានអ្វីសុខដូចសុខក្នុងរាជសម្បត្តិទេ អង្គខ្លះទៀតថា កាមសុខ ឯភិក្ខុដទៃទៀតថា មិនមានអ្វីសុខជាងការបរិភោគបាយស្រូវសាលីជាមួយនឹងសាច់ឡើយ។ ព្រះបរមសាស្តា ព្រះអង្គទ្រង់យាងមកហើយត្រាស់ថា អ្នកទាំងឡាយពោលអ្វីហ្នឹង សុខទាំងនេះ សុទ្ធតែជាប់ទាក់ទងដោយទុក្ខក្នុងវដ្តៈទាំងអស់រួចហើយទើបព្រះអង្គត្រាស់ព្រះគាថា :

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ សុខោ។**

ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តី

សុខ សេចក្តីព្រមព្រៀងគ្នានៃសង្ឃ ឬ ពួកក្រុម នាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមដុតកិលេសនៃអ្នកព្រមព្រៀងគ្នាទាំងនោះ នាំមកនូវសេចក្តីសុខ ។

នៅពេលចប់ព្រះធម៌ទេសនា ភិក្ខុជាច្រើនអង្គសម្រេចព្រះអរហត្តផល ។

វៀរលែងតែព្រះបច្ចេកពុទ្ធចេញ សត្វលោកទាំង-អស់ សុទ្ធតែសម្រេចមគ្គផលដល់ព្រះនិព្វាន ដោយអាស្រ័យការត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធទាំងអស់។ ព្រះ-ធម៌ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែង អស្ចារ្យណាស់ធ្វើឱ្យអ្នកស្តាប់ដោយល្អ បាននូវបញ្ញា ដូច្នេះ ពុទ្ធបរិស័ទគួរតែព្រមព្រៀងគ្នារក្សាព្រះពុទ្ធសាសនា ហើយប្រព្រឹត្តធម៌ដោយខ្លួនឯង កុំរវល់តែចាប់កំហុសអ្នកដទៃ ត្រូវពិចារណាវិបាកកម្មរបស់ខ្លួន និង តក់ស្លុតចំពោះអកុសលក្នុងចិត្តខ្លួនឯង ។

**២៥. ជយំ វេរំ បសវតិ** អ្នកឈ្នះតែងជួបប្រទះនូវពៀរ។

ព្រះមានព្រះភាគ ទ្រង់គង់នៅព្រះជេតពនមហា-វិហារ ព្រះអង្គទ្រង់ប្រារព្ធបរាជ័យនៃព្រះបាទកោសល ។ ព្រះបាទបសេនទិកោសល ទ្រង់ធ្វើសង្គ្រាមចាញ់ព្រះបាទ-អជាតសត្តុ ដែលត្រូវជាក្មួយបង្កើតរបស់ព្រះអង្គ ទ្រង់កើតទុក្ខ បង្អត់អាហារព្រះអង្គឯង ដោយព្រះតម្រិះថា ប្រយោជន៍អ្វីដោយការរស់នៅរបស់យើង ។ ភិក្ខុទាំង-ឡាយក្រាបទូលសេចក្ដីនោះដល់ព្រះបរមសាស្ដា ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា :

**ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ**
**ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ។**

អ្នកឈ្នះតែងជួបប្រទះនូវពៀរ អ្នកចាញ់រមែងដេកជាទុក្ខ ចំណែកបុគ្គលដែលស្ងប់រំងាប់ លះបង់នូវការឈ្នះចាញ់ចេញហើយ រមែងនៅជាសុខ ។

បទថា **ជយំ** ដោយសេចក្ដីថា អ្នកឈ្នះនូវបុគ្គល

ដទៃ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់សរសើរបុគ្គលដែលឈ្នះខ្លួនឯងថា ជាការឈ្នះដ៏ឧត្តមក្នុងសមរភូមិវដ្តសង្សារ ។

ការខឹងក្រោធ កើតមកអំពី :

១- ចាប់កំហុសអ្នកដទៃ

២- មិនតក់ស្លុតចំពោះអកុសលខ្លួនឯង ។

ដោយបរមត្ថ អ្នកដទៃគឺគ្រាន់តែមនោទ្វារវិថីចិត្តខ្លួនឯងសាងឡើងប៉ុណ្ណោះ អ្វីៗនោះ ត្រឹមតែជាវិថីចិត្ត និង អារម្មណ៍របស់វិថីចិត្តប៉ុណ្ណោះឯង ជាពិសេសវិបាករបស់កម្មតាមបញ្ចទ្វារ ដែលមិនមានបុគ្គលដទៃធ្វើកម្ម ហើយយើងជាអ្នកទទួលវិបាកនោះឡើយ ។ លោកទាំង ៦ សូន្យចាកសត្វបុគ្គលតួខ្លួន មានអ្នកណាមកធ្វើឱ្យយើងចាប់កំហុសហើយខឹងក្រោធទៅរកនោះ តែបើពោលពីសត្រូវពិតប្រាកដ គឺកិលេសក្នុងចិត្តខ្លួនឯង បើកិលេសមិនមានហើយ បញ្ហាកង្វល់ក្នុងវដ្តសង្សារក៏ត្រូវចប់ដែរ។

បិដកលេខ ៥២ ,ទំព័រ ៦៤ ,បន្ទាត់ ២

**២៦. ជិឃច្ឆា បរមា រោគា** ការស្រេកឃ្លាន គឺជារោគយ៉ាងក្រៃលែង ។

ព្រះសុគតសាស្តា ទ្រង់ប្រថាប់នៅនគរអាឡវី ទ្រង់ប្រារព្ធឧបាសកម្នាក់។ ឧបាសកនោះចង់ស្តាប់ព្រះធម៌ទេសនារបស់ព្រះបរមសាស្តា ប៉ុន្តែត្រូវទៅរកគោសិន ដល់ថ្ងៃត្រង់ទើបបានមក ហើយមានការស្រេកឃ្លានខ្លាំង ។ ព្រះមានព្រះភាគ ទ្រង់យាងពីសាវត្ថីមក ៣០ យោជន៍ដើម្បីឧបាសកម្នាក់នោះឯង កាលឧបាសកមិនទាន់មក ទ្រង់មិនត្រាស់សម្តែងព្រះធម៌ឡើយ ។ កាលឧបាសកមកហើយ ព្រះអង្គត្រាស់ចាត់ឱ្យគេរៀបចំអាហារឱ្យដល់ឧបាសកនោះ ។ ការចាត់ចែងអាហារដោយព្រះ-តថាគតដូច្នេះ មានតែម្តងហ្នឹងគត់ ក្នុងព្រះត្រៃបិដក ជាការអនុគ្រោះដើម្បីឧបាសកនោះមានកាយ និង ចិត្តស្ងប់ស្តាប់ព្រះធម៌សម្រេចសោតាបត្តិផល ។

ភិក្ខុទាំងឡាយ ពោលទោសចំពោះព្រះបរមសា-ស្តាក្នុងរឿងចាត់ចែងនូវអាហារនោះ ទើបព្រះអង្គត្រាស់

នូវព្រះគាថា ដូច្នេះថា ៖

**ជិឃច្ឆា បរមា រោគា សង្ខារា បរមា ទុក្ខា**

**ឯតំ ញត្វា យថាភូតំ និព្វានំ បរមំ សុខំ។**

ការស្រេកឃ្លាន គឺជារោគយ៉ាងក្រៃលែង សង្ខារទាំងឡាយជាទុក្ខយ៉ាងក្រៃលែង អ្នកប្រាជ្ញដឹងច្បាស់នូវសេចក្ដីនោះ តាមពិតហើយ រមែងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ព្រោះព្រះនិព្វានជាសុខយ៉ាងក្រៃលែង ។

បាទព្រះគាថាថា **ជិឃច្ឆា បរមា រោគា** ដោយសេចក្ដីថា បើរោគដទៃ រក្សាម្ដងក៏ជាសះស្បើយ ឬថាបុគ្គលអាចកម្ចាត់បង់បាន ឯចំណែកការស្រេកឃ្លានវិញត្រូវរក្សាអស់កាលជានិច្ច ។

អ្នកដែលពោលទោសចំពោះព្រះបរមសាស្ដា គឺមានតែបុថុជ្ជនប៉ុណ្ណោះ ចំណែកព្រះអរិយបុគ្គលវិញនោះសូម្បីតែទោមនស្សក្នុងចិត្តបន្តិចបន្តួចចំពោះព្រះអង្គ ក៏ពុំមានដែរ ព្រោះលោកបានជ្រាបនូវព្រះពុទ្ធគុណច្បាស់ ។

បិដកលេខ ៥២ ,ទំព័រ ៦៤ ,បន្ទាត់ ៣-៥

**២៧- និព្វានំ បរមំ សុខំ** ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ពាក្យនេះ ប្រារព្ធចំពោះឧបាសកម្នាក់នៅនគរអាឡវីផង និង ទ្រង់ប្រារព្ធចំពោះព្រះបាទបសេនទិកោសលផង ។

ព្រះនិព្វានជាបរមសុខ ព្រោះការអស់ទៅនៃទុក្ខទាំងពួង ព្រះនិព្វានគឺជាទុក្ខនិរោធអរិយសច្ច ។ ពាក្យថាទុក្ខទាំងពួង គឺជាវដ្តសង្សារដែលសន្មតថាជាយើង ថាជាគេម្នាក់ៗរៀងៗខ្លួនហ្នឹងឯង ។ វដ្តសង្សារ គឺជាតំណនៃខន្ធ មួយខណៈៗ អស់ពីមួយជាតិ តមួយជាតិ ដោយមិនដឹងទីបំផុតខាងដើមពីត្រឹមណាមក ត្រូវបញ្ចប់ដោយអរហត្តមគ្គ និង ទីបំផុតនៃសង្សារត្រឹមការបរិនិព្វានរបស់ព្រះអរហន្ត អស់ជាតិ អស់កំណើត ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា នាមរូបរលត់អស់មិនមានសេសសល់ព្រោះការរលត់ទៅនៃវិញ្ញាណ ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាព្រះវិហារ-

ជេតពន ទ្រង់ប្រារព្ធព្រះបាទបសេនទិកោសល ។

ព្រះរាជាមានរឿងនាំឱ្យសប្បាយព្រះហឫទ័យ ៤ រឿង គឺ ១- សប្បាយព្រះកាយ ព្រោះស្គាល់ប្រមាណក្នុងការសោយព្រះក្រយា , ២- ឈប់ធ្វើចម្បាំងជាមួយនឹងស្ដេចក្មួយ គឺព្រះបាទអជាតសត្តុ , ៣- រកកែវមណីរបស់ព្រះបាទកុសរាជឃើញ កែវមណីនោះបានមកជារបស់ព្រះអង្គទ្រង់រាជ្យ , ៤- បាននាង **វាសភខត្តិយា** ធីតាក្រុងកបិលពស្តុក្នុងបំណងចង់ធ្វើជាញាតិនៃព្រះសម្មាសម្ពុទ្ធ។

ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថា :

**អារោគ្យបរមា លាភា សន្តុដ្ឋិបរមំ ធនំ**

**វិស្សាសបរមា ញាតី និព្វានំ បរមំ សុខំ ។**

លាភទាំងឡាយ មានការមិនមានរោគ ជាយ៉ាងក្រៃលែង ទ្រព្យមានសេចក្ដីសន្តោស ជាយ៉ាងក្រៃលែង ញាតិមានសេចក្ដីស្និទ្ធស្នាល ជាយ៉ាងក្រៃលែង ព្រះនិព្វានជាសុខយ៉ាងក្រៃលែង ។

**២៨. សាធុ ទស្សនមរិយានំ** ការបានជួបប្រទះឃើញព្រះអរិយៈទាំងឡាយ ជាការល្អប្រសើរ (ព្រោះញ៉ាំងប្រយោជន៍ឱ្យសម្រេច) ។

ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅនាវេឡុវ-គ្រាមទ្រង់មាននូវអាពាធដ៏ធ្ងន់គឺចុះព្រះលោហិត ព្រះអង្គទ្រង់ប្រារព្ធសក្កទេវរាជ ។ សក្កទេវរាជបានមកបម្រើព្រះបរមសាស្តា ទូលឧច្ចារៈលាយដោយព្រះលោហិតលើព្រះសីសៈ ប្រព្រឹត្តដោយសេចក្តីគោរពយ៉ាងក្រៃលែង ដែលធ្វើឱ្យភិក្ខុទាំងឡាយពោលសរសើរ ។ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជធ្វើនូវការគោរពស្រឡាញ់ចំពោះតថាគតនេះ មិនគួរឱ្យអស្ចារ្យឡើយ ព្រោះសក្កទេវរាជស្តាប់ធម៌ទេសនាហើយសម្រេចសោតាបត្តិផល លះបង់នូវជរាភាព បានជាព្រះ-ឥន្ទកំលោះ អាស្រ័យនឹងតថាគត នៅនាឥន្ទសាលគុហាព្រមដោយទេវតា ១៤ កោដិសម្រេចធម្មាភិសម័យ ។ តថាគតមានឧបការៈច្រើនដល់សក្កទេវរាជនោះ ដោយ

ប្រការយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ការបានជួបប្រទះឃើញព្រះអរិយៈទាំងឡាយ ជាការល្អប្រសើរ... ។

ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថា :

**សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ**
**អទស្សនេន ពាលានំ និច្ចមេវ សុខី សិយា ។**

ការបានជួបប្រទះឃើញព្រះអរិយៈទាំងឡាយ ជាការល្អប្រសើរ ការនៅរួមជាមួយនឹងព្រះអរិយៈទាំងឡាយ ជាហេតុឱ្យកើតនូវសេចក្តីសុខសព្វកាល បុគ្គលគប្បីមានសេចក្តីសុខអស់កាលជានិច្ច ព្រោះមិនជួបប្រទះនូវបុគ្គលពាលទាំងឡាយ ។

ពាក្យថា **សាធុ** អដ្ឋកថាថា **សាធុ** បានដល់ជាការញ៉ាំងប្រយោជន៍ឱ្យសម្រេច គឺថាជាសេចក្តីល្អ បានដល់ កម្មដ៏ចម្រើន ។

**២៩~ អក្កោធេន ជិនេ កោធំ** ឈ្នះអ្នកខឹងក្រោធដោយការមិនក្រោធ ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារវេឡុវ័ន ទ្រង់ធ្វើភត្តកិច្ចនៅផ្ទះនាងឧត្តរាបុត្រីសេដ្ឋីបុណ្ណៈ ទ្រង់ប្រារព្ធនាងឧត្តរាសម្តែងនូវព្រះធម៌ទេសនា ។

នាងឧត្តរាឧបាសិកា បានសម្រេចសោតាបត្តិផលជាមួយនឹងមាតាបិតា ក្នុងពេលស្តាប់ព្រះធម៌ តាំងតែពីនាងនៅមិនទាន់មានស្វាមី ។ នៅពេលដែលនាងមានប្តីបានពីរខែកន្លះ នាងបានជួលស្ត្រីរូបស្អាតម្នាក់ឈ្មោះនាងសិរិមា ឱ្យមកបម្រើប្តីរបស់នាង ទើបនាងបានឱកាសចាត់ចែងថ្វាយចង្ហាន់ដល់ព្រះភិក្ខុសង្ឃ និង ព្រះមានព្រះភាគ ។ នាងសិរិមា ភ្លេចខ្លួនកើតចិត្តប្រចណ្ឌ ហើយធ្វើការប្រទូស្តចំពោះនាងឧត្តរា ប៉ុន្តែដោយសារមេត្តាភាវនារបស់នាងឧត្តរា បានធ្វើឱ្យនាងសិរិមាភ្ញាក់ខ្លួនសូមខមាទោស ព្រមទាំងបានស្តាប់ព្រះធម៌ទេសនា ដែលព្រះអង្គត្រាស់ថា ឈ្នះអ្នកខឹងក្រោធ ដោយការមិនក្រោធ ឈ្នះ

មនុស្សមិនល្អដោយសេចក្តីល្អ... ។ នាងសិរិមាបាន សម្រេចសោតាបត្តិផល ។

ព្រះអង្គទ្រង់ត្រាស់សម្តែងនូវព្រះគាថា :

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

ឈ្នះមនុស្សក្រោធដោយការមិនក្រោធ ឈ្នះមនុស្សមិនល្អដោយសេចក្តីល្អ ឈ្នះមនុស្សកំណាញ់ដោយការឱ្យ ឈ្នះមនុស្សពោលពាក្យមិនពិត ដោយពាក្យពិត ។

បើមិនឈ្នះការខឹងក្រោធរបស់អ្នកដទៃទេ ក៏បានឈ្នះការខឹងក្រោធខ្លួនឯងដែរ ដូច្នេះការមិនក្រោធ គឺជាការធ្វើបុណ្យដ៏ធំមួយ ។ ឯការឈ្នះសេចក្តីអាក្រក់របស់ខ្លួនជាដើម ក៏ដូច្នោះដែរ ។

បិដកលេខ ៥២ ,ទំព័រ ៧២ ,បន្ទាត់ ៧

**៣០. បមាទោ រក្ខតោ មលំ** សេចក្ដីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា។

ព្រះបរមសាស្ដា ទ្រង់គង់ប្រថាប់នៅព្រះជេតពន-មហាវិហារ ទ្រង់ប្រារព្ធនូវព្រះភិក្ខុលោឡុទាយី ។ កាលដែលមហាជនពោលសរសើរគុណព្រះអគ្គសាវ័កទាំង ២ ភិក្ខុលោឡុទាយីបានសម្ដែងខ្លួនធ្វើគ្រាន់បើ ដើម្បីឱ្យអ្នកស្រុកនិមន្តលោកទេសនា លុះដល់អ្នកស្រុកត្រូវការលោកបែរជាសម្ដែងអត់បានធម៌អ្វីទាំងអស់។ ព្រះដ៏មាន-ព្រះភាគ ទ្រង់ត្រាស់ថា មន្តទាំងឡាយមានការមិនស្វាធ្យាយជាមន្ទិល ផ្ទះទាំងឡាយមានការមិនថែទាំជាមន្ទិល សេចក្ដីខ្ជិលជាមន្ទិលនៃពណ៌សម្បុរ រីឯសេចក្ដីប្រមាទ ជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

អ្នករក្សាគោ កាលបើធ្វេសប្រហែស គោរមែងចុះស៊ីសន្ទូងខ្លួនឯង ឬ សន្ទូងអ្នកដទៃ ពុំនោះសោត គោចូលព្រៃជួបក្ដីអន្តរាយផ្សេងៗ យ៉ាងណាមិញ ការរក្សាចិត្ត គ្រប់គ្រងទ្វារ ៦ ក៏ដូច្នោះដែរ អារម្មណ៍ ៦ ដូចជា

សន្ទូង ចំណែកពាលធម៌ដែលជាបាបមិត្តរបស់ចិត្ត ដូចជាព្រៃដែលពេញដោយគ្រោះថ្នាក់ផ្សេងៗ មានគ្រោះថ្នាក់ដោយសត្វសាហាវជាដើម ចំណែកស្មារតីដូចជាអ្នករក្សាគោ រីឯចិត្តដូចជាគោ ។

ព្រះគាថាប្រារព្ធភិក្ខុលោឡុទាយី :

**អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា**
**មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ។**

មន្តទាំងឡាយមានការមិនស្វាធ្យាយជាមន្ទិល ផ្ទះទាំងឡាយមានការមិនថែទាំជាមន្ទិល សេចក្តីខ្ជិលជាមន្ទិលនៃពណ៌សម្បុរ រីឯសេចក្តីប្រមាទជាមន្ទិលរបស់បុគ្គលអ្នករក្សា ។

បិដកលេខ ៥២ ,ទំព័រ ៧២ ,បន្ទាត់ ១០

**៣១- អវិជ្ជា បរមំ មលំ** អវិជ្ជាជាមន្ទិលដ៏ក្រៃលែង ។

ព្រះបរមសាស្ដា ទ្រង់គង់នៅព្រះវេឡុវ័នមហាវិហារ ទ្រង់ប្រារព្ធកុលបុត្រម្នាក់ ។ កុលបុត្រនោះឯងមានភរិយាក្បត់ចិត្ត រួចទៅខ្លួនឯងខ្មាសគេមិនហ៊ានចូលវត្ត ក្រោយមកទើបចូលគាល់ព្រះបរមសាស្ដា ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងព្រះជាតក ហើយត្រាស់សម្ដែងព្រះធម៌ទេសនាអំពីមន្ទិលជាច្រើនប្រការ ។

ព្រះអង្គទ្រង់ត្រាស់ថា :

**មលិត្ថិយា ទុច្ចរិតំ មច្ឆេរំ ទទតោ មលំ**
**មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច**
**តតោ មលា មលតរំ អវិជ្ជា បរមំ មលំ**
**ឯតំ មលំ បហន្ត្វាន និម្មលា ហោថ ភិក្ខវោ។**

ការប្រព្រឹត្តអាក្រក់ជាមន្ទិលរបស់ស្ត្រី សេចក្តីកំណាញ់ជាមន្ទិលរបស់អ្នកឱ្យ ធម៌អាក្រក់ទាំងឡាយជាមន្ទិលក្នុងលោកនេះ និង ក្នុងលោកខាងមុខ ឯចំណែក

ធម្មជាតិជាមន្ទិលដ៏ក្រៃលែង ជាងមន្ទិលទាំងនោះ គឺអវិជ្ជា អវិជ្ជាជាមន្ទិលដ៏ក្រៃលែង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះមន្ទិលទាំងនោះចេញ ចូរកុំជាអ្នកមាននូវមន្ទិលឡើយ ។

ការមិនដឹងសេចក្តីពិត នាំឱ្យជាប់ជំពាក់ចិត្ត ឬកើតទុក្ខមិនសុខចិត្តក្នុងរឿងរ៉ាវផ្សេងៗ ។ បុគ្គលល្ងង់ខ្លៅជាកំពូលសត្រូវនឹងខ្លួនឯង ចំណែកបណ្ឌិតបានដឹងការពិតរមែងបានជាទីពឹងឱ្យខ្លួនឯង ។

**មលិត្ថិយា ទុច្ចរិតំ** អដ្ឋកថាថា ការប្រព្រឹត្តកន្លងចិត្តប្តី ឈ្មោះថាទុច្ចរិតក្នុងព្រះគាថានេះ ។

បិដកលេខ ៥២ ,ទំព័រ ៧៣ ,បន្ទាត់ ១៣

**៣២~ នត្ថិ រាគសមោ អគ្គិ ភ្លើងស្មើដោយរាគៈ មិនមាន ។**

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ទ្រង់ប្រារព្ធឧបាសក ៥ នាក់ ។ ក្នុង ៥ នាក់នោះ មានតែឧបាសកម្នាក់ប៉ុណ្ណោះដែលស្តាប់ព្រះធម៌ដោយគោរព ។ ការដែលមិនអាចស្តាប់បាន ព្រោះមិនធ្លាប់សន្សំការស្តាប់រាប់ជាតិជាអនេកមក គឺធ្លាប់តែស្តាប់តិរច្ឆានកថា ដោយប្រការផ្សេងៗ និង ស្តាប់ភ្លេងកម្សាន្តរាំច្រៀង ។ ម្យ៉ាងទៀត ព្រោះអាស្រ័យរាគៈ ទោសៈ មោហៈ និង តណ្ហា ទើបមិនអាចស្តាប់ធម៌បាន។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា :

**នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ**
**នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី។**

ភ្លើងស្មើដោយរាគៈ មិនមាន ការចាប់ស្មើដោយទោសៈ មិនមាន សំណាញ់ស្មើដោយមោហៈ មិនមាន ស្ទឹងទន្លេស្មើដោយតណ្ហា មិនមាន ។

ភ្លើងអាចញ៉ាំងកប្បឱ្យវិនាសបាន ប៉ុន្តែយូរៗម្តង ប៉ុណ្ណោះ ឯចំណែកភ្លើងគឺរាគៈវិញនោះ ឆេះអស់កាលជានិច្ច ម្យ៉ាងទៀត ភ្លើងខាងក្រៅក្តៅណាស់ឆេះចំពោះរូបតែប៉ុណ្ណោះ ចំណែករាគៈដុតឆេះកុសលធម៌ផ្សេងៗឱ្យវិនាសបាត់បង់អស់ ។ ឧបាសកអ្នកស្តាប់ធម៌ដោយគោរពបានសម្រេចសោតាបត្តិផល ។

សត្វនៅក្នុងអបាយភូមិ មិនអាចប្រារព្ធនូវសេចក្តីព្យាយាមដើម្បីការត្រាស់ដឹងសច្ចធម៌បានឡើយ ។ គោ ក្របី ដំរី សេះ សម្រាប់បម្រើក្នុងការងារ ប្រេតមានទុក្ខវេទនាព្រោះស្រេកឃ្លាន ឯចំណែកសត្វនរកវិញខ្វាំងក្លាដោយសេចក្តីទុក្ខ ... « ម្នាលភិក្ខុទាំងឡាយ នេះជាពេលវេលា ដែលអ្នកទាំងឡាយត្រូវប្រារព្ធនូវសេចក្តីព្យាយាម » ។

បិដកលេខ ៥២ ,ទំព័រ ៧៤ ,បន្ទាត់ ១០

**៣៣~ សទ្ធារា សស្សតា នត្ថិ** សង្ខារទាំងឡាយជារបស់ទៀង មិនមាន ។

ព្រះបរមសាស្តា ទ្រង់ផ្ទំដោយអនុដ្ឋានសញ្ញា នៅនាសាលវន៍របស់ពួកមល្លក្សត្រ ក្នុងនគរកុសិនារា ព្រះអង្គទ្រង់ប្រោសព្វបរិព្វាជកឈ្មោះសុភទ្ទៈ ។

ព្រះដ៏មានព្រះភាគ ទ្រង់បរិនិព្វាននៅនគរកុសិនារា ដើម្បីប្រយោជន៍៣ យ៉ាង គឺ

(១)- សម្តែងមហាសុទស្សនសូត្រ ប្រារព្ធនគរកុសិនារា។

(២)- បានទោណព្រាហ្មណ៍ចែកព្រះបរមសារីរិកធាតុ ។

(៣)- ដើម្បីប្រោសសុភទ្ទបរិព្វាជក ជាសាវក័សម្រេចព្រះអរហត្តចុងក្រោយ ក្នុងការគង់ព្រះជន្មនៅនៃព្រះបរមសាស្តា ។

សុភទ្ទបរិព្វាជក ធ្លាប់ជាបងប្អូនរបស់ព្រះអញ្ញាកោណ្ឌញ្ញៈក្នុងអតីតជាតិ ជាអ្នកមានឧបនិស្ស័យយឺតយ៉ាវក្នុងការធ្វើទាន រហូតមកដល់ជាតិចុងក្រោយ ក៏ជាប់ឧបនិស្ស័យយឺតយ៉ាវនោះមក ពោលគឺយឺតយ៉ាវក្នុងការ

ចូលគាល់ព្រះដ៏មានព្រះភាគ ។ កាលដែលក្រាបទូលសួរបញ្ហាហើយ ទើបព្រះសុគតសាស្តាត្រាស់វិសជ្ជនា ... សង្ខារទាំងឡាយជារបស់ទៀង មិនមាន ។

**អាកាសេ ច បទំ នត្ថិ សមណោ នត្ថិ ពាហិរេ សង្ខារា សស្សតា នត្ថិ នត្ថិ ពុទ្ធានមិញ្ជិតំ ។**

ស្នាមជើងក្នុងអាកាស មិនមាន សមណៈខាងក្រៅ មិនមាន សង្ខារទាំងឡាយជារបស់ទៀង មិនមាន ព្រះពុទ្ធគ្រប់ព្រះអង្គ មិនមានកិលេសជាគ្រឿងញាប់ញ័រឡើយ ។

យើងត្រូវកុំភ្លេចថា មានតែខ្លួនយើងប៉ុណ្ណោះ ដែលអាចរំលត់កិលេសឱ្យខ្លួនយើងបាន ដូច្នេះទើបយើងមិនត្រូវជាមនុស្សឡេះឡោះ ឥតបានការនោះទេ ។

បិដកលេខ ៥២ ,ទំព័រ ៧៨ ,បន្ទាត់ ៨

**៣៤. មគ្គានដ្ឋង្គិកោ សេដ្ឋោ** ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ ។

ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅនាព្រះវិហារជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥០០ អង្គ។ ព្រះភិក្ខុទាំងនោះ គង់ក្នុងសាលា ប្រជុំគ្នាពោលអំពីផ្លូវពីភូមិមួយទៅភូមិមួយ រាបស្មើខ្លះ មិនរាបស្មើខ្លះ ។ ព្រះសុគត-សាស្តា ស្តេចទ្រង់យាងមកកាន់ទីប្រជុំនោះ ហើយព្រះ-អង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវដែលអ្នកទាំងឡាយពោលនេះ ជាផ្លូវខាងក្រៅទេ ផ្លូវគឺអរិយមគ្គ ទើបជាផ្លូវចេញផុតអំពីទុក្ខបាន រួចហើយទ្រង់ត្រាស់ជាបន្តថា :

**មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្ចានំ ចតុរោ បទា**
**វិរាគោ សេដ្ឋោ ធម្មានំ ទិបទានញ្ច ចក្ខុមា**
**ឯសេវ មគ្គោ នត្ថញ្ញោ ទស្សនស្ស វិសុទ្ធិយា។**
**ឯតញ្ហិ តុម្ហេ បដិបជ្ជថ មារស្សេតំ បមោហនំ**
**ឯតញ្ហិ តុម្ហេ បដិបន្នា ទុក្ខស្សន្តំ ករិស្សថ ។**
**អក្ខាតោ វោ មយា មគ្គោ អញ្ញាយ សល្លសត្ថនំ**

តុម្ហេហិ កិច្ចំ អាតប្បំ    អក្ខាតារោ តថាគតា
បដិបន្នា បមោក្ខន្តិ    ឈាយិនោ មារពន្ធនា។

ផ្លូវមានអង្គ ៨ ប្រសើរជាងផ្លូវទាំងឡាយ បទ ៤ គឺ អរិយសច្ច ប្រសើរជាងសច្ចៈទាំងឡាយ វិរាគធម៌គឺព្រះនិព្វាន ប្រសើរជាងធម៌ទាំងឡាយ ព្រះតថាគតមាននូវចក្ខុ ប្រសើរជាងសត្វទ្វេបាទទាំងឡាយ ។ ផ្លូវនេះឯងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃទស្សនៈ ផ្លូវដទៃមិនមានឡើយ ព្រោះហេតុនោះ អ្នកទាំងឡាយចូរធ្វើដំណើរតាមផ្លូវនេះ ផ្លូវនេះជាផ្លូវញ៉ាំងមារឱ្យវង្វេង អ្នកទាំង-ឡាយដើរតាមផ្លូវនេះហើយ នឹងធ្វើឱ្យផុតទុក្ខបាន ។

ផ្លូវនេះហើយ ដែលតថាគតដឹងថា ជាផ្លូវកម្ចាត់បង់នូវកូនសរ តថាគតប្រាប់ដល់អ្នកទាំងឡាយ សេចក្តីព្យាយាមញ៉ាំងកិលេសឱ្យក្តៅសព្វ អ្នកទាំងឡាយគប្បីធ្វើ ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ ជនទាំង-ឡាយ ជាអ្នកធ្វើដំណើរទៅហើយ ដោយការសម្លឹងពិនិត្យ នឹងរួចចាកបំណងរបស់មារបាន ។

បិដកលេខ ៥២ ,ទំព័រ ៧៩ ,បន្ទាត់ ៣

**៣៥~ សព្វេ សង្ខារា អនិច្ចា** សង្ខារទាំងពួង មិនទៀង ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាវិហារ-ព្រះជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥០០ អង្គដទៃទៀត។ ព្រះភិក្ខុទាំងនោះប្រឹងប្រែងព្យាយាមនៅក្នុងព្រៃ ប៉ុន្តែមិនបានសម្រេចព្រះអរហត្តឡើយ ទើបនិមន្តមកគាល់ព្រះដ៏មាន-ព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ភិក្ខុទាំងនេះក្នុងកាលនៃព្រះកស្សបទសពល បានប្រកបហើយក្នុងអនិច្ចលក្ខណៈអស់ ២ ម៉ឺនឆ្នាំ ទើបព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងពួងក្នុងភពទាំងឡាយ មានកាមភពជាដើម ជាសភាវៈមិនទៀងឡើយ ព្រោះអត្ថថា មានហើយត្រឡប់ទៅជាមិនមាន គឺបាត់អស់ទៅវិញ។ ជាបន្តទ្រង់ត្រាស់ព្រះគាថា :

**សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា។**

ក្នុងកាលណា បុគ្គលបានឃើញដោយបញ្ញាថា

សង្ខារទាំងពួងមិនទៀង ដូច្នេះ ក្នុងកាលនោះ រមែងនឿយណាយក្នុងទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

ខន្ធទាំងឡាយដែលកើតឡើងហើយក្នុងភពឈ្មោះថា មិនទៀង ព្រោះត្រូវរលត់ទៅក្នុងភពនោះៗឯង ម្យ៉ាះហើយការហួងហែងខន្ធមួយជាតិៗ ត្រូវចោលទៅទទេ ។

នៅមានភិក្ខុ ៥០០ អង្គដទៃទៀត ដែលព្រះបរមសាស្តាទ្រង់ទូន្មានដោយព្រះគាថាថា **សព្វេ សង្ខារា ទុក្ខាតិ** ដូច្នេះជាដើម។ រីឯ ៥០០ អង្គផ្សេងទៀតព្រះអង្គត្រាស់ថា **សព្វេ ធម្មា អនត្តាតិ** តាមឧបនិស្ស័យនៃភិក្ខុទាំងនោះ ។ ចប់ព្រះធម៌ទេសនា ភិក្ខុទាំងអស់អង្គនោះ សុទ្ធតែបានសម្រេចព្រះអរហត្តផល ។

បិដកលេខ ៥២ ,ទំព័រ ៨៤ ,បន្ទាត់ ២

**៣៦~ ទុប្បព្វជ្ជំ ទុរភិរមំ** ការដែលមានសទ្ធាចេញចាកផ្ទះចូលកាន់ផ្នួសបួសជាបព្វជិត បានដោយក្រ។

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់អាស្រ័យក្រុងវេសាលី គង់ប្រថាប់នៅនាមហាវ័ន បានប្រារព្ធភិក្ខុមួយអង្គជាឱរសរបស់ស្តេចក្នុងដែនវជ្ជី ។ ព្រះភិក្ខុអង្គនេះស្រណោះខ្លួន សោកសៅ ព្រោះប្រារព្ធកាមគុណ ៥ ។ មានទេវតាមួយអង្គ បានមកពោលផ្តល់កម្លាំងចិត្តដល់លោក ស្នែកឡើងព្រះភិក្ខុបានចូលគាល់ព្រះបរមសាស្តា ព្រះពុទ្ធបរមគ្រូទ្រង់ប្រកាសទុក្ខរបស់ឃរាវាស និង ទុក្ខក្នុងវដ្តសង្សារ ព្រះអង្គទ្រង់ត្រាស់ថា :

**ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា**
**ទុក្ខោ សមានសំវាសោ ទុក្ខានុបតិតទ្ធគូ**
**តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា។**

ការចេញមកបួសបានដោយក្រ ការត្រេកអរក្នុងធម៌វិន័យបានដោយក្រ ផ្ទះគ្រប់គ្រងមិនល្អនាំឱ្យកើតទុក្ខ ការនៅរួមជាមួយជនស្មើគ្នា ពោលគឺមិនកោតក្រែងគ្នា

នាំមកនូវទុក្ខ  បុគ្គលដើរផ្លូវឆ្ងាយក្នុងវដ្តៈត្រូវទុក្ខជាប់តាម ព្រោះហេតុនោះ    បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយក្នុង វដ្តៈ និង មិនគប្បីជាអ្នកមានទុក្ខជាប់តាម ។ ភិក្ខុវជ្ជីបុត្រ សម្រេចព្រះអរហត្តនៅពេលចប់ព្រះធម៌ទេសនា ។

បទថា **ទុប្បព្វជ្ជំ** ដោយសេចក្តីថា ឈ្មោះថា ការ លះគំនរទ្រព្យសម្បត្តិ តិចក៏ដោយ ច្រើនក៏ដោយ និង ពួក ញាតិ បួសថ្វាយជីវិតក្នុងព្រះសាសនានេះ ជាការក្រ ។

បទថា **ទុរភិរមំ** ដោយសេចក្តីថា ការដែលកុល- បុត្របួសហើយយ៉ាងនេះ បានចិញ្ចឹមជីវិតដោយការនិមន្ត បិណ្ឌបាត ត្រេកអរក្នុងការគ្រប់គ្រងគុណគឺសីលដែលមិន មានប្រមាណ និង បំពេញធម៌បដិបត្តិដ៏សមគួរដល់ធម៌ឱ្យ បរិបូណ៌ ជាការក្រ។

**៣៧~ អភូតវាទី និរយំ ឧបេតិ** អ្នកដែលពោលពាក្យមិនពិត រមែងទៅកាន់នរក។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធនាងបរិព្វាជិកាឈ្មោះ សុន្ទរី។

ដើមរឿង មកអំពីលាភសក្ការៈបីដូចក្រសែទឹកនៃបញ្ចមហានទី កើតឡើងដល់ព្រះដ៏មានព្រះភាគ និងព្រះភិក្ខុសង្ឃ ឯចំណែកពួកអន្យតិរ្ថិយ៍ក៏សាបសូន្យចាកលាភសក្ការៈ ដូចជាអំពិលអំពែកក្នុងវេលាព្រះអាទិត្យរះឡើង ដូច្នោះឯង ។ ព្រោះហេតុនោះ ទើបពួកអន្យតិរ្ថិយ៍មានគំនិតអាក្រក់ ហើយចាត់ចែងឱ្យនាងសុន្ទរីពោលកុហកពួកពុទ្ធបរិស័ទថា ខ្លួនបានទៅរួមអភិរម្យដោយកិលេសក្នុងព្រះគន្ធកុដិ ជាមួយនឹងព្រះសមណគោតម ។ លុះក្រោយមក បានជួលពួកអ្នកលេងឱ្យសម្លាប់នាងសុន្ទរី ហើយកប់សពក្បែរព្រះគន្ធកុដិនាវត្តជេតពននោះឯង គឺដើម្បីទម្លាក់កំហុសចំពោះភិក្ខុសង្ឃ ។ រឿងរ៉ាវអាក្រក់ទាំងអស់ត្រូវបែកការណ៍ ព្រោះពួកអ្នកលេងស្រវឹងស្រា

ឈ្លោះគ្នានិយាយចេញមក។ ចំពោះរឿងនេះ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ថា **អភូតវាទី និរយំ ឧបេតិ...។** **អភូតវាទី** គឺរកកំហុសអ្នកដទៃមិនបានក៏ក្លែងរឿងពោលចោទប្រកាន់ដោយពាក្យមិនពិត ។

ព្រះគាថាទ្រង់ប្រារព្ធនាងសុន្ទរី :

**អភូតវាទី និរយំ ឧបេតិ**
**យោ វាបិ កត្វា ន ករោមីតិ ចាហ**
**ឧភោបិ តេ បេច្ច សមា ភវន្តិ**
**និហីនកម្មា មនុជា បរត្ថ ។**

អ្នកដែលពោលពាក្យមិនពិត រមែងទៅកាន់នរក ឬ បុគ្គលណាធ្វើអំពើអាក្រក់ហើយ និយាយថាអញមិនធ្វើទេ បុគ្គលនោះ ក៏ធ្លាក់នរកដូចគ្នាដែរ ។ ជនទាំងពីរពួកនោះ ដែលមានអំពើថោកទាបដូចគ្នា លុះលះលោកនេះទៅហើយ រមែងជាអ្នកស្មើគ្នាដោយគតិក្នុងលោកខាងមុខ ។

បិដកលេខ ៥២ ,ទំព័រ ៨៦ ,បន្ទាត់ ១២

**៣៨~ អកតំ ទុក្កតំ សេយ្យោ** អំពើអាក្រក់ដែលបុគ្គលមិនធ្វើ ប្រសើរជាង ។

ព្រះដ៏មានព្រះភាគ កាលដែលទ្រង់គង់ប្រថាប់នៅនាព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធស្ត្រីប្រណែនម្នាក់ ។ ស្ត្រីប្រណែនម្នាក់នេះ បានចាប់ចងដៃចងជើងស្រីបម្រើម្នាក់ ហើយបានកាត់ចុងច្រមុះ កាត់ស្លឹកត្រចៀកស្រីបម្រើនោះ ដោយចោទប្រកាន់ថា ធ្វើការស្និទ្ធស្នាលនឹងប្ដីរបស់ខ្លួន រួចហើយបានឃុំឃាំងស្រីបម្រើក្នុងបន្ទប់មួយ ដើម្បីបិទបាំងនឹងប្ដី កាលដែលប្ដីមកដល់ផ្ទះនោះឯង ក៏បានបបួលប្ដីទៅវត្តស្ដាប់ធម៌ ។ ពេលដែលនាំប្ដីចេញផុតពីផ្ទះ មានភ្ញៀវមកដល់ ភ្ញៀវនោះឯងបានជួយស្រីបម្រើឱ្យចេញពីបន្ទប់ឃុំឃាំង ស្រីបម្រើនោះក៏បានទៅវត្តក្រាបទូលរឿងរ៉ាវដល់ព្រះសម្មាសម្ពុទ្ធ ទាំងដែលបរិស័ទកំពុងជួបជុំគ្នាច្រើន។ ព្រះបរមសាស្ដាជ្រាបហើយទ្រង់ត្រាស់ថា : ទុច្ចរិត សូម្បីតិចតួចក៏បុគ្គលមិនគួរធ្វើដែរ កុំអាងថាគ្មានអ្នកណាដឹងនោះ ព្រោះថា វានឹង

ដុតរោលតាមក្រោយ ឯចំណែកសុចរិតវិញ ទោះជាគ្មានគេដឹង ក៏គួរធ្វើ ព្រោះនាំឱ្យមាននូវបាមោជ្ជៈត្រជាក់ចិត្ត រួចហើយទើបត្រាស់នូវព្រះគាថា :

**អកតំ ទុក្កតំ សេយ្យោ  បច្ឆា តប្បតិ ទុក្កតំ**
**កតញ្ច សុកតំ សេយ្យោ  យំ កត្វា នានុតប្បតិ។**

អំពើអាក្រក់ដែលបុគ្គលមិនធ្វើ ប្រសើរជាង ព្រោះថា អំពើអាក្រក់ រមែងធ្វើឱ្យក្តៅក្រហាយ ក្នុងកាលខាងក្រោយ ។ បុគ្គលធ្វើអំពើណាហើយ រមែងមិនក្តៅក្រហាយស្តាយក្រោយ អំពើនោះ ជាអំពើល្អ បើបុគ្គលធ្វើហើយ ឈ្មោះថា បុគ្គលប្រសើរ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ឧបាសកនិងស្ត្រីជាភរិយា បានតាំងនៅក្នុងសោតាបត្តិផល ។ ស្រីបម្រើបានរួចពីភាពជាទាសី ជនទាំងឡាយ បានជួយឱ្យនាងមានប្រក្រតីប្រព្រឹត្តធម៌ ។

**៣៩_ ខណោ មា វោ ឧបច្ចគា**[១] ខណៈចូរកុំកន្លងនូវអ្នកទាំងឡាយឡើយ ។

ព្រះពុទ្ធអង្គ ទ្រង់គង់ប្រថាប់នៅនាព្រះជេតពន ត្រាស់សម្តែងព្រះធម៌ទេសនាដល់ភិក្ខុអាគន្តុកៈច្រើនអង្គ។ ទ្រង់លើកយកពីការរក្សានូវព្រះនគរ មកជាការបញ្ឆាក់ដល់ការរក្សាខ្លួន រួចហើយទើបព្រះអង្គត្រាស់ថា ខណៈចូរកុំកន្លងនូវអ្នកទាំងឡាយឡើយ ។ ខណៈដែលសំខាន់បំផុត គឺ ខណៈដែលបានកើតជួបព្រះសម្មាសម្ពុទ្ធ ឬ ជួបព្រះពុទ្ធសាសនា និង ខណៈបាននូវសម្មាទិដ្ឋិ ព្រមទាំងមាននូវអាយតនៈភ្នែកត្រចៀកជាដើមគ្រប់គ្រាន់ ។

បើបុគ្គលណា មិនគ្រប់គ្រងរក្សាខ្លួន ឱ្យដូចជាគេរក្សានូវព្រះនគរទេ ខណៈរមែងកន្លងនូវបុគ្គលនោះ ។ ការមានសតិរក្សាទ្វារទាំង ៦ មានទ្វារភ្នែកជាដើម ធ្វើឱ្យចិត្តស្ងប់ដូចជាព្រះនគរសុខសាន្ត ឈ្មោះថាបានរក្សាខ្លួនដោយប្រការដូច្នេះឯង ។

---

១_អដ្ឋកថា = **ខណោ វោ មា ឧបច្ចគា** ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ព្រះគាថា :

**នគរំ យថា បច្ចន្តំ គុត្តំ សន្តរពាហិរំ**
**ឯវំ គោបេថ អត្តានំ ខណោ វោ មា ឧបច្ចគា**
**ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។**

នគរនៅទីបំផុតដែន ដែលគេគ្រប់គ្រងហើយ ទាំងខាងក្នុង ទាំងខាងក្រៅ យ៉ាងណា អ្នកទាំងឡាយ គួររក្សាខ្លួន យ៉ាងនោះ កុំឱ្យខណៈកន្លងនូវអ្នកទាំងឡាយ ឡើយ ព្រោះថា ជនទាំងឡាយ ដែលឱ្យខណៈកន្លង ហើយ រមែងសោកសៅក្នុងនរក មីរដេរដាស ។

លុះចប់ព្រះធម៌ទេសនា ភិក្ខុទាំងនោះ តាំងនៅ ក្នុងព្រះអរហត្តផល ។

មនុស្សយើង ប្រសិនបើបានទៅឃើញសត្វនរក ហើយបានដឹងថា សត្វនោះៗ មុននឹងទៅកើតក្នុងនរក ជាបុគ្គលដូចម្តេច ប្រាកដជាគិតថា យើងមិនត្រូវប្រមាទ ឡើយ ។

បិដកលេខ ៥២ ,ទំព័រ ៨៨ ,បន្ទាត់ ៧

**៤០~ ទុស្សីលោ ហិ ពហុជ្ជនោ** ជនទ្រុស្តសីលមានច្រើននាក់ ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅក្រុងកោសម្ពី ទ្រង់ប្រារព្ធព្រះអង្គផ្ទាល់ ដែលពួកមិច្ឆាទិដ្ឋិទ្រុស្តសីល មិនជ្រះថ្លានឹងព្រះរតនត្រ័យ តាមជេរដោយអក្កោសវត្ថុ ១០ នៅក្នុងព្រះនគរ ។ ព្រះអង្គទ្រង់ត្រាស់នឹងព្រះអានន្ទថា ការអត់ធន់ចំពោះពាក្យដែលជនទ្រុស្តសីលដ៏ច្រើនពោល ហើយ ជាភារៈរបស់យើង ។ សេចក្តីនៅក្នុងព្រះគាថា ព្រះអង្គទ្រង់ត្រាស់ថា : តថាគតនឹងអត់ទ្រាំចំពោះពាក្យល្មើស ដូចដំរីអត់ទ្រាំចំពោះព្រួញដែលបាញ់ចេញអំពីធ្នូក្នុងសង្គ្រាមដូច្នោះឯង ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ... ។

បទថា **ទុស្សីលោ ហិ** ដោយសេចក្តីថា ព្រោះលោកិយមហាជននេះ មានចំនួនច្រើន សុទ្ធតែជាបុគ្គលទ្រុស្តសីល ត្រាច់ទៅពោលពាក្យសិកសៀតចាក់ដោតដោយអំណាចនៃកិលេសគ្របសង្កត់ចិត្ត ពោលទៅតាម

ចំណង់របស់ខ្លួន ឯការអត់ធន់ស្ងប់ស្ងៀមព្រងើយចំពោះពាក្យទាំងនោះ ជាភារៈរបស់យើង ។

ព្រះគាថាប្រារព្ធព្រះអង្គផ្ទាល់ :

**អហំ នាគោវ សង្គាមេ ចាបាតោ បតិតំ សរំ**

**អតិវាក្យន្តិតិក្ខិស្សំ ទុស្សីលោ ហិ ពហុជ្ជនោ។**

តថាគតនឹងអត់ទ្រាំនូវពាក្យល្មើស ដូចដំរីដែលអត់ទ្រាំចំពោះព្រួញដែលបាញ់ចេញអំពីធ្នូក្នុងសង្គ្រាមដូច្នោះឯង ព្រោះថា ជនទ្រុស្តសីលមានច្រើននាក់ ។

**ទន្តំ នយន្តិ សមិតឹ ទន្តំ រាជាភិរូហតិ**

**ទន្តោ សេដ្ឋោ មនុស្សេសុ យោតិវាក្យន្តិតិក្ខតិ។**

ពួកជនតែងនាំវាហនៈ ដែលទូន្មានហើយទៅកាន់ទីប្រជុំ ព្រះរាជា ស្តេចឡើងកាន់វាហនៈ ដែលទូន្មានហើយ បណ្តាមនុស្សទាំងឡាយ មនុស្សណា អត់ទ្រាំចំពោះពាក្យល្មើសបាន មនុស្សនោះជាអ្នកមានខ្លួនទូន្មានហើយ ឈ្មោះថាជាបុគ្គលប្រសើរបំផុត ។

បិដកលេខ ៥២ ,ទំព័រ ៩០ ,បន្ទាត់ ២

**៤១. អប្បមាទរតា ហោថ** អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្ដីមិនប្រមាទ ។

ព្រះបរមសាស្ដា កាលដែលទ្រង់គង់ប្រថាប់នៅវត្តជេតពន ព្រះអង្គបានប្រារព្ធដំរីឈ្មោះ បាវេរកៈ ជាដំរីរបស់ព្រះបាទបសេនទិកោសល ។ ដំរីនោះឯងជាប់ភក់ រើខ្លួនមិនរួច នាយហត្ថាចារ្យបានរៀបចំដូចចូលកាន់សមរភូមិក្នុងទីនោះ ហើយឱ្យទូងស្គរចម្បាំងឡើង ។ ដំរីមានជាតិជាប់ដោយមានះ ធ្លាប់ចូលកាន់សមរភូមិប្រយុទ្ធក៏ស្ទុះដោយកម្លាំងចិត្តផ្សំនឹងកម្លាំងកាយ ក៏តាំងនៅលើគោកបាន ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបហេតុការណ៍នោះហើយ ព្រះអង្គទ្រង់ត្រាស់ដាស់តឿនភិក្ខុទាំងឡាយឱ្យរើខ្លួនឡើងចាកភក់ គឺកិលេស ដោយប្រារព្ធសេចក្ដីព្យាយាម ។ ជាបន្តព្រះអង្គទ្រង់ត្រាស់នូវព្រះគាថា :

**អប្បមាទរតា ហោថ សចិត្តមនុរក្ខថ**
**ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ។**

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្ដីមិនប្រមាទ

ចូរតាមរក្សាចិត្តរបស់ខ្លួន ចូររើខ្លួនឡើងចេញចាកភក់គឺកិលេស ដែលឆ្លងបានដោយក្រ ដូចដំរីដែលជាប់នៅក្នុងភក់ ហើយរើខ្លួនរួចបាន ដូច្នោះឯង ។

បទថា **អប្បមាទរតា** ដោយសេចក្តីថា អ្នកទាំងឡាយចូរត្រេកអរក្នុងការនៅមិន ប្រាសចាកសតិ ។

បទថា **សចិត្តំ** ដោយសេចក្តីថា ចូររក្សាចិត្តរបស់ខ្លួនក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម មិនឱ្យរូបជាដើមនោះ គ្របសង្កត់ចិត្តបាន ។

បទថា **សន្នោ** ដោយសេចក្តីថា ដំរីព្យាយាមរើខ្លួនចាកភក់ ហើយតាំងនៅលើគោក យ៉ាងណា អ្នកទាំងឡាយ ចូររើខ្លួនចាកភក់គឺកិលេស ហើយតាំងនៅលើគោកគឺព្រះនិព្វាន ក៏យ៉ាងនោះដែរ ។

កាលចប់ព្រះធម៌ទេសនា ភិក្ខុទាំងនោះបានតាំងនៅក្នុងព្រះអរហត្តផល ។

បិដកលេខ ៥២ ,ទំព័រ ៩១ ,បន្ទាត់ ៤

**៤២~ បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ** បុណ្យនាំសេចក្ដីសុខមកឱ្យក្នុងកាលអស់ជីវិត ។

ព្រះបរមសាស្ដា កាលដែលទ្រង់គង់ប្រថាប់ក្នុងព្រះគន្ធកុដិ នាដែនដីនៃព្រៃហិមពាន្ត ព្រះអង្គទ្រង់ប្រារព្ធមារាធិរាជ ។ ក្នុងកាលនោះ មារបានមកអារាធនាសូមឱ្យព្រះអង្គត្រឡប់ទៅគ្រប់គ្រងរាជសម្បត្តិវិញ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ទៅកាន់មារថា ភ្នំមាស ២ ក៏មិនអាចធ្វើឱ្យបុគ្គលម្នាក់គ្រប់គ្រាន់បានដែរ បុគ្គលជ្រាបដូច្នេះហើយ គប្បីប្រព្រឹត្តធម៌សន្ដោស ដូច្នេះជាដើម ។

ជាបន្ត ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថា :

**អត្ថម្ហិ ជាតម្ហិ សុខា សហាយា**
**តុដ្ឋី សុខា យា ឥតរីតរេន**
**បុញ្ញំ សុខំ ជីវិតសង្ខយម្ហិ**
**សព្វស្ស ទុក្ខស្ស សុខំ បហានំ។**

កាលបើសេចក្ដីត្រូវការកើតឡើងហើយ សម្លាញ់ទាំងឡាយនាំសេចក្ដីសុខមកឱ្យ សេចក្ដីត្រេកអរដោយ

បច្ច័យ តាមមានតាមបាន ជាហេតុនាំសេចក្តីសុខមកឱ្យ បុណ្យនាំសេចក្តីសុខមកឱ្យក្នុងកាលអស់ជីវិត ការលះបង់ទុក្ខទាំងអស់បាន ជាហេតុនាំសេចក្តីសុខមកឱ្យ ។

**សុខា មត្តេយ្យតា លោកេ  អថោ បេត្តេយ្យតា សុខា**
**សុខា សាមញ្ញតា លោកេ  អថោ ព្រហ្មញ្ញតា សុខា**
**សុខំ យាវ ជរា សីលំ  សុខា សទ្ធា បតិដ្ឋិតា**
**សុខោ បញ្ញាបដិលាភោ  បាបានំ អករណំ សុខំ។**

ការប្រតិបត្តិល្អដល់មាតា នាំសេចក្តីសុខមកឱ្យក្នុងលោក ម្យ៉ាងទៀត ការប្រតិបត្តិល្អដល់បិតា នាំសេចក្តីសុខមកឱ្យ ។ ការប្រតិបត្តិល្អដល់សមណៈ នាំសេចក្តីសុខមកឱ្យក្នុងលោក ម្យ៉ាងទៀតការប្រតិបត្តិល្អដល់ព្រាហ្មណ៍ (អ្នកដែលមានបាបបណ្តែតចោលហើយ ) នាំសេចក្តីសុខមកឱ្យ ។ សីលនាំសេចក្តីសុខមកឱ្យដរាបដល់ចាស់ សទ្ធាដែលបុគ្គលតម្កល់ស៊ប់ហើយ នាំសេចក្តីសុខមកឱ្យ ការបានចំពោះនូវបញ្ញា នាំសេចក្តីសុខមកឱ្យ ការមិនធ្វើបាបទាំងឡាយ នាំសេចក្តីសុខមកឱ្យ ។

បិដកលេខ ៥២ ,ទំព័រ ៩៦ ,បន្ទាត់ ១១

**៤៣. សព្វទានំ ធម្មទានំ ជិនាតិ** ធម្មទានឈ្នះទានទាំងពួង ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ទ្រង់ប្រារព្ធសក្កទេវរាជ។ សក្កទេវរាជបាននាំទេវតាក្នុងម៉ឺនចក្កវាឡ មកទូលសួរបញ្ហាព្រះធម៌ ដោយពួកទេវតាទាំងនោះមិនអាចដោះស្រាយបាន អស់រយៈពេល ១២ ឆ្នាំ ។ ឯបញ្ហាមាន ៤ ចំណុចគឺសួរថា : បណ្តាទានទាំងឡាយ ទានបែបណា បណ្ឌិតពោលថាប្រសើរជាង ? ដូច្នេះជាដើម ។

សម្តេចព្រះទ្រង់ញាណ ទ្រង់ត្រាស់ថា សាធុ ! សាធុ ! មហាបពិត្រ :

១. បណ្តាទានទាំងឡាយ ធម្មទានប្រសើរជាង ។

២. បណ្តារសទាំងឡាយ ធម្មរសជាកំពូលនៃរស។

៣. បណ្តាសេចក្តីត្រេកអរទាំងឡាយ សេចក្តីត្រេកអរក្នុងធម៌ប្រសើរក្រៃលែង ។

៤. ចំណែកការអស់ទៅនៃតណ្ហា ប្រសើរជាទី

បំផុត ព្រោះជាហេតុឱ្យបុគ្គលសម្រេចនូវព្រះអរហត្ត ។ ត្រាស់ស្រេចហើយ ទ្រង់ត្រាស់សម្ដែងនូវព្រះគាថា :

**សព្វទានំ ធម្មទានំ ជិនាតិ** ធម្មទាន ឈ្នះទាន ទាំងពួង ។

**សព្វរសំ ធម្មរសោ ជិនាតិ** ធម្មរស ឈ្នះរស ទាំងពួង ។

**សព្វរតឹ ធម្មរតិ ជិនាតិ** សេចក្ដីត្រេកអរក្នុង ធម៌ ឈ្នះសេចក្ដីត្រេកអរទាំងពួង ។

**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ** ការអស់តណ្ហា ឈ្នះទុក្ខទាំងពួង ។

លុះចប់ព្រះគាថា ទេវតាបានសម្រេចមគ្គផលជាច្រើនម៉ឺនអង្គ ។ កាលសក្កទេវរាជសូមពរ ព្រះលោកនាថទ្រង់ត្រាស់ដល់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយសម្ដែងធម៌ក្ដី ស្ដាប់ធម៌ក្ដី គប្បីចែកចំណែកបុណ្យធម្មទានដល់សព្វសត្វ មានទេវតាជាដើមផង ។

**៤៤~ ហនន្តិ ភោគា ទុម្មេធំ** ភោគៈទាំងឡាយរមែងសម្លាប់បុគ្គលមិនមានបញ្ញា ។

ព្រះបរមសាស្តា កាលទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ព្រះអង្គបានប្រារព្ធនូវអបុត្តក-សេដ្ឋី ។ សេដ្ឋីនេះគាត់អត់មានបុត្រ ហើយកំណាញ់ដ៏ក្រៃលែង ។ ដែលគាត់អត់មានបុត្រ ព្រោះបុព្វកម្មសម្លាប់ក្មួយដណ្តើមទ្រព្យសម្បត្តិ ។ គាត់បានជាសេដ្ឋី ព្រោះបានថ្វាយទានដល់ព្រះបច្ចេកពុទ្ធព្រះនាម តគរសិខី ។ ជាសេដ្ឋីកំណាញ់ ព្រោះថ្វាយទានហើយស្តាយក្រោយ ។ កាលពីបានថ្វាយទានដល់ព្រះបច្ចេកពុទ្ធហើយ គាត់ទៅកើតនៅទេវលោកអស់ ៧ ដង ជាសេដ្ឋីនៅក្រុងសាវត្ថី ៧ ដង ។ ជាសេដ្ឋីលើកទី ៧ នេះឯង ដែលគាត់ស្លាប់ទៅធ្លាក់រោរុវនរក ព្រោះបុព្វកម្មសម្លាប់ក្មួយពីជាតិមុន ទើបតែឱ្យផល ។ ទ្រព្យសម្បត្តិអបុត្តកសេដ្ឋី ត្រូវព្រះបាទ-បសេនទិកោសល ឱ្យដឹកជញ្ជូនចូលព្រះរាជឃ្លាំងអស់រយៈពេល ៧ ថ្ងៃ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ៖

**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**
**ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ។**

ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលមិនមានបញ្ញា ប៉ុន្តែមិនសម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះ-និព្វានឡើយ បុគ្គលដែលអត់បញ្ញា រមែងសម្លាប់ខ្លួនឯងព្រោះអាស្រ័យតណ្ហាក្នុងភោគៈ ។

បាទព្រះគាថា **ហន្តិ អញ្ញេវ អត្តនំ** ដោយសេចក្តីថា បុគ្គលដែលមិនមានបញ្ញា រមែងសម្លាប់ខ្លួនឯងដូចសម្លាប់អ្នកដទៃ ព្រោះអាស្រ័យតណ្ហាក្នុងភោគៈទាំងឡាយ ។

អបុត្តកសេដ្ឋីសម្លាប់អ្នកដទៃព្រោះទ្រព្យយ៉ាងណា ឈ្មោះថា សម្លាប់ខ្លួនឯងក្នុងវដ្តសង្សារ យ៉ាងនោះ ។

បិដកលេខ ៥២ ,ទំព័រ ៩៩ ,បន្ទាត់ ៦

## ៤៥~ សព្វសោ នាមរូបស្មឹ...។

**សព្វសោ នាមរូបស្មឹ យស្ស នត្ថិ មមាយិតំ**
**អសតា ច ន សោចតិ ស វេ ភិក្ខូតិ វុច្ចតិ ។**

បុគ្គលណាមិនមានសេចក្តីប្រកាន់ក្នុងនាមរូប ថាជារបស់អញ ដោយប្រការទាំងពួង មួយទៀតបុគ្គលណាមិនសោកសៅ ព្រោះនាមរូបដែលមិនមាន បុគ្គលនោះឯង តថាគតហៅថា ភិក្ខុ ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ព្រះអង្គបានប្រារព្ធព្រាហ្មណ៍ម្នាក់ ។ ព្រាហ្មណ៍នេះ កាលដែលមិនទាន់បានឱ្យទាន រមែងមិនបរិភោគខ្លួនឯងឡើយ ។

ពេលមួយ ព្រាហ្មណ៍កំពុងបរិភោគបានពាក់កណ្តាល ព្រះបរមសាស្តាស្តេចយាងទៅបិណ្ឌបាត ។ ព្រាហ្មណ៍បានថ្វាយភត្តដល់ព្រះពុទ្ធអង្គ ដោយពោលថា បពិត្រ ព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គថ្វាយអគ្គទានក្នុងពេលទាំង ៥ ហើយ ទើបបរិភោគ ប៉ុន្តែឥឡូវនេះ ខ្ញុំ-

ព្រះអង្គមានភត្តពាក់កណ្តាលចាកពីបរិភោគ សូមព្រះអង្គទ្រង់មេត្តាប្រោសទទួលនូវភត្តនេះរបស់ខ្ញុំព្រះអង្គ ។

ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ ចំណែកដ៏ប្រសើរលើសក្តី ភត្តដែលសល់ពីអ្នកបរិភោគក្តី ជារបស់សមគួរដល់តថាគតទាំងអស់ ម្នាលព្រាហ្មណ៍ អ្នកបួសដូចតថាគត ជាអ្នកអាស្រ័យអាហារដែលអ្នកដទៃឱ្យដើម្បីចិញ្ចឹមជីវិត ដូចជាពួកប្រេតដែរ ។

ព្រាហ្មណ៍បានស្តាប់ព្រះពុទ្ធដីកាហើយ មានចិត្តជ្រះថ្លាដ៏ក្រៃលែង បានទូលសួរថា ព្រះអង្គត្រាស់ហៅសាវ័ករបស់ព្រះអង្គថា ភិក្ខុ ដោយហេតុដូចម្តេច ?

ព្រះអង្គទ្រង់ជ្រាបឧបនិស្ស័យរបស់ព្រាហ្មណ៍ ត្រាស់នូវព្រះគាថា **សព្វសោ នាមរូបស្មឹ...** ធ្វើឱ្យព្រាហ្មណ៍ពីរនាក់ប្តីប្រពន្ធសម្រេចអនាគាមិផល ។

## ៨៦_ មេត្តាវិហារី យោ ភិក្ខុ...។

**មេត្តាវិហារី យោ ភិក្ខុ      បសន្នោ ពុទ្ធសាសនេ**
**អធិគច្ឆេ បទំ សន្តំ         សង្ខារូបសមំ សុខំ ។**

ភិក្ខុណា មានប្រក្រតីនៅដោយមេត្តា ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះ រមែងបានដល់នូវសន្តិបទ ជាសុខ ព្រោះរំងាប់នូវសង្ខារ ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ព្រះអង្គទ្រង់ប្រារព្ធភិក្ខុច្រើនអង្គ ។ ភិក្ខុទាំងអស់នោះ មុននឹងបួសគឺជាក្រុមចោរដ៏ធំមួយមានគ្នា ៩០០ នាក់ ។

ដំណើររឿង មានលំដាប់លំដោយពីព្រះសោណកុដិកណ្ណត្ថេរ ។ ព្រះថេរៈបានសូត្រធម៌ ១៦ សូត្រ ដោយបទសរភញ្ញ ថ្វាយព្រះដ៏មានព្រះភាគ ក្នុងព្រះគន្ធកុដិនាវត្តជេតពន ។ ព្រះដ៏មានព្រះភាគ ទ្រង់អនុមោទនាជាពិសេស ទើបបានប្រទានសាធុការថា សាធុ ! សាធុ ! ម្នាលភិក្ខុ ប្រពៃណាស់ៗ ។ ក្នុងកាលនោះ សំឡេង

សាធុការនៃទេវតា ក៏បានលាន់ឡើងតៗគ្នា រហូតដល់ព្រហ្មលោក ។ ចំណែកទេវតានៅនឹងផ្ទះញោមស្រីរបស់ព្រះសោណកុដិកណ្ណត្ថេរ ក្នុងកុររឃរនគរប្រមាណ ១២០ យោជន៍ពីវត្តជេតពន ក៏បានប្រទានសាធុការផងដែរ ។ ញោមឧបាសិកា កាលដែលបានជ្រាបថា ព្រះបរមសាស្តាព្រមដោយទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម ប្រទានសាធុការដល់បុត្ររបស់ខ្លួន ក៏មានបីតិផ្សាយទៅពេញសរីរៈ ថ្ងៃក្រោយបាននិមន្តព្រះថេរៈសម្តែងព្រះធម៌ នៅក្នុងកុររឃរនគរ ។ កាលនោះឯង ពួកចោរទាំង ៩០០ នាក់ បានស្តាប់ព្រះធម៌ ដែលព្រះថេរៈសម្តែង លះបង់ចោរកម្មមកបួសក្នុងព្រះពុទ្ធសាសនា ប្រព្រឹត្តសមណធម៌លើកំពូលភ្នំមួយ ។ ព្រះដ៏មានព្រះភាគទ្រង់ប្រទានព្រះធម៌ទេសនា មានជាអាទិ៍ថា **មេត្តាវិហារី យោ ភិក្ខុ...** ញ៉ាំងភិក្ខុទាំងអស់នោះ ឱ្យតាំងនៅក្នុងអរហត្តផល ។

បិដកលេខ ៥២ ,ទំព័រ ១០១ ,បន្ទាត់ ៦

**៤៧ ~ អត្តនា ចោទយត្តានំ** អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ព្រះអង្គប្រារព្ធព្រះនង្គលកូដត្ថេរ ។ ព្រះថេរៈមុននឹងបួសគឺជាអ្នកក្រទ្រព្យម្នាក់ ស៊ីឈ្នួលភ្ជួរស្រែឱ្យគេ ក្រោយមកបានជួបព្រះភិក្ខុមួយអង្គនាំមកបួសក្នុងព្រះពុទ្ធសាសនា ។ ក្នុងកាលដែលមកបួស បានទុកនង្គ័ល និង សំពត់ចាស់ដែលខ្លួនស្លៀកនៅនឹងមែកឈើនាគុម្ពព្រៃមួយកន្លែង ។ ក្រោយមកលោកអផ្សុកចង់សឹកបាននិមន្តទៅកាន់ទីដែលទុកនង្គ័ល ហើយឱ្យឱវាទខ្លួនឯងថា អ្នកឯងមិនមានហិរិ មិនចេះខ្មាសបាប អ្នកឯងចង់មកស្លៀកសំពត់រឹងៗនេះ ទៅស៊ីឈ្នួលភ្ជួរស្រែឱ្យគេទៀតឬ ។ កាលដែលបានដាស់តឿនខ្លួនឯងយ៉ាងនេះហើយក៏បានធូរស្រាលក្នុងចិត្តលែងចង់សឹកទៅ ។ លោកតែងតែនិមន្តទៅឱ្យឱវាទខ្លួនឯងរឿយៗ ក្នុងទីទុកនង្គ័លនោះនៅពេលចង់សឹកម្តងៗ លោកទុកទីនោះជាសម្នាក់អាចារ្យ

របស់លោក ក្រោយមកលោកក៏បានសម្រេចព្រះអរហត្ត ជាព្រះអរហន្តមួយអង្គ ។

ព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធសេចក្តីនោះ ទើបត្រាស់សម្តែងពីរព្រះគាថា :

**អត្តនា ចោទយត្តានំ　　បដិមំសេតមត្តនា**
**សោ អត្តគុត្តោ សតិមា　សុខំ ភិក្ខុ វិហាហិសិ។**
**អត្តា ហិ អត្តនោ នាថោ អត្តា ហិ អត្តនោ គតិ**
**តស្មា សញ្ញម អត្តានំ　　អស្សំ ភទ្រំវ វាណិជោ។**

អ្នកចូរដាស់តឿនខ្លួនដោយខ្លួនឯង ចូរពិចារណាខ្លួនដោយខ្លួនឯង ភិក្ខុនោះឯងមានស្មារតី រក្សាខ្លួនទុកហើយ នឹងនៅជាសុខ ។ មែនពិត ខ្លួនជាទីពឹងរបស់ខ្លួន ខ្លួនជាគតិរបស់ខ្លួន ព្រោះហេតុនោះ អ្នកចូរស្ងួនគ្រងរក្សានូវខ្លួន ដូចនាយពាណិជស្ងួនគ្រងរក្សានូវសេះដ៏ល្អដូច្នោះឯង ។

បិដកលេខ ៥២ ,ទំព័រ ១០១ ,បន្ទាត់ ១០

## ៤៨~ បាមោជ្ជពហុលោ ភិក្ខុ ...។

បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ
អធិគច្ឆេ បទំ សន្តំ សង្ខារូបសមំ សុខំ ។

ភិក្ខុដែលច្រើនទៅដោយសេចក្តីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា រមែងបាននូវបទដ៏ស្ងប់ ជាទីរំងាប់នូវសង្ខារ នាំមកនូវសេចក្តីសុខ ។

ព្រះបរមសាស្តា កាលដែលទ្រង់គង់ប្រថាប់នៅនាមហាវិហារវេឡុវ័ន ព្រះអង្គទ្រង់បានត្រាស់ប្រារព្ធព្រះ-វក្កលិត្ថេរ ។ ព្រះថេរៈអង្គនេះ កើតក្នុងត្រកូលព្រាហ្មណ៍នាក្រុងសាវត្ថី លុះដល់ចម្រើនវ័យ បានឃើញព្រះសម្មា-សម្ពុទ្ធ ក៏ចូលកាន់ផ្នួសក្នុងបំណងគន់មើលនូវព្រះសិរីរៈរបស់ព្រះអង្គ ។ ព្រះបរមសាស្តារង់ចាំឱ្យញាណរបស់លោកចាស់ក្លា ទើបព្រះអង្គត្រាស់ថា ម្នាលវក្កលិប្រយោជន៍អ្វីដល់អ្នក ក្នុងការមើលកាយស្អុយនេះ ម្នាលវក្កលិ បុគ្គលណា ឃើញធម៌ បុគ្គលនោះ ឃើញតថាគតបុគ្គលណា ឃើញតថាគត បុគ្គលនោះ ឃើញធម៌ ។

វក្កលិអ្នកចូរចេញទៅ ។ ព្រះវក្កលិត្ថេរគិតថា បើមិនបាន
ឃើញព្រះបរមសាស្តា តើប្រយោជន៍អ្វីដោយការរស់នៅ
គិតហើយ លោកបានចេញពីវត្តទៅឡើងភ្នំគិជ្ឈកូដ ដើម្បី
លោតសម្លាប់ខ្លួន ។ ព្រះលោកនាថ ទ្រង់ផ្សាយព្រះរស្មី
ដើម្បីឱ្យព្រះថេរៈឃើញព្រះអង្គ ព្រះថេរៈឃើញហើយ ក៏
បាត់អស់នូវសេចក្តីសោកសៅ ដូចជាស្រះដែលរីងស្ងួត
ហើយ ស្រាប់តែមានភ្លៀងធ្វើឱ្យស្រះពេញដោយទឹក ។
ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវព្រះគាថា **បាមោជ្ជ-
ពហុលោ ភិក្ខុ** ជាដើម រួចហើយទ្រង់ត្រាស់ហៅ
ព្រះវក្កលិ ។ ព្រះថេរៈអណ្តែតទៅឰដ៏អាកាស នឹកដល់
ព្រះគាថា ក៏បានសម្រេចព្រះអរហត្ត ព្រមដោយបដិ-
សម្ភិទា ចុះមកថ្វាយបង្គំព្រះបរមសាស្តា ព្រះអង្គទ្រង់
ស្ថាបនាក្នុងតំណែងឯតទគ្គៈខាងសទ្ធាធិមុត្ត ។

## ៤៩~ ឆិន្ទ សោតំ បរក្កម្ម...។

ឆិន្ទ សោតំ បរក្កម្ម កាមេ បនូទ ព្រាហ្មណ
សង្ខារានំ ខយំ ញត្វា អកតញ្ញូសិ ព្រាហ្មណ។

ម្នាលព្រាហ្មណ៍ អ្នកចូរខំប្រឹងកាត់តណ្ហាដូចខ្សែទឹក ចូរបន្ទោបង់កាមទាំងឡាយចេញ ម្នាលព្រាហ្មណ៍ អ្នកដឹងច្បាស់នូវការអស់សង្ខារទាំងឡាយហើយ ឈ្មោះថាជាអ្នកដឹងនូវព្រះនិព្វាន ដែលបច្ច័យតាក់តែងមិនបាន។

ព្រះបរមសាស្តា ទ្រង់គង់ប្រថាប់នៅនាមហាវិហារព្រះជេតពន ព្រះអង្គទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ដែលមានសេចក្តីជ្រះថ្លាខ្លាំង ។ ព្រាហ្មណ៍នោះឯង ស្តាប់ព្រះធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធហើយ ក៏មានសេចក្តីជ្រះថ្លាធ្វើនិច្ចភត្តថ្វាយសង្ឃមានភិក្ខុ ១៦ អង្គនៅផ្ទះរបស់ខ្លួន ។ នៅពេលព្រះភិក្ខុនិមន្តមក គាត់បានពោលថា សូមព្រះអរហន្តទាំងឡាយដ៏ចម្រើននិមន្តមក សូមព្រះអរហន្តនិមន្តអង្គុយ ដូច្នេះជាដើម ។

ភិក្ខុទាំងអស់នោះ មានសេចក្តីរង្កៀស ហើយមិន

ទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះទៀតឡើយ ។ ព្រាហ្មណ៍កើតទុក្ខខ្វល់ចិត្ត ទៅកាន់មហាវិហារ ថ្វាយបង្គំព្រះសាស្ដា ក្រាបទូលសេចក្ដីនោះដល់ព្រះអង្គ ។ ព្រះបរមសាស្ដា ប្រជុំភិក្ខុសង្ឃត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ តើពួកអ្នកមានការត្រេកអរនឹងពាក្យព្រាហ្មណ៍ដែលហៅពួកអ្នកថាជាព្រះអរហន្តទេ ? កាលដែលពួកភិក្ខុក្រាបទូលថា ពួកខ្ញុំព្រះអង្គមិនត្រេកអរហើយ ទើបព្រះសុគតសាស្ដា ត្រាស់ថា សេចក្ដីជ្រះថ្លាក្នុងព្រះអរហន្តទាំងឡាយ មានក្នុងសន្តានចិត្តព្រាហ្មណ៍ច្រើនដ៏ក្រៃលែង ព្រោះហេតុនោះ ពួកអ្នកទាំងឡាយគប្បីកាត់ខ្សែតណ្ហា ហើយសម្រេចជាព្រះអរហន្ត ទើបជាការគួរ ។ រួចហើយព្រះសុគតសាស្ដា ទ្រង់ត្រាស់ព្រះគាថា **ឆិន្ទ សោតំ បរក្កម្ម** ដូច្នេះជាដើម ។

បិដកលេខ ៥២ ,ទំព័រ ១០៣ ,បន្ទាត់ ២

## ៥០. ទិវា តបតិ អាទិច្ចោ...។

**ទិវា តបតិ អាទិច្ចោ     រត្តិមាភាតិ ចន្ទិមា**

**សន្នទ្ធោ ខត្តិយោ តបតិ     ឈាយី តបតិ ព្រាហ្មណោ**

**អថ សព្វមហោរត្តឹ     ពុទ្ធោ តបតិ តេជសា។**

ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទរុងរឿងក្នុងវេលាយប់ ក្សត្រទ្រង់ប្រដាប់ពេញយសហើយ រមែងរុងរឿង សមណព្រាហ្មណ៍អ្នកមានឈាន រមែងរុងរឿង ចំណែកព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងដោយតេជះរហូតថ្ងៃនិងយប់គ្រប់វេលា ។

ព្រះបរមសាស្តា កាលដែលទ្រង់គង់នៅក្នុងប្រាសាទរបស់ឧបាសិកាឈ្មោះមិគារមាតា ព្រះអង្គបានប្រារព្ធព្រះអានន្ទត្ថេរ ។ ព្រះអានន្ទ បានពោលសរសើរព្រះរស្មីនៃព្រះសម្មាសម្ពុទ្ធ ក្នុងថ្ងៃនោះជាថ្ងៃមហាបវារណា ព្រះអាទិត្យកំពុងអស្តង្គត ព្រះចន្ទកំពុងរះ ក្នុងកាលនោះ ព្រះបាទបសេនទិកោសល ទ្រង់គ្រឿងឥស្សរិយាភរណៈស្តេចយាងមកកាន់ព្រះវិហារ រីឯព្រះកាឡុទាយិត្ថេរ

កំពុងគង់ចូលឈានទៅខាងចុងនៃបរិស័ទ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវព្រះគាថា **ទិវា តបតិ អាទិច្ចោ** ដូច្នេះជាដើម ។

បទថា **តេជសា** គឺថា ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងដោយតេជះ ៥ យ៉ាង,១-តេជះនៃសីល,២-តេជះនៃគុណ, ៣-តេជះនៃបញ្ញា, ៤-តេជះនៃបុណ្យ[១] និង ៥-តេជះនៃធម៌ ។

## តេជះព្រះពុទ្ធ

ព្រះសុរិយារុងរឿងពេលថ្ងៃ ចន្ទពេញបូណ៌មីរុងរឿងពេលយប់
ក្សត្រទ្រង់គ្រឿងរាជ្យរុងរឿងនរបតី អ្នកចូលឈានគ្រប់រុងរឿងសាស្ដា ។
ព្រះពុទ្ធរុងរឿងដោយតេជះបុណ្យ តេជះនៃគុណតេជះសីលា
តេជះព្រះធម៌តេជះបញ្ញា រុងរឿងអស្ចារ្យទាំងយប់ទាំងថ្ងៃ ។

ដោយ **ប. ស. ទ.**

---

១. បុណ្យដែលព្រះអង្គទ្រង់បំពេញមកហើយ គឺព្រះដ៏មានបុណ្យ។

## ៥១~ បំសុកូ្លធរំ ជន្តុំ...។

**បំសុកូ្លធរំ ជន្តុំ កិសន្ធមនិសន្ថតំ**
**ឯកំ វនស្មឹ ឈាយន្តំ តមហំ ព្រូមិ ព្រាហ្មណំ។**

តថាគត ហៅបុគ្គលអ្នកទ្រទ្រង់សំពត់បង្សុកូល មានកាយស្គម មានខ្លួនរវាមដោយសរសៃ ជាបុគ្គលម្នាក់ឯងចម្រើនឈានក្នុងព្រៃនោះ ថាជាព្រាហ្មណ៍ ។

ព្រះបរមសាស្តា ទ្រង់គង់នៅលើកំពូលភ្នំគិជ្ឈកូដ ទ្រង់ប្រារព្ធព្រះនាងកិសាគោតមីថេរី ។

ក្នុងកាលនោះ សក្កទេវរាជចុះមកគាល់ព្រះពុទ្ធបរមគ្រូ ព្រមដោយទេវបរិស័ទ ក្នុងទីបំផុតនៃបឋមយាមនៃរាត្រី ស្តាប់ព្រះធម្មកថាដែលជាទីតាំងនៃស្មារតី ។ ក្នុងខណៈនោះ ព្រះនាងកិសាគោតមីថេរីគិតថា យើងនឹងគាល់ព្រះបរមសាស្តា ហើយក៏ហោះមកតាមផ្លូវអាកាស ឃើញសក្កទេវរាជ ព្រមទាំងទេវបរិស័ទ ទើបថ្វាយបង្គំព្រះបរមសាស្តាពីចម្ងាយ រួចត្រឡប់ទៅវិញ។ សក្កទេវ-រាជទតព្រះនេត្រឃើញព្រះថេរីថ្វាយបង្គំ ហើយត្រឡប់

ទៅវិញ ក៏ទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនីឈ្មោះអ្វី ? បានមកឃើញនិងថ្វាយបង្គំព្រះអង្គហើយ ក៏ត្រឡប់ទៅវិញភ្លាម ។

ព្រះបរមសាស្ដា ត្រាស់តបថា មហាបពិត្រ ភិក្ខុនីនោះ ឈ្មោះកិសាគោតមី ជាធីតារបស់តថាគត ជាកំពូលនៃព្រះថេរី អ្នកទ្រទ្រង់ចីវរបង្សុកូលទាំងឡាយ ។ រួចហើយទ្រង់ត្រាស់នូវព្រះគាថាបន្តថា **បំសុកូលធរំ ជន្តុំ** ដូច្នេះជាដើម ។

កិសាគោតមីស្រីមានបុណ្យ សន្សំសាងគុណពីបុព្វេ
បុណ្យនាំជួបព្រះឥតងាករេ សាងផ្នួសលះស្នេហ៍បែររកត្រើយ ។
ជីវិតមុនបួសរស់ស្រួលដែរ ប៉ុន្តែមិនទៀងទុក្ខឥតស្បើយ
មានជួបមានព្រាត់លាឱ្យហើយ ប្រញាប់រកត្រើយទីពឹងពិត ។

**សូមអនុមោទនា !**



# កាលមុនខ្ញុំក៏ដូចអ្នកដែរ

សុភាពបុរសកំលោះសង្ហា ជាទីប្រាថ្នានៃស្រីទាំងឡាយ
ក្រមុំគ្រប់លក្ខណ៍ល្អភក្ត្រល្អកាយ បុរសទាំងឡាយតែងតែប្រាថ្នា ។
ចំពោះអ្នកដែលសង្រួមឥន្ទ្រិយ៍ ជាន់ឈ្លីអវិជ្ជាចេញពីចិន្តា
គឺជាអ្នកញ៉ាំងសេចក្ដីជ្រះថ្លា ដល់ជនគ្រប់គ្នាទាំងអស់ទូទៅ ។
បណ្ឌិតឥតគិតបៀតបៀនអ្នកណា ឆ្លាំឆ្លងម្ដេចម្ដាជួយប្រាប់តម្រូវ
តែងមានមេត្តាដល់ជនទូទៅ គោរពម៉ែឪចិញ្ចឹមថ្នមថៃ ។
ឆ្អឹងខ្មោចសាកសពបុរសស្ត្រី ហាក់ដូចស្រដីទាំងយំត្អូញត្អែរ
ថាកាលមុនខ្ញុំ ក៏ដូចអ្នកដែរ អ្នកក៏គង់តែ ដូចខ្ញុំដែរទេ ។
ដំបូលគ្មាន ទ សម្រាប់ត្រងទឹក ភ្លៀងធ្លាក់សន្ធឹកពាងទឹកទំនេរ
ដំបូលមាន ទ ទឹកច្រើនជាងគេ កម្លាំងខ្លាំងទេ្វចូលពាងឥតខ្វល់ ។
យ៉ាងណាចិត្តឥតបានប្រមូលផ្ដុំ ឱ្យមកប្រជុំលើបុណ្យកុសល
ចិត្តនោះបែងចែកបែកច្រើនកិច្ចកល តាមអកុសល ងងុលឥតស្វាង ។
បើចិត្តផ្ដុំគ្នាសទ្ធាតាំងមាំ សតិឆ្ពោះចំកុសលតែម្យ៉ាង
កម្លាំងបុណ្យខ្លាំងតាំងជាតំណាង បញ្ញាភ្លឺស្វាងសាងសុខសិរី ។
មាសប្រាក់ចាយបានពេលមានជីវិត បុណ្យកុសលពិតស្លាប់រស់មិនថ្វី
បុណ្យតែងទ្រទ្រង់ឱ្យផុតទុក្ខភ័យ ឆ្លងគ្រោះភពត្រៃក្នុងវដ្តសង្សារ ។

ដោយឧបាសក **គុយ សុធន**

# ស្ពានតែចិត្តស្មោះ

គេងគិតកើយដៃរីងរៃឱរា　　ព្រោះក្ដីប្រាថ្នាត្រូវរលាយអស់
មេឃមីរស្រទំគេងយំស្រណោះ　បាត់បង់សម្រស់ព្រោះព្រាត់គូស្នេហ៍ ។
ស្និទ្ធស្នាលស្នេហ៍ស្នងសាសងសម្ដី　ពាក្យពេចន៍វែងខ្លីក្រោមពន្លឺខែ
នឹកស្មានថាស្មោះស្ម័គ្រឥតកែប្រែ　មិនស្មានចិត្តស្នេហ៍ប្រួលប្រែសាមាន្យ ។
រឿងគេក្បត់ចិត្តមិនត្រូវគិតខ្លី　រឿងគេមានថ្មីមិនគួរបោកប្រាណ
កំលោះពេញឃុំក្រមុំរកបាន　ស្ម័គ្រស្មោះកុំស្មានឱ្យរំខានចិត្ត ។
បើស្នេហ៍ចិត្តវេឱ្យគេទៅចុះ　ថ្ងៃក្រោយនាំខុសបើគេមិនគិត
បានស្គាល់ប៉ុណ្ណឹងបានដឹងគំនិត　រក្សាជីវិតគិតដល់សុខភាព ។
ព្រៃឈើណែនខ្នាប់ត្រូវកាប់រំលស់　បើកាប់ដើមខ្ពស់ត្រូវបាក់ដើមទាប
បើកាប់ដើមតូចត្រូវខូចខាតលាភ　ត្រូវកាប់ស្ទង់ស្ទាប ម្ដងមួយៗ ។
បើនៅក្នុងផ្ទះថ្ងៃរះចូលរួច　ត្រូវបិទបង្អួចរួចហើយកុំព្រួយ
បើក្លិនមិនល្អដោយស្មៅរលួយ　បិទទ្វារនោះមួយជួយដោះបញ្ហា ។
ដោះការថ្ពាំងថ្នាក់ធ្លាក់រចនាចិត្ត　ធ្លាក់ដោយកាំបិតមុតគឺបញ្ញា
ធ្លាក់ម្ដងបន្តិចតែដោយឧស្សាហ៍　ដោយក្ដីជ្រះថ្លាសម្មាទិដ្ឋិ ។

ដោយឧបាសក **គុយ សុធន**

# សរសើរឬកកិលេស

ពេលមួបត្រជាក់លះបង់ទីណា កម្តៅសុរិយាផ្សាយឥតស្រណោះ
បីតិស្ងប់ស្ងាត់រសាត់បាត់អស់ ទោមនស្សកើតមកភ្លាមមួយរំពេច ។
បើសេចក្តីសុខកាន់តែកើនឡើង រវល់ត្រូវស្តើងនៅកាន់តែតិច
បើសេចក្តីសុខកើនឡើងជានិច្ច សម្ភារៈរេចកាន់តែតិចទៅ ។
ព្រោះសម្ភារៈគឺជាឫសគល់ នាំឱ្យរវល់អំពល់ជាប់នៅ
កង្វល់នឹងទ្រព្យជាប់ដល់យប់ជ្រៅ មុនគេងលក់ទៅក៏នៅអាល័យ ។
ព្រះអង្គុលីមាលគឺជាមហា ឃាតកប្រហារសាហាវពេកក្រៃ
សម្លាប់ទាំងយប់សម្លាប់ទាំងថ្ងៃ កាត់រាប់ម្រាមដៃដោតជាកម្រង ។
ព្រះនាងបដាចារវិកលស្មារតី ព្រោះស្លាប់កូនប្តីម៉ែឪនិងបង
នៅតែព្រះធម៌អាចជួយចម្លង ទាំងពីរឱ្យឆ្លងផុតភពបីបាន ។
ចុះយើងហេតុអ្វីបានជានៅសល់ ធម៌ចូលមិនដល់ទល់នឹងសន្តាន
គួរឱ្យសង្វេគនឹកស្រណោះប្រាណ តើពេលណាបានព្រះធម៌ចូលដល់ ។
ឃើញឬកកិលេសចេះតែសរសើរ ដូចជាគ្រាន់បើទាំងមិនមានផល
ធាត់ធំដូចស្គរក្នុងមានតែខ្យល់ តាមដែលគេស្គាល់ស្មានតែគ្រាន់បើ ។

ដោយឧបាសក **គុយ សុធន**

# សុបិនមួយជាតិ

ល្អស្រស់អស្ចារ្យកូនមហាសេដ្ឋី បានរួមមេត្រីប្រគល់សម្បត្តិ
មកឱ្យក្នុងពេលសុបិនយប់ស្ងាត់ រលឹកឡើងបាត់បានត្រឹមរំខាន ។
សត្វអាសិរពិសទោះខ្លួនតូចក្តី ក៏អាចប្រល័យជីវិតមនុស្សបាន
ដុំរងើកភ្លើងទោះតូចប៉ុន្មាន អាចរាលឆេះប្រាណឆេះគ្រប់អ្វីៗ ។
ចំណែកដុំគ្រួសទោះតូចម្តេចម្តា ធ្លាក់ទឹកពេលណាក៏លិចដល់ដី
រីឯលាមកទោះតិចតួចក្តី ក៏ស្អុយគ្មានអ្វីប្រៀបប្រដូចបាន ។
យ៉ាងណាបាបកម្មក៏យ៉ាងនោះដែរ ទោះតិចគង់តែរងទុក្ខឥតខាន
បាបឱ្យផលហើយអ្នកអើយកុំស្មាន ថាអាចរស់បានសុខសាន្តនោះណា ។
កើតមកក្នុងលោករងទុក្ខឥតល្ហែ ពុំមែនចេះតែបានតាមប្រាថ្នា
សុបិនមួយជាតិឃ្លាតឆ្ងាយសាសនា មិនភ្ញាក់កាយាលង់លក់ទាំងថ្ងៃ ។
ខានធ្វើបុណ្យទានមិនមានកុសល រហូតមិនស្គាល់រសព្រះធម៌ថ្លៃ
កិលេសរុំជិតឃឹតយកអស់ដៃ ពុំមាននិស្ស័យនឹងព្រះធម្មា ។
រស់ក្នុងសង្គមនិយមមុខមាត់ ក្នុងចិត្តប្រាកដអត់មានសទ្ធា
អណ្តូងក៏ស្តារបន្លាក៏ពារ លាបមុខមាត់គ្នាបន្លំធម្មជាតិ ។

ដោយឧបាសក **គុយ សុធន**

# ផ្សាំងដំរីព្រៃ

សម្តីសំដៅចេញពីសន្តាន　　　វាចាថ្មើរម៉ានកុំស្មានមិនដឹង
ក្នុងចិត្តយ៉ាងណាសម្តីយ៉ាងហ្នឹង　　　សម្លក់សម្លឹងប្រឹងប្រាប់អ្នកណា ។
ទោះគេថាយើងអាក្រក់ក៏ដោយ　　　កុំឱ្យតែយើងដូចពាក្យគេថា
បើយើងអាក្រក់ហួសពីឧបមា　　　គេថាយើងល្អក៏ពុំល្អឡើយ ។
បើបុគ្គលណាមុជចុះក្នុងភក់　　　គឺកាមគម្រក់ដោយខ្លួនឯងហើយ
តើធ្វើម្តេចអាចឡើងគោករកត្រើយ　　　កុំបាច់ថាឡើយជួយអ្នកដទៃ ។
ទម័កជីកដាំសសរធំមាំ　　　បង្ហាប់បុកដំទៅក្នុងផែនដី
សម្រាប់ចងក្រៀកផ្សាំងសត្វដំរី　　　ដែលចាប់ពីព្រៃដើម្បីប្រើបាន ។
យ៉ាងណាព្រះអរិយសាវ័ក　　　បានចងក្រៀកជាក់ទាក់ចិត្តសន្តាន
រំងាប់ភ្ជាប់នឹងសតិប្បដ្ឋាន　　　ឱ្យបានជាក់ច្បាស់នូវព្រះនិព្វាន ។
នោះគឺព្រះអរិយបុគ្គល　　　លោកផុតកង្វល់តម្កល់ក្នុងឈាន
លោកមិនប្រមាទលោកមិនបំពាន　　　ក្នុងចិត្តលោកមានមេត្តាជានិច្ច ។
ចុះយើងឥឡូវនេះយ៉ាងណាដែរ　　　គ្រាន់តែឪម៉ែពុំគួរបើភ្លេច
គុណមិនទ្រទ្រង់គង់តែលង់លិច　　　ដឹងគុណជានិច្ចធ្មេចភ្នែកញញឹម ។

ដោយឧបាសក **គុយ សុធន**

# បងខុសហើយអូន

សម្ដីរម្យទម   សម្ដីទឹកឃ្មុំ   អប់រំទូទៅ
សម្ដីកំហូច   ដូចសំដីស្រូវ   សំដីហុយត្រូវ
នាំស្មៀបរមាស់ ។
លំបាកម្លេះទេ   ចង់បិទមាត់គេ   សម្ដីឡេះឡោះ
តែត្រចៀកខ្លួន   ចំហទាំងអស់   គ្មានអ្វីទប់សោះ
មុតអស់សន្ដាន ។
រឿងក្នុងផ្ទះសោះ   អ្នកក្រៅដឹងអស់   ទុកចិត្តម្ដេចបាន
ត្រូវប្រុងប្រយ័ត្ន   អ្នកនៅជិតប្រាណ   រឿងហួសប្រមាណ
កុំអាលឱ្យដឹង ។
ការរួមរស់នៅ   តែងមានខុសត្រូវ   ភ្នែកនៅសម្លឹង
ប្រឹងចាប់កំហុស   ចាំចងកំហឹង   ម្នាក់ខុសម្នាក់ខឹង
គ្រាន់បើអ្នកណា ។
កើតមកដោយបុណ្យ   រស់បានដោយគុណ   មុនសូន្យសង្ខារ
ត្រូវធ្វើបុណ្យទាន   មានចិត្តជ្រះថ្លា   ខុសទាស់ម្ដេចម្ដា
មេត្តាគ្នាផង ។

សុទ្ធតែអ្នកចេះ ភ្លេចគិតកិលេស ប្រេះចេញម្ដងៗ
សាហាវខ្លាំងណាស់ ឥតខ្មាសអ្នកផង មួយយប់កន្លង
បងខុសហើយអូន ។
ទទួលកំហុស ដឹងថាខ្លួនខុស ធ្វើមុខស្រពោន
មិនយូរប៉ុន្មាន មិនបានជួបអូន ភ្លេចប្រពន្ធកូន
អូនយំដដែល ។
ដើរដួលពុំក្រោក កិលេសវាបោក ខោកហើយអង្អែល
ខឹងខុសខូចខាត ប្រមាទដដែល បានត្រឹមប្រហែល
ក្រវិលភ្ជំភ្លើង ។
ស្អប់កាចខ្លាចក្ដៅ ម្ដេចចេះតែទៅ ស្ទាបដៃជាន់ជើង
កាចឆ្នាសប៉ះស្អិត ចិត្តរេរកទ្រើង ឡើងហើយរលើង
ភ្លើងរលាកហើយ ។

ដោយឧបាសក **គុយ សុធន**

# ប្រកាន់មាំក្រៀមក្រាំចិត្ត

សត្វលោកកើតមកចង់បានសុខ  តែបែរជួបទុក្ខមុខស្រពោន
ទុក្ខទាំងម៉ែឪទុក្ខទាំងកូន  ទុក្ខរហូតសូន្យសត្វសង្ខារ ។
ថ្នាំពុលថ្នាំពិសមនុស្សខ្លាចណាស់  តែបើដឹងច្បាស់អស់បញ្ហា
បើមិនលាបលិទ្ធជាអាហារ  ពិសពុលយ៉ាងណាក៏មិនថ្វី ។
សុរាមេរ័យគ្រឿងស្រវឹង  តែត្រូវយល់ដឹងមិនបាច់ភ័យ
បើមិនផឹកទេស្រវឹងអី  សុរាមេរ័យឥតមានគ្នា ។
បន្លាក្នុងព្រៃគ្មានអំណាច  គ្នាខ្លាចតែមនុស្សដើរទៅពារ
ដើរជាន់គ្នាបាក់មុតបែរជា  ថាគ្នាឃោរឃៅទៅមុតគេ ។
ភ្លើងឆេះគ្រប់គ្រាពិតជាក្តៅ  តែបើមិនទៅលូកប៉ះទេ
នៅឆ្ងាយពីភ្លើងទាំងយើងគេ  មិនរលាកទេកុំបារម្ភ ។
យ៉ាងណាទុក្ខក៏មិនអាចធ្វើ  អំពើនាំឱ្យយើងក្រៀមក្រាំ
បើយើងមិនបានប្រកាន់មាំ  ប្រគល់អារម្មណ៍ឱ្យចិត្តទៅ ។
ការប្រកាន់មាំនេះឯងណា  បើមុនមរណាមានជាប់នៅ
បដិសន្ធិក្នុងស្ថានជ្រៅ  រកផ្លូវសុខសាន្តពុំបានឡើយ ។

ដោយឧបាសក **គុយ សុធន**

# សំណាងស្រុកយើងមានព្រះពុទ្ធសាសនា

លំហវេហាមហាធំធេង ហោះហើររមែងវែងឥតទាល់
អាកាសបែកផ្សេងតែងមានខ្យល់ នៅក្នុងសកលលោកទូទៅ ។
ក្រោមមេឃមានដីជាប្រធាន នៅលើដីមានមនុស្សរស់នៅ
មនុស្សមានបេះដូងរូបរាងរៅ ក្នុងបេះដូងជ្រៅមានដួងចិត្ត ។
ក្នុងចិត្តមានធម៌ល្អគួរគាប់ ក្នុងធម៌ចិត្តស្ងប់អស់ទុក្ខពិត
បើអស់ទុក្ខហើយមិនបាច់គិត ថាសុខមានពិតឬយ៉ាងណា ។
ឃើញបន្លាច្រើនព្រៃមាត់ជ្រោះ ដើរបិទភ្នែកព្រោះខ្លាចបន្លា
តើអាចដើរដល់ដូចប្រាថ្នា មិនមុតបន្លាដែរឬអី ។
ដូច្នេះត្រូវបើកភ្នែកសម្លឹង ពិនិត្យឱ្យដឹងជើងជាន់ដី
ត្រង់ណាស្រឡះឥតមានអ្វី អាចឆ្លងផុតព្រៃបន្លាបាន ។
យ៉ាងណាបើខ្លាចសេចក្តីទុក្ខ តែមិនស្គាល់មុខទុក្ខប៉ុន្មាន
មិនកំណត់ដឹងក្នុងសន្តាន ទុក្ខរឹតតែបានចម្រើនឡើង ។
ដើម្បីស្គាល់មុខទុក្ខឱ្យច្បាស់ ត្រូវតែរហ័សលើកតម្កើង
ព្រះធម៌វិន័យប្រពៃឡើង សំណាងស្រុកយើងមានសាសនា ។

ដោយឧបាសក **គុយ សុធន**

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
# ក្នុងការចារធម្មទាន

| | |
|---|---|
| ១. លោកគ្រូ រស់ សូផាត | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. ឧបាសក សោម រតនៈ | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. ឧបាសិកា ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក ជឹម ជំនិត | ១២. ឧបាសក ជឹង វេងអ៊ាវ |
| ១៣. ឧបាសក ង៉ូវ គា | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសក ច័ន្ទ សុខុម | ១៦. ឧបាសក ទូច គីមស្រ៊ាង |
| ១៧. ឧបាសក ម៉ៅ ម៉ន | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូផា | ២០. ឧបាសិកា ហាយច័ន្ទធវី |
| ២១. ឧបាសក អ៊ឹម វ៉ៃយ៉ា | ២២. ឧបាសក ហាន សីហៈ |

# រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
# ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១- លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហគ្គា +បុត្រ ..... ស.រ.អ.
២- ឧ.ស.កៅ សេក និង ឧ.សិ.យី សាគុណ ព្រមទាំងបុត្រ+ចៅ ស.រ.អ.
៣- ឧ.សិ.ង៉ែត លេន ព្រមទាំងបុត្រ និងចៅ ....................... ស.រ.អ.
៤- លោក ចាន់ ម៉ល់ និង អ្នកស្រី ជា សុផា ព្រមទាំងបុត្រ...... ស.រ.អ.
៥- ឧ.សិ.ចាន់ នារីសុខ និងក្រុមគ្រួសារ ........................... ស.រ.អ.
៦- ឧ.សិ.ឆាន់ ហៃគីង ព្រមទាំងបុត្រ និង ចៅ ...................... ស.រ.អ.
៧- ឧ.ស.ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គីមសែ + បុត្រ ......... ស.រ.អ.
៨- ឧ.ស.ឆេង សារឿន ឧ.សិ.ជុំ លាភ+ឧ.ស.ហ៊ឹស៊ុ ឧ.សិ.អាន . ស.រ.អ.
៩- ឧ.ស.ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា ព្រមទាំងបុត្រ .. ស.រ.អ.
១០- ឧ.ស.ជិម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ +ចៅ ..... ស.រ.អ.
១១- ឧ.សិ.ឈ គីមហោ ព្រមទាំងបុត្រ និងចៅ ..................... ស.រ.អ.
១២- ភិក្ខុ ឈួម បូ ( វត្តពន្លឺពុទ្ធចក្រ លោវែល ) .................... ស.រ.អ.
១៣- ឧ.សិ.តាន់ ភិចជួ ព្រមទាំងបុត្រធីតា និងចៅៗ ............. ស.រ.អ.
១៤- ឧ.ស.តែ ប៊ុនគង់ និង ឧ.សិ.ថោង បូនី ព្រមទាំងបុត្រ+ចៅ ស.រ.អ.
១៥- ឧ.សិ.តែ សាយជូ ព្រមទាំងបុត្រ និងចៅ ...................... ស.រ.អ.
១៦- ឧ.សិ.ទីន ឈីវ ព្រមទាំងបុត្រ និងចៅ ......................... ស.រ.អ.
១៧- ឧ.សិ.ទូច ផានី និង ស្វាមី Leslie Mael ព្រមទាំងបុត្រ . ស.រ.អ.

| | | |
|---|---|---|
| ១៨- | ឧ.សិ.នួន ប៊ិច និង ឧ.សិ.រស់ សុផល ព្រមទាំងបុត្រ+ចៅ... | ស.រ.អ. |
| ១៩- | ឧ.សិ.ប៉ាន់ ពិណ្ណារី និង ស្វាមី ព្រមទាំងបុត្រ និងចៅ ........ | ស.រ.អ. |
| ២០- | ឧ.សិ.ប៉ាន សារិទ្ធ ( ហៅង៉ា ) ព្រមទាំងបុត្រ និងចៅ ....... | ស.រ.អ. |
| ២១- | ឧ.សិ.ប៊ិត ថងខាំ និង ឧ.សិ.សាន ផល្លីន ព្រមទាំងបុត្រ+ចៅ. | ស.រ.អ. |
| ២២- | ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹង រិទ្ធារី ព្រមទាំងបុត្រ ...... | ស.រ.អ. |
| ២៣- | លោកយាយ ពិន សាត ព្រមទាំងបុត្រ និងចៅ.............. | ស.រ.អ. |
| ២៤- | ឧ.ស.ពឹង សេងគី និង ឧ.សិ.អ៊ឹង ធឿម ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ២៥- | លោក ពេជ្រ សីហា និង អ្នកស្រី ថាប់ សុរត្ន័ ................ | ស.រ.អ. |
| ២៦- | ឧ.សិ.មិល យ៉ែម និង ឧ.សិ.គួយ ឡេង ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ២៧- | ឧ.ស.ម៉ៃ គួលអេង និង ឧ.សិ.រស់ កល្យាណ ................... | ស.រ.អ. |
| ២៨- | ឧ.ស.យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម + បុត្រ ........... | ស.រ.អ. |
| ២៩- | ឧ.សិ.រស់ លីណា និង ឧ.សិ.នឹម វណ្ណី ព្រមទាំងកូនចៅ .... | ស.រ.អ. |
| ៣០- | ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ ............................................. | ស.រ.អ. |
| ៣១- | ឧ.សិ.លឹម សុខុម ព្រមទាំងបុត្រ ................................ | ស.រ.អ. |
| ៣២- | ឧ.ស.វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ+ចៅ .. | ស.រ.អ. |
| ៣៣- | ឧ.ស.វ៉ាង សាវុធ និង ឧ.សិ.គង់ ស៊ីណាត ព្រមទាំងបុត្រ .. | ស.រ.អ. |
| ៣៤- | ឧ.សិ.ស៊ីវ យក់លុយ ព្រមទាំងបុត្រ និងចៅ ................... | ស.រ.អ. |
| ៣៥- | ឧ.សិ.សុខ យ៉ាន ...................................................... | ស.រ.អ. |
| ៣៦- | ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ព្រមទាំងបុត្រ .......... | ស.រ.អ. |
| ៣៧- | ឧ.ស.ស៊ូ ហុកឡុង និង ឧ.សិ.តាន់ ឈីវហា ព្រមទាំងបុត្រ. | ស.រ.អ. |
| ៣៨- | ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ... | ស.រ.អ. |

| | | |
|---|---|---|
| ៣៩- | ឧ.ស.សំណាង យឹម និង ឧ.សិ.ឡូរ៉ា យឹម ព្រមទាំងបុត្រ ... | ស.រ.អ. |
| ៤០- | ឧ.សិ.ស្រង់ អែ និង ឧ.សិ.ស្រង់ ឡេង ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ៤១- | ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា ព្រមទាំងបុត្រ | ស.រ.អ. |
| ៤២- | ឧ.ស.ហោ លាន និង ឧ.សិ.ឆឹង អូន +ឧ.សិ.អុន ញ៉ូ ........ | ស.រ.អ. |
| ៤៣- | ឧ.សិ.ឡុង អ៊ុម ព្រមទាំងបុត្រ និងចៅ ........................ | ស.រ.អ. |
| ៤៤- | ឧ.សិ.ឡាំង គីមឆេង ព្រមទាំងបុត្រ ........................... | ស.រ.អ. |
| ៤៥- | ឧ.សិ.អ៊ឹង ស៊ីវន ព្រមទាំងបុត្រ និងចៅ .......................... | ស.រ.អ. |
| ៤៦- | ឧ.ស.អ៊ុន ឆៃត្រី និង ភរិយា ព្រមទាំងបុត្រ .................. | ស.រ.អ. |
| ៤៧- | លោកគ្រូធម្មបណ្ឌិត អឿ សៅ .................................. | ស.រ.អ. |
| ៤៨- | ឧ.ស.អៀង ឆាយ និង ឧ.សិ. អៀ កេសរ ព្រមទាំងបុត្រ . | ស.រ.អ. |
| ៤៩- | ឧ.ស.កាំង ប៉េងជីវ និង ឧ.សិ.លឹម អ៊ីហ៊ាម + កូនចៅ ..... | អូស្ត្រាលី |
| ៥០- | ឧ.ស.គង់ វុធ និង ឧ.សិ.ជ័យ សារីម ព្រមទាំងកូនចៅ ....... | អូស្ត្រាលី |
| ៥១- | កញ្ញា គា ដារ៉ា ( ហៅ ស្រីណេ ) .............................. | អូស្ត្រាលី |
| ៥២- | ឧ.ស.ង៉ូវ ឈីវ និង ឧ.សិ.ហេង ពាស៊ុម ព្រមទាំងបុត្រ+ចៅ | អូស្ត្រាលី |
| ៥៣- | យុវជន ចាន់ ឌីណា ............................................... | អូស្ត្រាលី |
| ៥៤- | ឧ.សិ.ឆេង លុន ព្រមទាំងបុត្រ និងចៅ ........................ | អូស្ត្រាលី |
| ៥៥- | ឧ.សិ.ជា ឡេង ព្រមទាំងបុត្រ .................................. | អូស្ត្រាលី |
| ៥៦- | ឧ.សិ.ជូ រ៉េន ........................................................ | អូស្ត្រាលី |
| ៥៧- | ឧ.សិ.ឈុ គីមស៊ីន និង ក្រុមគ្រួសារកូនចៅ .................. | អូស្ត្រាលី |
| ៥៨- | ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង ព្រមទាំងបុត្រ.... | អូស្ត្រាលី |
| ៥៩- | លោក ញាន ហេងម៉ូវ និង អ្នកស្រី ស៊ា ចន្ថា ព្រមទាំងបុត្រ | អូស្ត្រាលី |

៦០- ឧ.ស.ដែន គង់ហួត និង ឧ.សិ.កាំង គឹមស៊ុន ព្រមទាំងបុត្រ អូស្ត្រាលី
៦១- ឧ.ស.តូ សាវឿន និង ឧ.សិ.មាន សុវត្ថិ ព្រមទាំងបុត្រ ........ អូស្ត្រាលី
៦២- ឧ.សិ.តាំង សៀវកហៀង ព្រមទាំងកូនចៅ ........................ អូស្ត្រាលី
៦៣- ឧ.ស.ទា សុង និង ឧ.សិ.ង៉ោ ចាន់ខេង ព្រមទាំងកូនចៅ .. អូស្ត្រាលី
៦៤- ឧ.សិ.បាក់ លីឡេងហ៊ាង ព្រមទាំងកូនចៅ ...................... អូស្ត្រាលី
៦៥- ឧ.ស.ប៊ុន ហេង និង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ .......... អូស្ត្រាលី
៦៦- ឧ.សិ.ប៉ុក យ៉ារ៉ាត និង ស្វាមី+បុត្រ+លឹម ស៊ុនហេង+បុត្រ.. អូស្ត្រាលី
៦៧- ឧ.ស.ប៉ុច វឿត និង ឧ.សិ.ញូង ស៊ាងម៉េង ព្រមទាំងបុត្រ.. អូស្ត្រាលី
៦៨- លោកយាយ ប្រាក់ខាត់+ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ អូស្ត្រាលី
៦៩- ឧ.សិ.ម៉េង ប៊ុន្នារី ( ហៅស្រីពៅ ) និង ស្វាមី ព្រមទាំងបុត្រ. អូស្ត្រាលី
៧០- ឧ.ស.យ៉ង់ សិន និង ឧ.សិ.នន់ ហេង ព្រមទាំងបុត្រ+ចៅ. អូស្ត្រាលី
៧១- លោក យឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល +បុត្រ........ អូស្ត្រាលី
៧២- ឧ.សិ.រត្ន័ គឹមសាន ..................................................... អូស្ត្រាលី
៧៣- ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង ព្រមទាំងបុត្រ . អូស្ត្រាលី
៧៤- ឧ.ស.រាជ ស៊ាង និង ឧ.សិ.វង់ រិទ្ធ ព្រមទាំងបុត្រ ............ អូស្ត្រាលី
៧៥- ឧ.សិ.លឹម ស៊ូឆេង ព្រមទាំងកូនចៅ ........................... អូស្ត្រាលី
៧៦- ឧ.ស.លឹម ហុងលី និង ឧ.សិ.ស៊ឹម តេងគី ព្រមទាំងបុត្រ... អូស្ត្រាលី
៧៧- ឧ.សិ.ស៊ន លន់អេង ................................................... អូស្ត្រាលី
៧៨- ឧ.ស.សរ ប៊ុនធឿង ព្រមទាំងបុត្រ និងចៅ................... អូស្ត្រាលី
៧៩- ឧ.ស.ស៊ីវ សៀងថៃ និង ឧ.សិ.ឯក សុកហាក់ +បុត្រ ...... អូស្ត្រាលី
៨០- ឧ.ស.ស៊ីវ មាស និង ឧ.សិ.លាង ណាំសួរ ព្រមទាំងកូនចៅ.. អូស្ត្រាលី

| | | |
|---|---|---|
| ៨១- | ឧ.សិ.ស៊ុយ គឹមស៊ាន និងកូនស្រី សេង ផល្លា ................ | អូស្ត្រាលី |
| ៨២- | កញ្ញា ស៊ុយ ដាំណែត .............................................. | អូស្ត្រាលី |
| ៨៣- | ឧ.ស.ស៊ូ ឃឹម និង ឧ.សិ.សៀង តិច ព្រមទាំងបុត្រ+ចៅ.. | អូស្ត្រាលី |
| ៨៤- | ឧ.សិ.សៀង វួច ព្រមទាំងកូនចៅ ................................. | អូស្ត្រាលី |
| ៨៥- | ឧ.សិ.សេង សៀងឈុន ព្រមទាំងបុត្រ និងចៅ ............. | អូស្ត្រាលី |
| ៨៦- | ព្រឹទ្ធាចារ្យ សេង ទូច ព្រមទាំងបុត្រ និងចៅ ................ | អូស្ត្រាលី |
| ៨៧- | ឧ.សិ.ស៊ិត ស៊ីវ៉ន ព្រមទាំងបុត្រ និងចៅ ..................... | អូស្ត្រាលី |
| ៨៨- | ឧ.ស.សំ សុខគុណ និង ឧ.សិ.លី សៀមហៀង + បុត្រ ... | អូស្ត្រាលី |
| ៨៩- | កុង ហេង ឡេងថៃ និង ម៉ា អ៊ា គឹមទាង+ចៅថៃ ឃីអ៊ុយ | អូស្ត្រាលី |
| ៩០- | ឧ.ស.ឡុង ហ៊ន និង ឧ.សិ.លិម យូអេង ...................... | អូស្ត្រាលី |
| ៩១- | ឧ.ស.ឡៅ គឹមងួន និង ឧ.សិ.ដួង លី ព្រមទាំងបុត្រ ........ | អូស្ត្រាលី |
| ៩២- | ឧ.សិ.អ៊ន ម៉ា ព្រមទាំងកូនចៅ .................................... | អូស្ត្រាលី |
| ៩៣- | ឧ.ស.អ៊ា សេង និង ឧ.សិ.គីម ខេង ព្រមទាំងកូនចៅ ...... | អូស្ត្រាលី |
| ៩៤- | ឧ.ស.អ៊ឹង ឈាងហេង និង ឧ.សិ.សំ ពៅនារី +បុត្រ ......... | អូស្ត្រាលី |
| ៩៥- | ឧ.សិ. អ៊ុក ណារី ព្រមទាំងបុត្រ .................................. | អូស្ត្រាលី |
| ៩៦- | ឧ.សិ.ឱម លក្ខណា  ព្រមទាំងបុត្រធីតា ........................ | អូស្ត្រាលី |
| ៩៧- | HENG Srey Chea+H.Srey Chan+H.Srey Neang. | អូស្ត្រាលី |
| ៩៨- | Mr BOON Leang Chaing+Mrs Nary SOK... | អូស្ត្រាលី |
| ៩៩- | ឧ.សិ.គឹម ហួយ ព្រមទាំងបុត្រ និងចៅ ..................... | បារាំង |
| ១០០- | ឧ.ស.ង៉ូវ ជួនណារេត ឧ.សិ.ង៉ូវ សោភ័ណ ព្រមទាំងបុត្រ... | បារាំង |
| ១០១- | ឧ.សិ.ង៉ែត យ៉េន ព្រមទាំងបុត្រ និងចៅ .................. | បារាំង |

| | | |
|---|---|---|
| ១០២- | ឧ.ស.ជីន ជុង និងភរិយា......................................... | បារាំង |
| ១០៣- | ឧ.ស.ឈឹម ហុកអ៊ាន ព្រមទាំងបុត្រ និងចៅ ............... | បារាំង |
| ១០៤- | ឧ.សិ.ទាវ គឹមហ៊ួន ព្រមទាំងកូនចៅ ......................... | បារាំង |
| ១០៥- | ឧ.ស.បាន ណារិន និង ឧ.សិ.ហោ ចន្ធូ ព្រមទាំងបុត្រ .... | បារាំង |
| ១០៦- | ឧ.ស.ប៊ុន ឈឹម និង ឧ.សិ.គី គីមលាង ព្រមទាំងបុត្រ .. | បារាំង |
| ១០៧- | លោក យូណូស អាស៊ីស  និង អ្នកស្រី ហុក ណារី+បុត្រ ... | បារាំង |
| ១០៨- | ឧ.សិ.ហែម ពៅ ព្រមទាំងបុត្រ .............................. | បារាំង |
| ១០៩- | ឧ.ស.ហ្វាន់ វ៉ាន់ហួ និង ឧ.សិ.ហ្វាន់ យូលាង ព្រមទាំងបុត្រ | បារាំង |
| ១១០- | ឧ.ស.ឡុក ប៊ុនអ៊ីវ និង ឧ.សិ.តាន់ ស៊ីវឡាង+បុត្រ........... | បារាំង |
| ១១១- | ឧ.ស.ឡៅ សេងជ្រុន និង ឧ.សិ.ផាំង លី កូនចៅ .......... | បារាំង |
| ១១២- | ឧ.សិ.អ៊ឹង ហ្គេចតេង ព្រមទាំងបុត្រ  ........................ | បារាំង |
| ១១៣- | ឧ.សិ.អ៊ឹង យ៉េកសាង ព្រមទាំងបុត្រ ........................ | បារាំង |
| ១១៤- | Mme LAK KIM LEANG .............................. | បារាំង |
| ១១៥- | ឧ.សិ.ចំណាន ព្រមទាំងក្រុមគ្រួសារ ......................... | កាណាដា |
| ១១៦- | ឧ.សិ.ឆាយ ស៊ន ព្រមទាំងបុត្រ និងចៅ+ចៅទួត......... | កាណាដា |
| ១១៧- | ឧ.ស.ពុធ ប៉ោលាង និង ឧ.សិ.ហ៊ុន ស៊ីវអៀង+កូនចៅ . | កាណាដា |
| ១១៨- | Chhem Sokreth.Puth Kunthea+Rothmony+Bunnawat. | កាណាដា |
| ១១៩- | Su Sokunora et Inn Visal+Narita et Raksa ..... | កាណាដា |
| ១២០- | ឧ.សិ.តាន់ វួចឆាយ .......................................... | កាណាដា |
| ១២១- | ឧ.សិ. លី វន ព្រមទាំងក្រុមគ្រួសារ ........................ | កាណាដា |
| ១២២- | កូនចៅរបស់ ឧ.សិ.លាន ម៉ិច ............................... | កាណាដា |

| | | |
|---|---|---|
| ១២៣- | ឧ.ស.ឡាវ លាងថេង និង ឧ.សិ.ពឹង ឈីវអ៊ាន+បុត្រ .. | កាណាដា |
| ១២៤- | ឧ.សិ.អ៊ា នៅ និង ឧ.សិ.អ៊ា គឹមយូ ព្រមទាំងកូនចៅ ....... | កាណាដា |
| ១២៥- | ឧ.សិ.អ៊ាប គិមអ៊ីន ព្រមទាំងបងប្អូនកូនចៅ ........... | កាណាដា |
| ១២៦- | ឧ.សិ.ត្រា វ៉ាន្នី និង ឧ.ស.ត្រា ពិសារ ........................... | ស្វីស |
| ១២៧- | ឧ.សិ.កាំង ប៉ោទាង និង ឧ.ស.ហេ អេន +កូនចៅ ....... | ភ.ព. |
| ១២៨- | ឧ.សិ.ខៀវ វុត្ថា (ហៅមុំ)................................... | ភ.ព. |
| ១២៩- | ឧ.ស.ខៀវ ជៀប និង ឧ.សិ.ប៉ោ គឹមស្រ៊ាង ព្រមទាំងកូនចៅ | ភ.ព. |
| ១៣០- | ឧ.សិ.គង់ ម៉ៃ ព្រមទាំងបុត្រ និងចៅ ........................ | ភ.ព. |
| ១៣១- | ឧ.ស.គង់ សៀងហៃ និង ឧ.សិ.ប៉ក់ សូត្រតារាភិឱន+បុត្រ | ភ.ព. |
| ១៣២- | ឧ.ស.គង់ ហេង និង ឧ.សិ.ធាវ ស៊ីប ព្រមទាំងកូនចៅ .. | ភ.ព. |
| ១៣៣- | ឧ.សិ.គឹម សុខុន ព្រមទាំងបុត្រ និងចៅ ................... | ភ.ព. |
| ១៣៤- | ឧ.ស.គួច ឡៃស្រេង និង ឧ.សិ.ជិន ហួរ ....................... | ភ.ព. |
| ១៤៥- | ឧ.សិ.គ្រី ណៃប៊ួយ ព្រមទាំងបុត្រ ........................... | ភ.ព. |
| ១៣៦- | ឧ.សិ.ឃុត គឹមថន+ឧ.សិ.ឃួន គឹមនី .................. ..... | ភ.ព. |
| ១៣៧- | ឧ.ស.ឃ្លោក យិត និងពុទ្ធបរិស័ទខេត្តព្រះសីហនុ ........ | ក.ព.ស. |
| ១៣៨- | ឧ.ស.ង៉ឹម ញាណ និង ឧ.សិ.កាំង ប៊ូលីន ព្រមទាំងបុត្រ . | ភ.ព. |
| ១៣៩- | ឧ.ស.ង៉ែត ផេង និង ឧ.សិ.ហៅ ហេង+បុត្រ ផេង បូរ៉ា . | ភ.ព. |
| ១៤០- | ឧ.ស.ង៉ូវ គា និង ឧ.សិ.ឈុន គឹមអេង ព្រមទាំងបុត្រ ... | ប.ប. |
| ១៤១- | ឯ.ឧ.កាន់ វ៉ាត់ និង ឧ.សិ.កែវ កល្យាណ+ក.កាន់សុថារត្ន័ | ភ.ព. |
| ១៤២- | ឯ.ឧ.ចែម វីឡ៉ា និង លោកជំទាវ សុខា ស៊ូលីវណ្ណ+បុត្រ. | ភ.ព. |
| ១៤៣- | ឯ.ឧ.ធ្នាំ (ធម្ម )ប៊ុនស្រុន លោកជំទាវ យ៉ែម សួស្តី+បុត្រ. | ភ.ព. |

| | | |
|---|---|---|
| ១៤៤- | ឯ.ឧ.ស្បោង សារ៉ាត់  លោកជំទាវ ស៊ាន ឈុនហេង+បុត្រ | ក.ព.ស. |
| ១៤៥- | ឯ.ឧ.អ៊ិត ប្រាំង និង លោកជំទាវ ញ៉ែម សេដ្ឋា+បុត្រចៅ | ភ.ព. |
| ១៤៦- | ឯ.ឧ.ឯម ប៊ុនសាត និង លោកជំទាវ នូ ចន្ថា ព្រមទាំងបុត្រ | ភ.ព. |
| ១៤៧- | ឯ.ឧ.ឧកញ៉ា ទុយ គី និង លោកជំទាវ កង វុទ្ធា ( ស្រីម៉ៅ) | ភ.ព. |
| ១៤៨- | ឧកញ៉ា ស៊ិន សុខា និង លោកជំទាវ សុខា ផល្លី +បុត្រ+ចៅ | ភ.ព. |
| ១៤៩- | ឧកញ៉ា សេង ឆាយអ៊ួរ និង ឧ.សិ.កាំង ហ៊ិចណៃ+បុត្រ+ចៅ | ភ.ព. |
| ១៥០- | ឧកញ៉ា សុខ សុខា និង លោកជំទាវ ចាន់ លាង+បុត្រ ... | ភ.ព. |
| ១៥១- | ឧ.សិ.ច័ន្ទ បុប្ផាណា ព្រមទាំងបុត្រធីតា ..................... | ភ.ព. |
| ១៥២- | ឧ.សិ.ច័ន្ទ ណារឿន+ឪពុក ច័ន្ទ ឆឹង និងម្តាយ មួង ភី ..... | ភ.ព. |
| ១៥៣- | ឧ.ស.ច័ន្ទ សុខុម និង ឧ.សិ.គឹម ចន្ថា ព្រមទាំងកូនចៅ ... | ភ.ព. |
| ១៥៤- | ឧ.ស.ចាន់ យូរ៉ាន់ និង ឧ.សិ.ពត សារ៉ាន់ +បុត្រ ......... | ភ.ព. |
| ១៥៥- | ឧ.សិ.ចាន់ សុស ( ហៅ សាម៉េត ) ព្រមទាំងបុត្រ ....... | ភ.ព. |
| ១៥៦- | ឧ.សិ.ច្រឹង គឹមស្រ៊ី ព្រមទាំងបុត្រ .......................... | ភ.ព. |
| ១៥៧- | យុវជន ជា សុភ័ក្រ្ត និងមាតាបិតា ........................... | ភ.ព. |
| ១៥៨- | ឧ.សិ.ជា សុណារី និងក្មួយស្រី ជា សុមេធាធីតា .......... | ភ.ព. |
| ១៥៩- | ឧ.ស.ជា សុខុម និង ឧ.សិ.អ៊ុន ពូន ព្រមទាំងបុត្រ ....... | ភ.ព. |
| ១៦០- | ឧ.សិ.ជា ស៊ីវយ៉េក+ឧ.សិ.ហេងមួយចេង+ហេងមួយឡាង | ភ.ព. |
| ១៦១- | ឧ.ស.ជាន យ៉ែត និង ឧ.សិ.សុក ចេង ព្រមទាំងបុត្រ ..... | ភ.ព. |
| ១៦២- | ឧ.សិ.ជិន ហួ ព្រមទាំងកូនចៅ ............................... | ភ.ព. |
| ១៦៣- | លោកស្រី ជីវ គឹមឆេង និង ឧ.សិ.ជីវ យ៉ា ................. | ប.ប. |
| ១៦៤- | ឧ.សិ.ជូ ឆេងហោ  ............................................ | ភ.ព. |

១៦៥- ឧ.សិ.ជុំ ឆាយ និង ឧ.សិ.ជុំ ណារ៉ា+ជុំ ពិសិដ្ឋ+ជុំ សុជាតិ . ភ.ព.

១៦៦- ឧ.សិ.ជ្រុន ស៊ីដេត និងប្អូន +ក្មួយ និងចៅ .................. ភ.ព.

១៦៧- ឧ.សិ.ឈឹម ផលវិទ្យា និងក្មួយ វរុណ ភក្តី .................. ភ.ព.

១៦៨- ឧ.សិ.ឈុន ណារី និងកូនចៅ+ឧ.សិ.តោ ឡោ និងកូនចៅ ភ.ព.

១៦៩- ឧ.សិ.ឈួន គឹមនី និងបងប្អូន កូនក្មួយ ...................... ភ.ព.

១៧០- ឧ.ស.ណុប យូហេង និង ឧ.សិ.ផេង ផន +កូនចៅ ....... ភ.ព.

១៧១- ឧ.សិ.តាន់ ជាលី និងពុទ្ធបរិស័ទខេត្តសៀមរាប .......... ភ.ព.

១៧២- ឧ.ស.តូច ផាន់ណាស៊ី និង ឧ.សិ.សុខ ច័ន្ទណារិទ្ធ+បុត្រ... ភ.ព.

១៧៣- ឧ.សិ.តាំង លីគាង និង ស្វាមី ព្រមទាំងបុត្រ +ចៅ ...... ភ.ព.

១៧៤- ឧ.ស.តៅ ឃាង និង ឧ.សិ. ឈុន លន ព្រមទាំងកូនចៅ . ភ.ព.

១៧៥- ឧ.សិ.ថៃ នាថ ព្រមទាំងបុត្រ និងចៅ ...................... ភ.ព.

១៧៦- ឧ.ស.ទី គៀង និង ភរិយា ព្រមទាំងបុត្រ .................. ភ.ព.

១៧៧- ទៀងវណ្ណថា+ចាន់ហ្កេចស៊ីម+ហុយខេង+ទិត្យស៊ុន+ប៉ិចគុណ ភ.ព.

១៧៨- ឧ.ស.នុត វន្ថា និង ឧ.សិ.ម៉ៅ សុភា ព្រមទាំងបុត្រ ...... ភ.ព.

១៧៩- ឧ.សិ.ប៉ក់ សុភាព ព្រមទាំងបុត្រ និងចៅ .................. ភ.ព.

១៨០- ឧ.ស.ប៉ុល នាង និង ឧ.សិ.គ្រៀល ស៊ីយ៉ា +បុត្រ+ចៅ . ភ.ព.

១៨១- លោកយាយ ប៊ុន យ៉ាំ ព្រមទាំងបុត្រ និងចៅ ............. ភ.ព.

១៨២- ឧ.សិ.ប៊ូអាន ស៊ីវុត្ថា ............................................ ភ.ព.

១៨៣- ឧ.សិ.ប៊ូ ផារ៉ាំណ .............................................. ភ.ព.

១៨៤- ឧ.សិ.ប៊ូ សៀកហ៊ុន ព្រមទាំងបុត្រ និងចៅ ............... ភ.ព.

១៨៥- ឧ.សិ.ព្រុំ សុភាព ព្រមទាំងបុត្រ ............................ ភ.ព.

| | | |
|---|---|---|
| ១៨៦- | ឧ.ស.ភាវ សាន និង ឧ.សិ.ប៉ក់ សុបុណ្យ+បុត្រ.......... | ភ.ព. |
| ១៨៧- | ឧ.ស.មាស ខេង និង ឧ.សិ.មួរ វួច ព្រមទាំងកូនចៅ ... | ភ.ព. |
| ១៨៨- | ឧ.ស.ម៉ូវ ធីម និង ឧ.សិ.ហ៊ាន ណៃយឹម ព្រមទាំងបុត្រ . | ភ.ព. |
| ១៨៩- | ឧ.ស.ម៉ួង យឿនវណ្ណៈ និង ឧ.សិ.ប៉ក់ សូត្រសុន្ទី+បុត្រ.. | ភ.ព. |
| ១៩០- | លោក ម៉េង ហ៊ា និង អ្នកស្រី ម៉ាន ស៊ីសុថា ព្រមទាំងបុត្រ | ភ.ព. |
| ១៩១- | ឧ.ស.ម៉េង សាខន និង ឧ.សិ.ចាន់ សុខា ព្រមទាំងបុត្រ. | ភ.ព. |
| ១៩២- | ឧ.ស.ម៉ែន សឿន និង ឧ.សិ.អៀង ណារី +បុត្រ+ចៅ .. | ភ.ព. |
| ១៩៣- | ឧ.ស.ម៉ៅ ផុន និងមាតា យស សម្បត្តិ .................... | ភ.ព. |
| ១៩៤- | ឧ.ស.ម៉ៅ សយ និង ឧ.សិ.គង់ ចំរើន +បុត្រ+ចៅ ....... | ភ.ព. |
| ១៩៥- | ឧ.ស.ម៉ៅ សុគន្ធ និង ឧ.សិ.អ៊ឹង យ៉េកហួយ និងបុត្រ .. | ភ.ព. |
| ១៩៦- | ឧ.ស.ម៉ៅ ស្រ៊ិន និង ឧ.សិ.ទូច ស៊ីនហ៊ាន+បុត្រ+ចៅ..... | ភ.ព. |
| ១៩៧- | ឧ.ស.ម៉ៅ វ៉ាន និង ឧ.សិ.ធន់ សំបូរ ព្រមទាំងបុត្រ ...... | ភ.ព. |
| ១៩៨- | ឧ.សិ.ម៉ៅ សុន្ថា ................................................ | ភ.ព. |
| ១៩៩- | ឧ.សិ.មុំ ទូច និង ឧ.សិ.សាមុល គឹមធន់ ( ជាកូន )........ | ភ.ព. |
| ២០០- | ឧ.ស.យន្ត សួន និង ឧ.សិ.តាំង ឈុងប៊ួយ +កូនចៅ ...... | ភ.ព. |
| ២០១- | ឧ.ស.យឹម ស៊ីមុន្នី និង ឧ.សិ.យូ ប៉ូលីន និងបុត្រ+ចៅ ... | ភ.ព. |
| ២០២- | ឧ.សិ.យុន គីមជី និង ឧ.សិ.ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ. | ភ.ព. |
| ២០៣- | ឧ.ស.យូ ម៉េង និង ឧ.សិ.ជួន សំណាង..................... | ក.ព.ស. |
| ២០៤- | ឧ.ស.យ៉ាំ ស្រេន និង ឧ.សិ.អ៊ុល សេងលាង +បុត្រ....... | ភ.ព. |
| ២០៥- | លោក រឿង សេដ្ឋា និង អ្នកស្រី នាង ជួនអេង +បុត្រ .. | ភ.ព. |
| ២០៦- | ឧ.សិ.រៀល យ៉ុន ព្រមទាំងបុត្រ ........................... | ភ.ព. |

| | | |
|---|---|---|
| ២០៧- | ឧ.សិ.លី ស៊ីវជូ ព្រមទាំងបុត្រ និងចៅ ..................... | ភ.ព. |
| ២០៨- | ឧ.សិ.លី ឡៃហ៊ាង និង ឧ.ស.តាំង សុងឈីម+កូនចៅ .. | ភ.ព. |
| ២០៩- | លោក លី ម៉េងហួត និង អ្នកស្រី ហេង ឆេងស៊ីម+បុត្រ. | ភ.ព. |
| ២១០- | ឧ.សិ.លី គុយហ៊ួរ និង ឧ.សិ.លី ហ្គេចឡាង+ស្វាមី+បុត្រ | ភ.ព. |
| ២១១- | ឧ.សិ.លឹម ផៃសាន និង ឧ.សិ.ឆែ សារី +ស្វាមី .......... | ភ.ព. |
| ២១២- | ឧ.សិ.លឹម អេង ព្រមទាំងបុត្រ ............................. | ភ.ព. |
| ២១៣- | លោក លឹម ពួយលី និង អ្នកស្រី ណាំ មួយ+កូនចៅ ..... | ភ.ព. |
| ២១៤- | លោក វង្ស សោភ័ណ្ឌ លោកស្រី ឡោ គឹមលាង+មាតាបិតា. | ភ.ព. |
| ២១៥- | ឧ.សិ.វៀន គង់ និង ស្វាមី+ឧ.សិ.យុត វ៉ាន់ថា និងស្វាមី. | ភ.ព. |
| ២១៦- | ឧ.ស.វ៉ែន សារូ និង ឧ.សិ.តូច លីណារ៉ា ព្រមទាំងបុត្រ... | ភ.ព. |
| ២១៧- | ឧ.ស.សយ ស៊ីផាន់ណា និង ឧ.សិ.ម៉ៅ សុផល+បុត្រ .... | ភ.ព. |
| ២១៨- | ឧ.សិ.សយ វណ្ណា និង ស្វាមី ព្រមទាំងបុត្រ ................ | ភ.ព. |
| ២១៩- | ឧ.ស.ស៊ា បូរ៉ា និង ឧ.សិ.ប៉ុល បុទម+បុត្រ ស៊ា ស៊ូជីង .. | ភ.ព. |
| ២២០- | លោក ស៊ា រស់ និងអ្នកស្រី ញ៉េប ដារ៉េត ព្រមទាំងបុត្រ | ភ.ព. |
| ២២១- | ឧ.ស.សាន សុខគីន និង ឧ.សិ.ប៉ក់ សូត្រសេដ្ឋា +បុត្រ . | ភ.ព. |
| ២២២- | ឧ.សិ.ស៊ីវ យក់លី ............................................... | ភ.ព. |
| ២២៣- | ឧ.ស.ស៊ីវ សៅ និង ឧ.សិ.ស្រ៊ាង វួចលាង+បុត្រ ...... | ភ.ព. |
| ២២៤- | ឧ.ស.ស៊ិន វ៉ា+យានថៃ+ឧ.ស.ស៊ីនម៉េងស្រ៊ុន+បូជុំស៊ីន .. | ភ.ព. |
| ២២៥- | ឧ.ស.ស៊ឹម សុង ឧ.សិ.ឆែ គាង+ពុទ្ធបរិស័ទផ្សារកអណ្ដើក | ព.វ. |
| ២២៦- | ឧ.សិ.សុខ ភួង និង ឧ.សិ.សុខ ផៃ ព្រមទាំងកូនចៅ ..... | ភ.ព. |
| ២២៧- | ឧ.ស.សុខ សារឿន ឧ.សិ.ទូច ម៉ុម ហៅឃីម និងបុត្រ . | ភ.ព. |

២២៨- ឧ.ស.ស៊ុយ ជូ និង ឧ.សិ.តាំង ទ្បេង ព្រមទាំងកូនចៅ .. ភ.ព.

២២៩- ឧ.ស.សួរ សារឹម និង ឧ.សិ.បុង ផល្លី ព្រមទាំងបុត្រ .... ភ.ព.

